ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល









# ផែនការយុទ្ធសាស្ត្រថវិកា

# សម្រាប់ឆ្នាំ ២០២០ - ២០២២

# របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

# មាតិកា

I- **សេចក្តីផ្តើម**

១. បេសកកម្ម និងភារកិច្ចចម្បងៗសម្រាប់ឆ្នាំ២០២០-២០២២ ក្នុងក្របខណ្ឌនៃតួនាទី និងភារកិច្ចរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

២. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៨ (ធៀបសូចនាករដែលបានកំណត់)

៣. បញ្ហាប្រឈម (ដែលត្រូវយកចិត្តទុកដាក់ក្នុងឆ្នាំ២០១៩ និងឆ្នាំខាងមុខ)

៤. វិធានការគោលនយោបាយសម្រាប់រួមចំណែកអនុវត្តអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងវិធានការគោលនយោបាយដែលមានចរិតតាមវិស័យ និងអន្តរវិស័យសម្រាប់ឆ្នាំ២០២០-២០២២

II- **គោលចំណងគោលនយោបាយ**

III- **ការរៀបចំកម្មវិធី**

IV- **ការកំណត់សូចនាករ និងគោលដៅសូចនាករ**

V- **ការកំណត់ធនធាន**

ក. ការគ្រោងចំណូល

ខ. ការកំណត់តម្រូវការចំណាយ

VI- **សេចក្តីសន្និដ្ឋាន**

## I. សេចក្តីផ្តើម

ប្រទេសកម្ពុជាទទួលបានសន្តិភាពពេញលេញនៅចុងឆ្នាំ១៩៩៨ ក្រោមគោលនយោបាយឈ្នះៗរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ សេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សំគាល់ក្នុងរយៈពេលជិត២ទសវត្សចុងក្រោយនេះ កម្ពុជាទទួលបានចំណាត់ថ្នាក់ជា

ប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ និងលឿនបំផុតលំដាប់ទី៦ លើពិភពលោក ដោយសម្រេចបានកំណើនជាមធ្យម៧% នៃផលិតផលជាតិសរុបក្នុង១ឆ្នាំ តាមរយៈការរីកចម្រើនជាបន្តបន្ទាប់លើវិស័យឧស្សាហកម្មកម្មន្តសាល សំណង់ កសិកម្ម សេវាកម្ម ទេសចរណ៍ អចលនទ្រព្យ គមនាគមន៍ និងការដឹកជញ្ជូន។ ដោយឡែករចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា កំពុងផ្លាស់ប្តូរពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកលើវិស័យឧស្សាហកម្ម និងសេវាកម្ម។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជានឹងខិតខំប្រឹងប្រែងបន្តទៀត ដើម្បីឱ្យកម្ពុជាក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៥០។

ដើម្បីជម្រុញដល់កំណើនភ្ញៀវទេសចរណ៍ តាមរយៈគោលនយោបាយបើកចំហជើងមេឃ និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល វិស័យអាកាសចរស៊ីវិលនៅកម្ពុជា បាននឹងកំពុងមានការរីកចម្រើនទៅមុខយ៉ាងខ្លាំងស្ថិតក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់។ ការដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវបានចាត់ទុកថាជាកត្តាផលិតកម្មយុទ្ធសាស្ត្រមួយដ៏សំខាន់ នៃដំណើរការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ឧស្សាហកម្មនេះមានតួនាទីសំខាន់២ គឺការផ្តល់សេវាកម្ម អាជីវកម្ម និងជាយានសម្រាប់កិច្ចការពាណិជ្ជកម្មនៅក្នុងតំបន់ និងលើពិភពលោក។ វិស័យដឹកជញ្ជូនតាមផ្លូវអាកាសដែលមានប្រសិទ្ធភាព មិនត្រឹមតែជួយសម្រួលដល់ការដឹកជញ្ជូនអ្នកធ្វើដំណើរ និងទំនិញនានាក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះទេ ប៉ុន្តែវិស័យនេះ ក៏បានជួយសម្រួលដោយផ្ទាល់ដល់ការបង្កើនសកម្មភាពពាណិជ្ជកម្ម ទេសចរណ៍ បង្កើនចំណូលថវិកាជាតិ និងលើកកម្ពស់ទំនាក់ទំនងសង្គម ព្រមទាំងផ្តល់នូវអត្ថប្រយោជន៍ផ្សេងៗទៀតសម្រាប់ប្រទេសកម្ពុជាយើងផងដែរ។

បន្ទាប់ពីរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ទទួលការធ្វើសវនកម្មពីអង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO Audit) ដែលបានមកធ្វើសវនកម្មលើផ្នែកសុវត្ថិភាពអាកាសចរស៊ីវិល (ICAO USOAP Audit) ពីថ្ងៃទី១៥-២៥ ខែធ្នូ ឆ្នាំ២០១៨ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានជៀសផុតពីប្រទេសដែលមានក្តីបារម្ភលើផ្នែកសុវត្ថិភាពអាកាសចរស៊ីវិល (Significant Safety Concerned) និងពីបញ្ជីខ្មៅ (Black List) របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ ជាហេតុធ្វើឱ្យមានការទាក់ទាញយ៉ាងខ្លាំងពីបណ្តាក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិ និងដៃគូពាណិជ្ជកម្មផ្សេងៗ ដែលមានបំណងចង់វិនិយោគលើវិស័យអាកាសចរស៊ីវិលនៅកម្ពុជា។ ការផ្លាស់ប្តូរសំខាន់ៗជាច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ក្នុងគោលបំណង ដើម្បីជម្រុញឱ្យមានការអនុវត្តតាមបទបញ្ញត្តិបច្ចេកទេសលើផ្នែក សុវត្ថិភាព សន្តិសុខ សេដ្ឋកិច្ច និងបរិស្ថាននៃការដឹកជញ្ជូនតាមផ្លូវអាកាសជាសាកល ហើយជាពិសេសអនុវត្តតាមលក្ខខណ្ឌតម្រូវការនានារបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។

ចំពោះការចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចដំណើរការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមជាតិ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានចាត់វិធានការសំខាន់ៗជាច្រើនដើម្បីកម្ពស់ប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្មអាកាសចរស៊ីវិល ជាពិសេសគឺលើកទឹកចិត្តដល់វិនិយោគិនក្នុងការចូលរួមវិនិយោគសម្រាប់កិច្ចប្រតិបត្តិការសេវាកម្មអាកាសចរស៊ីវិល ដោយបានខិតខំដកចេញនូវរបាំងប្រតិបត្តិការមិនចាំបាច់មួយចំនួនចំពោះកិច្ចការងារនេះ។

**ក- ទស្សនវិស័យ**

អាកាសចរស៊ីវិលកម្ពុជា ត្រូវបានធានានូវសុវត្ថិភាព សន្តិសុខ បរិស្ថាន ប្រសិទ្ធភាពជានិរន្តន៍សម្រាប់ការធ្វើដំណើរ និងការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសក្នុងកម្រិតបទដ្ឋានអន្តរជាតិ។

## ខ- យុទ្ធសាស្ត្រជាតិ

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានសុឆន្ទៈបង្កើតនូវទស្សនវិស័យ និងយុទ្ធសាស្ត្រជាតិមួយប្រកបដោយភាពច្បាស់លាស់ ដើម្បីរៀបចំបង្កើតអោយមានជាប្រព័ន្ធដឹកជញ្ជូនតាមផ្លូវអាកាស ហើយប្រព័ន្ធនេះបានដើរតួនាទីជាកត្តាលីករមួយដ៏សំខាន់ ដើម្បីធ្វើអោយមានការផ្លាស់ប្តូរ និងរីកចម្រើននៃសង្គម និងសេដ្ឋកិច្ចជាតិ ក្នុងគោលដៅសំខាន់គឺ លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងការប្រកួតប្រជែង។ ប្រការនេះនឹងជួយសម្រួលដល់វិនិយោគិន ក្នុងការគណនាព្យាករណ៍លើការរីកចម្រើនផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលគម្រោងរបស់ពួកគេនាពេលអនាគតអាចទទួលបានផលប្រយោជន៍ និងធ្វើឱ្យពួកគេមានទំនុកចិត្តកាន់តែច្រើនជាងមុនចំពោះការអភិវឌ្ឍន៍លើវិស័យអាកាសចរស៊ីវិលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## គ - គោលបំណង

បរិយាកាសដឹកជញ្ជូនផ្លូវអាកាសជាការបង្កើតឡើង និងការសម្របសម្រួលបន្តមួយដែលមានការប្រកួតប្រជែង និងមានលក្ខណៈតម្រង់ទិស ដែលនៅក្នុងនោះរួមមានៈ

- ផលប្រយោជន៍នានានៃអ្នកប្រើប្រាស់អាកាសចរស៊ីវិលត្រូវបានចាត់ទុកថាជាកម្លាំងដឹកនាំជម្រុញនៅក្នុងគ្រប់ ការធ្វើសេចក្តីសម្រេចចិត្តជាប្រព័ន្ធ និងការរៀបចំទាំងអស់
- មានក្របខណ្ឌបទបញ្ញត្តិមួយដែលមានភាពច្បាស់លាស់ និងរឹងមាំអាចសម្របសម្រួលបាននូវតម្រូវការនៃការផ្លាស់ប្តូរ និងតាមកាលៈទេសៈនានា
- សុវត្ថិភាព សន្តិសុខ សេដ្ឋកិច្ច និងបរិស្ថាននៃប្រតិបត្តិការអាកាសចរស៊ីវិល ត្រូវបានធានាតាមរយៈប្រព័ន្ធគ្រប់គ្រងគោលនយោបាយ និងការអនុវត្តដ៏ច្បាស់លាស់
- ទំនុកចិត្តជាលក្ខណៈអន្តរជាតិ ត្រូវបានធានាតាមរយៈការអនុវត្តយ៉ាងហ្មត់ចត់នូវបទដ្ឋានអន្តរជាតិដែល សង្កត់ធ្ងន់ជាចម្បងទៅលើសុវត្ថិភាព សន្តិសុខ និងបរិស្ថាន
- សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសមានគុណភាពជាសកល និងប្រកបដោយសុវត្ថិភាព សន្តិសុខ ប្រសិទ្ធភាព អាចទុកចិត្តបានត្រូវបានផ្តល់នៅក្នុងកម្រិតតម្លៃសមរម្យស្របតាមស្ថានភាពទីផ្សារប្រកួតប្រជែង
- ត្រូវទទួលស្គាល់វិស័យអាកាសចរស៊ីវិលនៅក្នុងពេលបច្ចុប្បន្ននេះ គឺជាផ្នែកមួយដ៏សំខាន់នៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដែលត្រូវធ្វើទំនើបកម្មយ៉ាងឆាប់រហ័ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារតម្រូវឱ្យមានការអភិវឌ្ឍន៍អាកាសយានដ្ឋានស្តង់ដារកម្រិតតំបន់ និងអន្តរជាតិ ដោយផ្តល់អាទិភាពចំពោះអាកាសយានដ្ឋាន អន្តរជាតិដែលមានសកម្មភាពមមាញឹកជាងគេ
- ត្រូវទទួលស្គាល់ថា ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសមានសារៈសំខាន់ចំពោះការរីកចម្រើនផ្នែកសេដ្ឋកិច្ច-សង្គមកិច្ច បង្កើតបាននូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដ៏ជាក់លាក់សម្រាប់ការដឹកជញ្ជូនអ្នកដំណើរ និងទំនិញតាមផ្លូវអាកាស និងត្រូវលើកទឹកចិត្តដល់ការផ្តល់សេវាកម្មដែលមានសមត្ថភាពប្រកួតប្រជែងខ្ពស់
- ប្រតិបត្តិការរបស់ក្រុមហ៊ុនអាកាសចរណ៍ និងការលើកកំពស់សមត្ថភាពប្រកួតប្រជែង គឺត្រូវបានចាត់ទុកថាជាការចូលរួមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងប្រទេសកម្ពុជា

- វិស័យអាកាសចរស៊ីវិលកម្ពុជា ត្រូវទទួលបានទទួលការលើកទឹកចិត្តឱ្យមានការពង្រីកបន្ថែមក្នុងកម្រិតមួយប្រទាក់ក្រឡាគ្នាទៅនឹងការរីកចម្រើនរបស់វិស័យអាកាសចរស៊ីវិលអន្តរជាតិ
- ទំនាក់ទំនងជាមួយនឹងវិស័យដឹកជញ្ជូនផ្សេងៗទៀតត្រូវបានលើកទឹកចិត្ត និងខិតខំបង្កើតឱ្យមានឡើង
- ពាណិជ្ជកម្មទេសចរណ៍ និងសកម្មភាពសេដ្ឋកិច្ចទូទៅ និងការរីកចម្រើនផ្សេងៗទៀតត្រូវបានលើកទឹកចិត្ត
- ជម្រុញកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់ តំបន់ និងអន្តរជាតិនៅក្នុងវិស័យអាកាសចរស៊ីវិល និងការអភិវឌ្ឍន៍ដែលមានការសម្របសម្រួលតាមនិន្នាការអន្តរជាតិ និងការអនុវត្តល្អប្រសើរបំផុតដែលមានសង្គតិភាពជាមួយនឹងអធិបតេយ្យភាពនៃដែនអាកាសរបស់កម្ពុជា
- មានការពិចារណាទៅលើគម្រោងការនានានៃហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ ដើម្បីទទួលបាននូវប្រសិទ្ធភាពចំណាយ និងការសន្សំសំចៃខ្ពស់សម្រាប់ទទួលបានផលប្រយោជន៍ពីគ្នាទៅវិញទៅមករបស់បណ្តាប្រទេសមួយចំនួនដែលបានចូលរួមសកម្មភាពជាមួយគ្នា
- ការអភិវឌ្ឍន៍យន្តហោះ ព្រមទាំងគ្រឿងបន្លាស់សម្រាប់បម្រើឱ្យយន្តហោះ និងផលិតផលអាកាសចរណ៍នានានៅក្នុងប្រទេសត្រូវបានទទួលការលើកទឹកចិត្ត
- ប្រព័ន្ធតាមដាន និងគ្រប់គ្រងទិន្នន័យដែលមានប្រសិទ្ធភាពនានា នឹងត្រូវបានបង្កើតឡើងសម្រាប់ការគ្រប់គ្រងឧប្បទ្វវហេតុ និងគ្រោះថ្នាក់អាកាសចរណ៍ឱ្យបានទាន់ពេលវេលា ក្នុងនោះរួមមានទាំងការស៊ើបអង្កេតតាមដានគ្រោះថ្នាក់/ឧបទ្ទវហេតុនានាផងដែរ
- បន្តអនុវត្តគោលនយោបាយលើកកម្ពស់សមភាពយេនឌ័រដោយបង្កើនកាលានុវត្តភាព និងលើកតម្កើងតួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តកម្រិតគ្រប់គ្រង និងបច្ចេកទេសតាមរយៈការយកចិត្តទុកដាក់បណ្តុះបណ្តាលជំនាញដល់ស្ត្រីនៅគ្រប់កម្រិត
- បន្តសហការចូលរួមជាមួយដៃគូរសន្ធនាជាតិ និងអន្តរជាតិ ក្នុងកិច្ចការពារបរិស្ថាន និងទប់ស្កាត់ការប្រែប្រួលអាកាសធាតុ។
- លើកកម្ពស់ការបង្កើនគម្របបៃតង កាត់បន្ថយផលប៉ះពាល់ និងភាពរំខានដែលបង្កឡើងដោយផ្ទាល់ និងមិនផ្ទាល់ពីវិស័យអាកាសចរណ៍។

## ១- បេសកកម្ម និងភារកិច្ចចម្បងៗសម្រាប់ឆ្នាំ២០២០-២០២២ ក្នុងក្របខណ្ឌនៃតួនាទី និងភារកិច្ចរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

### ១.១- បេសកកម្ម

ដើម្បីធានាបាននូវប្រសិទ្ធភាព និងលើកកម្ពស់គុណភាពសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលអនុវត្តតួនាទី និងភារកិច្ចផ្អែកតាមអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលមានបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យអាកាសចរស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។ បេសកកម្មនេះ ដើម្បីរក្សា និងសម្របសម្រួលរាល់ប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រនិងគោលនយោបាយ រួមទាំងបទបញ្ញត្តិប្រកបដោយប្រសិទ្ធភាព និងការផ្តល់ប្រឹក្សាពីអ្នកជំនាញការបរទេស និងដើម្បីធ្វើឱ្យការដឹកជញ្ជូនតាមផ្លូវអាកាស ឆ្លើយតបបានយ៉ាងល្អប្រសើរបំផុតចំពោះតម្រូវការនានារបស់អ្នកប្រើប្រាស់ និងសង្គម ដោយផ្អែកតាមបទដ្ឋានប្រតិបត្តិការបច្ចេកទេស សុវត្ថិភាព សន្តិសុខ បរិស្ថាន គុណភាព ប្រសិទ្ធិភាពចំណាយនៅក្នុងទម្រង់មួយដែលមាននិរន្តរភាព និងជម្រុញឱ្យមានកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់នៃការដឹកជញ្ជូនតាមផ្លូវអាកាស។ ជាមួយគ្នានេះដែរ ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានចូលរួមយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមគោលការណ៍ដ៏ត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ និងធុរកិច្ច។

### ១.២- ភារកិច្ចចម្បងៗរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

ភារកិច្ចចំបងៗរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ការអនុវត្តក្នុងតួនាទីរបស់វិស័យអាកាសចរស៊ីវិល មានដូចខាងក្រោមៈ

**(I)- និយតករ (បញ្ញត្តិករ) និងការត្រួតពិនិត្យ**

**ក- តួនាទីនិយតករ (បញ្ញត្តិករ) និង ការត្រួតពិនិត្យលើសុវត្ថិភាពហោះហើរ**

- បញ្ញត្តិ និងត្រួតពិនិត្យនូវរាល់ប្រតិបត្តិការរបស់យន្តហោះដែលត្រូវចុះបញ្ជីនៅប្រទេសកម្ពុជា
- បញ្ញត្តិ និងត្រួតពិនិត្យនូវរាល់ប្រតិបត្តិការរបស់ក្រុមហ៊ុនប្រើប្រាស់ដែនអាកាសលើសុវត្ថិភាពហោះហើរ
- បញ្ញត្តិ និងត្រួតពិនិត្យនូវរាល់ប្រតិបត្តិការរបស់សន្តិសុខអាកាសយានដ្ឋាន
- បញ្ញត្តិ និងត្រួតពិនិត្យនូវរាល់ប្រតិបត្តិការរបស់អាកាសយានដ្ឋាន និងការនាំផ្លូវអាកាស
- សវនកម្ម/អធិការកិច្ច និងការចេញវិញ្ញាបនប័ត្រលើរាល់កិច្ចប្រតិបត្តិការសេវាកម្ម/អាជីវកម្មដឹកជញ្ជូនតាមផ្លូវអាកាស
- គ្រប់គ្រង និងត្រួតពិនិត្យបរិស្ថានអាកាសចរស៊ីវិល
- ធានានូវរាល់ច្បាប់ និងបទបញ្ញត្តិដែលកំពុងមានក្នុងវិស័យអាកាសចរស៊ីវិល ដោយអនុលោមតាមគោលការណ៍ណែនាំ បទដ្ឋាន និងអនុសាសន៍អនុវត្ត រួមទាំងនីតិវិធី និងការអនុវត្តទាំងឡាយ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាអាកាសចរស៊ីវិលអន្តរជាតិ និងឯកសារពាក់ព័ន្ធនានាដែលបានចែងឡើងដោយអង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។

**ខ- បញ្ញត្តិកម្មអាកាសយានដ្ឋាន និងការត្រួតពិនិត្យលើប្រតិបត្តិការ**

- បញ្ញត្តិ និងត្រួតពិនិត្យលើការធ្វើផែនការ រចនាប្លង់ ការស្ថាបនា និងប្រតិបត្តិការរបស់អាកាសយានដ្ឋានទាំងអស់ក្នុងប្រទេសកម្ពុជា រួមទាំងអាកាសយានដ្ឋានស្ថិតនៅក្រោមរូបភាពកិច្ចសន្យាសម្បទាន
- ប្រតិបត្តិ និងគ្រប់គ្រងអាកាសយានដ្ឋានទាំងអស់ លើកលែងតែអាកាសយានដ្ឋានទាំងឡាយណា ដែលត្រូវបានរដ្ឋាភិបាលបានធ្វើសម្បទានរួច
- ធ្វើផែនការអភិវឌ្ឍ និងរក្សាស្តង់ដារ ដើម្បីប្រសិទ្ធភាព និងសេវាកម្មទាំងឡាយក្នុងកិច្ចប្រតិបត្តិការអាកាសយានដ្ឋាន
- ធានាការកសាងផែនការ ការសាងសង់ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានស្របតាមបទដ្ឋានដែលបានកំណត់
- គ្រប់គ្រង ត្រួតពិនិត្យ និងសម្រួលដល់ប្រតិបត្តិការរបស់អ្នកអភិវឌ្ឍអាកាសយានដ្ឋាន ប្រតិបត្តិជាមួយនឹងស្តង់ដារដែលបានកំណត់
- គ្រប់គ្រង ត្រួតពិនិត្យមើលសំលេងយន្តហោះ និងវិធានការកាត់បន្ថយសំលេង
- គ្រប់គ្រងគោលនយោបាយទាក់ទងនឹងកិច្ចការពារបរិស្ថាន និងអតិបរមាភាវូបនីយកម្មនូវការប៉ះពាល់បរិស្ថាន ដោយសារតែការអភិវឌ្ឍ និងការអនុវត្តរបស់ប្រតិបត្តិករអាកាសចរណ៍ (Air Operators)
- គ្រប់គ្រង ត្រួតពិនិត្យ សម្របសម្រួល (Facilitation) ការអនុវត្តគោលនយោបាយទាក់ទងនឹងការចូលរួមភាពជាដៃគូរវាង រដ្ឋ និងឯកជន (PPP) ក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល។

**គ- បញ្ញត្តិកម្មប្រតិបត្តិការលំហអាកាស និង ប្រតិបត្តិការ**

- បញ្ញត្តិ និងត្រួតពិនិត្យលើប្រតិបត្តិការរបស់ក្រុមហ៊ុនផ្តល់សេវានាំផ្លូវអាកាស ដើម្បីធានាឱ្យបាននូវការហោះហើរជាប្រក្រតីនៅក្នុងតំបន់ព័ត៌មានហោះហើរភ្នំពេញ (FIR)
- គ្រប់គ្រង ត្រួតពិនិត្យ និងសម្របសម្រួល (Facilitation) ប្រតិបត្តិការសេវាកម្មត្រួតពិនិត្យហោះហើរ ស្របតាមកិច្ចព្រមព្រៀងច្បាប់ និងបទបញ្ញត្តិ
- អតិបរមាភាវូបនីយកម្មសមត្ថភាពលំហអាកាសក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) សមាគមដឹកជញ្ជូនផ្លូវអាកាសអន្តរជាតិ (IATA) និងក្រុមអ្នកប្រើប្រាស់ផ្សេងទៀត។

**ឃ- តួនាទីត្រួតពិនិត្យផ្នែកសេដ្ឋកិច្ចអាកាសចរណ៍**

- ធ្វើអប្បបរមានូវហានិភ័យលើសេវាកម្មអាកាសយានដ្ឋាន/ការផ្តល់សេវាកម្មនាំផ្លូវអាកាស (Airport/ Air Navigation Services Providers/ANSPs) និងសេវាកម្មដ៏ទៃទៀត ដែលជាប់ទាក់ទងនឹងការអនុវត្តទាំងឡាយមានលក្ខណៈប្រឆាំងការប្រកួតប្រជែង
- ធានាមិនឱ្យមានការរើសអើង និងមានតម្លាភាពក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីប្រតិបត្តិការអាជីវកម្ម
- កៀរគររកប្រភពទុនវិនិយោគ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនាពេលបច្ចុប្បន្ន និងនៅអនាគត

- ការពារផលប្រយោជន៍ទាំងឡាយរបស់អ្នកដំណើរ និងអ្នកប្រើប្រាស់ចុងក្រោយផ្សេងៗទៀត
- អភិវឌ្ឍ និងអនុវត្តប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការសេវាកម្មនាំផ្លូវអាកាសមួយប្រកបដោយសក្តិសិទ្ធភាព និងប្រសិទ្ធផល។

**(II)- ការផ្តល់សេវាកម្មអាកាសចរស៊ីវិល**

- ធ្វើផែនការ និងអភិវឌ្ឍន៍ប្រព័ន្ធវិទ្យុនាំផ្លូវអាកាស និងការគ្រប់គ្រងចរាចរដែនអាកាសថ្មី (New CNS/ATM)
- គ្រប់គ្រង និងត្រួតពិនិត្យលើការផ្តល់សេវាកម្មនាំផ្លូវអាកាស (ចេញ-ចូល) ក្នុង និងឆ្លងដែនអាកាសកម្ពុជា
- ផ្តល់សេវាកម្មចុះចតជាលក្ខណៈឯកជន (Charter Flight)
- ផ្តល់សេវាកម្មរុករក សង្គ្រោះបន្ទាន់ និងពន្លត់អគ្គីភ័យសម្រាប់យន្តហោះស្ថិតនៅក្នុងភាពគ្រោះថ្នាក់ក្នុងតំបន់ពត៌មានហោះហើរភ្នំពេញ (FIR)
- ការផ្តល់ជូនវិញ្ញាបនប័ត្រ/អាជ្ញាប័ណ្ណជូនប្រតិបត្តិករអាកាសចរណ៍ ប្រតិបត្តិករអាកាសយានដ្ឋាន ជួសជុលយន្តហោះ បុគ្គលិកបំរើការហោះហើរ អ្នកត្រួតពិនិត្យចរាចរដែនអាកាស និងសេវាកម្មផ្សេងៗទៀតដែលពាក់ព័ន្ធ។

**(III)- ការផ្តល់យោបល់ផែនការគោលនយោបាយ និងការអភិវឌ្ឍន៍**

**ក- មុខងារផ្តល់យោបល់**

- ផ្តល់យោបល់ដល់រដ្ឋាភិបាលលើរាល់បញ្ហាដែលទាក់ទងនឹងវិស័យអាកាសចរស៊ីវិលនៅកម្ពុជា
- ដើរតួនាទីក្នុងកិច្ចការអន្តរជាតិក្នុងនាមរាជរដ្ឋាភិបាល និងជាអាជ្ញាធរតំណាងប្រទេសកម្ពុជាលើបញ្ហានានា ដែលទាក់ទងដល់វិស័យអាកាសចរស៊ីវិល
- ផ្តល់យោបល់ និងអនុសាសន៍លើរាល់បញ្ហាដែលទាក់ទងនឹងគោលនយោបាយ ច្បាប់ បទញ្ញត្តិ និងបទដ្ឋានគតិយុត្តនានារបស់អាកាសចរស៊ីវិល និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនតាមផ្លូវអាកាស និងកិច្ចប្រតិបត្តិការនានា។

**ខ- មុខងារធ្វើផែនការគោលនយោបាយ និងការអភិវឌ្ឍន៍**

- ផ្តួចផ្តើម និងរៀបចំគោលនយោបាយសម្រាប់វិស័យអាកាសចរស៊ីវិល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ កំណត់គោលដៅ តម្រង់ទិសសម្រាប់រយៈពេលខ្លី មធ្យម និងវែងក្នុងវិស័យដឹកជញ្ជូនតាមផ្លូវអាកាស
- ផ្តួចផ្តើម សម្របសម្រួល និងពិនិត្យឡើងវិញលើការកែលម្អផែនការសកម្មភាពអាទិភាពដែលបានកំណត់នៅក្នុងគោលនយោបាយ/កម្មវិធី/អនុកម្មវិធីរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍ និងគោលនយោបាយវិស័យអាកាសចរស៊ីវិល
- ត្រួតពិនិត្យ សម្របសម្រួល និងរក្សាឱ្យបាននូវទំនួលខុសត្រូវសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនតាមផ្លូវអាកាស និងការអភិវឌ្ឍន៍ធុរកិច្ចទាំងអស់សម្រាប់ប្រព័ន្ធនាំផ្លូវហោះហើរ និងអាកាសយានដ្ឋាន

- ត្រួតពិនិត្យ ផ្តល់យោបល់ និងសម្របសម្រួលរាល់ការអភិវឌ្ឍន៍ធុរកិច្ច និងប្រតិបត្តិការស្ថិតនៅក្រោមកិច្ចសន្យាសម្បទាន ដោយអនុលោមតាមច្បាប់របស់កម្ពុជាជាធរមាន
- គ្រប់គ្រង និងសម្របសម្រួលកិច្ចសហប្រតិបត្តិការអនុតំបន់ តំបន់ និងអន្តរជាតិគ្រប់រូបភាពដែលទាក់ទងដល់វិស័យអាកាសចរស៊ីវិល
- ផ្តល់យោបល់លើរាល់សកម្មភាពដែលទាក់ទងដល់គោលនយោបាយ ច្បាប់ បទបញ្ញត្តិនិងលិខិតបទដ្ឋាន និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធវិស័យអាកាសចរស៊ីវិល និងប្រតិបត្តិការនានា។

**(IV)- ការអភិវឌ្ឍន៍សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស**

- រៀបចំផែនការគោលនយោបាយ និងបទបញ្ញត្តិ ស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាសឱ្យស្របទៅតាមគោលបំណង និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសអង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) និងសមាគមដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ (IATA)
- សិក្សាស្រាវជ្រាវ និងវិភាគទីផ្សារឧស្សាហកម្មអាកាសចរណ៍
- រៀបចំ និងផ្សព្វផ្សាយចំពោះដំណើរការអភិវឌ្ឍវិស័យអាកាសចរស៊ីវិលនៅកម្ពុជា
- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃបច្ចេកទេស និងសេដ្ឋកិច្ចដែលពាក់ព័ន្ធដល់គោលនយោបាយដឹកជញ្ជូនតាមផ្លូវអាកាស
- ត្រួតពិនិត្យគុណភាពសេវាកម្មរបស់សហគ្រាសឧស្សាហកម្មអាកាសចរស៊ីវិល ឱ្យស្របទៅតាមកម្រិតស្តង់ដាររបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) និងសមាគមដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ (IATA)
- រៀបចំចរចា និងបង្កើតអនុស្សារណៈយោគយល់លើកិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិនានា ស្តីពីការធ្វើសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស (ASA)
- ចូលរួមគ្រប់គ្រង និងចាត់ចែងលើការងារអាកាសចរណ៍ចាំបាច់មួយចំនួន ដូចជា៖ ការធ្វើសេរីភាវូនីយកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាមួយសមាគមដឹកជញ្ជូនអាស៊ាន និងអង្គការដ៏ទៃទៀតទាំងក្នុងកម្រិតតំបន់ និងអន្តរជាតិ
- ពង្រីកបណ្តាញសេវាកម្មដឹកជញ្ជូនផ្លូវអាកាសអន្តរជាតិរវាងកម្ពុជា និងប្រទេសផ្សេងៗទៀតទាំងថ្នាក់តំបន់ និងសកលលោក។

## ២- លទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៨ (ធៀបសូចនាករដែលបានកំណត់)

### ២.១- ស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០

ផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (រ.ល.អ.ស) គឺជាឧបករណ៍មួយដ៏សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ រ.ល.អ.ស និងគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺបង្កើនវិចារណកម្មអាទិភាពចំណាយឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ រ.ល.អ.ស ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ រ.ល.អ.ស ដើម្បីសម្រេចគោលបំណងគោលនយោបាយដែលបានដាក់ចេញ និងជាមូលដ្ឋានសម្រាប់បង្ហាញអំពីតម្រូវការ ថវិកាសម្រាប់អនុវត្តគោលនយោបាយ និងសម្រាប់ការរៀបចំថវិកា និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។

ឆ្នាំ២០១៨ ជាឆ្នាំទី៣ ដែលរាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យរដ្ឋលេខាធិកាដ្ឋានអាកាសចរស៊ីវិលអនុវត្តថវិកាកម្មវិធីពេញលេញ ក្នុងគោលបំណងដើម្បីផ្តល់សិទ្ធអំណាច និងការទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពការងារ ដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ និងអាចវាស់វែងបាន និងជួយសម្រួលដល់អង្គភាពថវិកាទាំង២ ដែលជាប្រតិបត្តិករថវិកាកម្មវិធី ព្រមទាំងរួមចំណែកដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។ ជាពិសេសគឺការបង្កើនប្រសិទ្ធភាព សក្តិសិទ្ធិភាព និងលើកកម្ពស់តម្លាភាព គណនេយ្យភាពក្នុងការគ្រប់គ្រង និងការអនុវត្តថវិកាទៅតាមសកម្មភាពការងារអាទិភាព និងសម្រេចបានលទ្ធផលការងារកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ទាំងទិដ្ឋភាពថវិកា និងទិដ្ឋភាពនៃការផ្តល់សេវាកម្មបច្ចេកទេសជូនដល់ប្រតិបត្តិករអាកាសចរណ៍ ក៏ដូចជាធានាបាននូវសន្តិសុខ និងសុវត្ថិភាពជូនអ្នកដំណើរតាមផ្លូវអាកាស។

ការផ្ទេរសិទ្ធិអំណាចក្នុងការគ្រប់គ្រងថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងការផ្ទេរសិទ្ធិអំណាចពីនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ មកអង្គភាពថវិកា រួមទាំងការចេញគោលការណ៍ណែនាំ និងនីតិវិធីអនុវត្តការងារមួយចំនួនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចជា៖ ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី និងប្រកាសស្តីពីសិទ្ធិអំណាច និងការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា គឺជាផែនទីបង្ហាញផ្លូវមួយដ៏សំខាន់ដែលបានបង្កលក្ខណៈងាយស្រួលដល់ការអនុវត្តថវិកាកម្មវិធី ជាពិសេសគឺការបែងចែកនូវសិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់រវាងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ (នាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ) និងអង្គភាពថវិកា ទាំងនៅក្នុងដំណាក់កាលរៀបចំថវិកា ដំណាក់កាលអនុវត្តថវិកា និងដំណាក់កាលត្រួតពិនិត្យ និងតាមដានការអនុវត្តថវិកា។

ការអនុវត្តថវិកាឆ្នាំ២០១៨ អង្គភាពថវិកាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការចូលរួមរៀបចំ និងវិភាជថវិកាសម្រាប់បម្រើឱ្យការអនុវត្តផែនការសកម្មភាពអាទិភាពតាមបណ្តានាយកដ្ឋាន និងអង្គភាពនានា ក្រោមចំណុះអង្គភាពទាំង២ ប្រកបដោយតម្លាភាព គណនេយ្យភាព ការទទួលខុសត្រូវ និងសម្រួលដល់ការចំណាយទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី ព្រមទាំងចំណាត់ថ្នាក់មុខងារ ដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក៏ដូចជាគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីរួមចំណែកសម្រេចឱ្យបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ជាពិសេស យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣។

**សមិទ្ធផលនានា ដែលរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលសម្រេចបានក្នុងឆ្នាំ២០១៨ រួមមាន៖**

## ១. ការងាររដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស

### ១.១ ការងាររដ្ឋបាល

ដើម្បីធានាបាននូវនិរន្តរភាព និងប្រសិទ្ធភាពក្នុងការដឹកនាំ និងគ្រប់គ្រងការបំពេញការងាររបស់មន្ត្រីក្រោមឱវាទឱ្យសម្រេចបានជោគជ័យតាមផែនការ និងលទ្ធផលរំពឹងទុក រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានរៀបចំនូវផែនការការងារប្រចាំឆ្នាំរបស់បណ្តានាយកដ្ឋាន និងអង្គភាពក្រោមចំណុះទាំងអស់ ការពិពណ៌នាមុខតំណែង សំដៅដល់ការកំណត់អំពីតួនាទីភារកិច្ច និងការទទួលខុសត្រូវ ព្រមទាំងលក្ខណៈសម្បត្តិសមស្របសម្រាប់កាន់មុខតំណែងតាមរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងការិយាល័យក្រោមចំណុះទាំងអស់ ជាពិសេសគឺ

ការរៀបចំលក្ខខណ្ឌការងារ ការគ្រប់គ្រងបញ្ជីវត្តមាន និងការរៀបចំរបាយការណ៍លទ្ធផល និងការត្រួតពិនិត្យឡើងវិញ។

ជាលទ្ធផលការងាររដ្ឋបាល រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលអនុវត្តទទួលបានភាពជោគជ័យទៅតាមផែនការដែលបានកំណត់នៅក្នុងឆ្នាំ ដូចជា៖ ការរៀបចំពិពណ៌នាមុខតំណែងគ្រប់គ្រង, ការគ្រប់គ្រងគុណផលគឺបានដំណើរការជាបណ្តើរៗ តាមរយៈការបំពេញការងាររបស់មន្ត្រីរាជការដោយផ្អែកតាមប្រព័ន្ធគ្រប់គ្រងគុណផល ដើម្បីជម្រុញឱ្យមន្ត្រី និងអ្នកគ្រប់គ្រងមានការទទួលខុសត្រូវ មានការចូលរួម និងបំពេញការងារឱ្យអស់ពីសមត្ថភាពរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍសមត្ថភាព។ រាល់ឯកសាររដ្ឋបាលត្រូវបានរៀបចំទុកដាក់មានសណ្តាប់ធ្នាប់ ទាំងឯកសារចូល និងឯកសារចេញ។ រាល់កិច្ចប្រជុំទាំងកម្រិតជាតិ និងកម្រិតអន្តរជាតិ ត្រូវបានធានា និងបង្កលក្ខណៈងាយស្រួលភ្ញៀវជាតិ និងអន្តរជាតិលើការផ្តល់សេវាកម្មផ្សេងៗ ដូចជា ភេសជ្ជៈ អនាម័យ និងបរិស្ថាននៅក្នុងបរិវេណអគាររដ្ឋបាលរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលទាំងមូល។

ជាមួយគ្នានេះដែរ ការងារពិធីការរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានសហការជាមួយគណៈកម្មាធិការបុណ្យជាតិ និងអន្តរជាតិ ក៏ដូចជាក្រុមពិធីការសម្តេចតេជោ នាយករដ្ឋមន្ត្រី ក្នុងការរៀបចំពិធីជូន និងទទួលដំណើរគណៈប្រតិភូជាន់ខ្ពស់ជាតិ និងអន្តរជាតិ រួមមាន៖ ស្ថាប័នព្រះមហាក្សត្រ ស្ថាប័នព្រឹទ្ធសភា ស្ថាប័នរដ្ឋសភា ស្ថាប័នរាជរដ្ឋាភិបាល។

## ១.២ ការងារគ្រប់គ្រងបុគ្គលិក

នៅឆ្នាំ២០១៨ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលមានមន្ត្រីរាជការសរុបចំនួន៧៤៦នាក់ ក្នុងនោះស្ត្រីចំនួន១៩២នាក់ (មន្ត្រីគ្មានក្របខណ្ឌចំនួន១២នាក់ និងមន្ត្រីមានក្របខណ្ឌចំនួន៧៣៤នាក់)។ ផ្អែកតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងបទដ្ឋានគតិយុត្តនានា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានសម្រេចកាត់មន្ត្រីរាជការចេញពីក្របខណ្ឌចំនួន២៧នាក់ ក្នុងនោះមន្ត្រីរាជការចូលនិវត្តន៍ចំនួន២៣នាក់, ផ្ទេរក្របខណ្ឌចេញចំនួន២នាក់, ទទួលមរណភាពចំនួន១នាក់ និងកាត់ចេញពីក្របខណ្ឌចំនួន១នាក់។

ដើម្បីធានាបាននូវប្រសិទ្ធផលក្នុងការអនុវត្តការងារប្រចាំថ្ងៃ និងផ្អែកតាមរចនាសម្ព័ន្ធនៃអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានធ្វើការបែងចែកមុខតំណែងតាមកម្រិត ដូចខាងក្រោម៖

**ក. ថ្នាក់ដឹកនាំកម្រិតនយោបាយ** សរុបចំនួន៩នាក់ (ស្រីចំនួន១នាក់) ក្នុងនោះ៖

- រដ្ឋមន្ត្រីទទួលបន្ទុក ចំនួន១នាក់ (គ្មានក្របខណ្ឌ)
- រដ្ឋលេខាធិការប្រចាំការ ចំនួន១នាក់ (មានក្របខណ្ឌ)
- អនុរដ្ឋលេខាធិការ ចំនួន៧នាក់ (មានក្របខណ្ឌចំនួន២នាក់ និងក្របខណ្ឌចំនួន៥នាក់)

**ខ. ថ្នាក់ដឹកនាំកម្រិតបច្ចេកទេស** សរុបចំនួន៤៩០នាក់ (ស្រីចំនួន១០៩នាក់) ក្នុងនោះ៖

• ថ្នាក់អគ្គនាយកដ្ឋាន៖
- អគ្គនាយក ចំនួន២នាក់
- អគ្គនាយករង ចំនួន១៨នាក់ (ស្រីចំនួន៣នាក់)

• ថ្នាក់នាយកដ្ឋាន៖

- ប្រធាន ចំនួន១៧នាក់
- អនុប្រធាន ចំនួន៩៧នាក់ (ស្រីចំនួន១៣នាក់)
- ថ្នាក់ការិយាល័យ
- ប្រធាន ចំនួន១០៤នាក់ (ស្រីចំនួន១៧នាក់)
- អនុប្រធាន ចំនួន២៥២នាក់ (ស្រីចំនួន៧៦នាក់)

**គ. ទីប្រឹក្សា និងជំនួយការ** សរុបចំនួន២៥នាក់ (ស្រីចំនួន៣នាក់) ក្នុងនោះ៖

- ឋានៈស្មើរដ្ឋលេខាធិការ ចំនួន៣នាក់
- ឋានៈស្មើអនុរដ្ឋលេខាធិការ ចំនួន៩នាក់
- ឋានៈស្មើអគ្គនាយក ចំនួន១៣នាក់។

ជាលទ្ធផលការងារគ្រប់គ្រងបុគ្គលិក បានបង្កើតគណៈកម្មការវាយតម្លៃចំណាត់ថ្នាក់លើការតម្លើង ឋានន្តរសក្តិ និងថ្នាក់តាមវេណជ្រើសរើស និងវេណអតីតភាពការងារជូនមន្ត្រីរាជការ និងតាមសញ្ញាប័ត្រ មានចំនួន៣៩៤នាក់ តាមក្របខ័ណ្ឌដូចខាងក្រោម៖

- ក្របខ័ណ្ឌ ក១ និងក២ ចំនួន១៣២នាក់ ក្នុងនោះ៖
- ក្របខ័ណ្ឌរដ្ឋបាល ចំនួន៩៥នាក់ (តម្លើងថ្នាក់ចំនួន៧២នាក់ និងតម្លើងឋានន្តរសក្តិចំនួន២៣នាក់)
- ក្របខ័ណ្ឌមន្ត្រីបច្ចេកទេស ក៣, ខ និង គ ចំនួន៣៧នាក់ (តម្លើងថ្នាក់ចំនួន២៥នាក់ និងតម្លើងឋានន្តរសក្តិចំនួន១២នាក់)
- ក្របខ័ណ្ឌមន្ត្រីរដ្ឋបាល ក៣, ខ និង គ ចំនួន១៤៣នាក់ (តម្លើងថ្នាក់ចំនួន១៣៨នាក់ និងតម្លើងឋានន្តរសក្តិចំនួន៥នាក់)
- ក្របខ័ណ្ឌមន្ត្រីបច្ចេកទេស ក៣, ខ និង គ ចំនួន១១៩នាក់ (តម្លើងថ្នាក់ចំនួន១១២នាក់ និងតម្លើងឋានន្តរសក្តិចំនួន៧នាក់)។

ជាមួយគ្នានេះដែរ នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ក៏បានរៀបចំសំណុំបែបបទនៃការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល តារាងគ្រោង និងឯកសារពាក់ព័ន្ធទៅក្រសួងមុខងារសាធារណៈ ដើម្បីសុំទិដ្ឋាការ និងតារាងបើកបៀវត្សមន្ត្រីរាជការរៀងរាល់ខែ។ ផ្អែកតាមលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល នាយកដ្ឋាន ក៏បានរៀបចំកែសម្រួល និងតម្លើងបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។ ព្រមជាមួយគ្នា នាយកដ្ឋានបានរៀបចំ និងដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍សម្រាប់ឆ្នាំ២០១៨ និងរៀបចំផែនការតម្រូវការក្របខ័ណ្ឌប្រចាំឆ្នាំ២០១៩ ទៅក្រសួងមុខងារសាធារណៈ។

ធនធានមនុស្សដែលមានជំនាញអាកាសចរស៊ីវិលសម្រាប់បម្រើការងារត្រួតពិនិត្យសុវត្ថិភាព សន្តិសុខ និងការផ្តល់សេវាកម្មអាកាសចរស៊ីវិលឆ្នាំ ២០១៨ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានដូចខាង ក្រោម៖

| ល.រ | ប្រភេទជំនាញ | ចំនួនមន្ត្រីបច្ចេកទេស ឆ្នាំ២០១៨ | ចំនួនមន្ត្រីបច្ចេកទេស ឆ្នាំ២០១៩ |
|---|---|---|---|
| INSPECTORS | | | |
| ១ | Flight Operation Inspectors | ០៨ | ០៧ |
| ២ | Air Worthiness Inspectors | ០៩ | ០៩ |
| ៣ | Aerodrome Inspectors | ០៧ | ០៤ |
| ៤ | Aviation Security Inspectors | ០៥ | ០៥ |
| ៥ | Air Navigation Standards & Safety Inspectors | ០៩ | ១១ |
| ៦ | Dangerous Goods Inspectors | ០៤ | ០២ |
| ៧ | Personnel Licensing Inspectors | ០៣ | ០៤ |
| ៨ | Fire Fighting and Rescue Inspector | ០១ | ០១ |
| ៩ | Cabin Safety Inspector | ០១ | ០២ |
| **DESIGNER / VALIDATOR / INVESTIGATOR /INSTRUCTOR** | | | |
| ១០ | Language Proficiency Interviewers/ Raters | ០៥ | ០៥ |
| ១១ | Aircraft Accident Investigators | ០៥ | ០៥ |
| ១២ | Airbus Flight Data Analyst | ០២ | ០២ |
| ១៣ | AIS Instructor | ០២ | ០២ |
| ១៤ | CNS/ATM Instructors | ០៤ | ០៤ |
| ១៥ | Dangerous Goods Instructors | ០២ | ០២ |
| ១៦ | Aviation English Instructors | ០៣ | ០៣ |
| ១៧ | Air Traffic Control Instructors | ០៣ | ០៤ |
| ១៨ | Fire Fighting Instructors | ០២ | ០២ |
| ១៩ | AVSEC Instructors | ០៤ | ០៤ |
| ២០ | Flight Instructors | ០៣ | ០៣ |
| ២១ | Course Developers | ០៣ | ០៣ |
| ២២ | Search and Rescue Administrators | ០៥ | ០៦ |
| **PUBLIC SERVICE PROVIDERS** | | | |
| ២៣ | Flight Procedure Designers | ០៩ | ០៩ |
| ២៤ | NAVAIDs Installers | ០៣ | ០៣ |
| ២៥ | Qualified Aviation Meteorology Officers | ២៦ | ៣៦ |
| ២៦ | Air Traffic Controllers | ១២០ | ១២០ |
| ២៧ | Pilots | ១៤ | ២០ |
| | សរុប | ២៦២ | ២៧៨ |

## ១.៣ ការអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យអាកាសចរស៊ីវិលឆ្នាំ២០១៨ និងទិសដៅឆ្នាំ២០២០

### ១.៣.១ លទ្ធផលសម្រេចបានសម្រាប់ឆ្នាំ២០១៨

ដើម្បីឆ្លើយតបទៅនឹងតម្រូវការធនធានមនុស្សលើជំនាញអាកាសចរស៊ីវិល និងដើម្បីដោះស្រាយបញ្ហាប្រឈមដែលត្រូវបានរកឃើញដោយក្រុមសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិក្នុងឆ្នាំ២០១៨ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានពង្រឹងសមត្ថភាពមន្ត្រីតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទៅតាមផែនការឆ្នាំដែលបានគ្រោងទុកជាបន្តបន្ទាប់។ ជាក់ស្តែងក្នុងឆ្នាំ២០១៨នេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានរៀបចំធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាល ជាពិសេសគឺ កម្មវិធីបណ្តុះបណ្តាលរបស់មន្ត្រីអធិការកិច្ចដោយអនុវត្តទៅតាមផែនការបណ្តុះបណ្តាល រយៈពេលខ្លី ដែលផ្តោតជាសំខាន់ទៅលើ ០៣ មុខជំនាញគឺ៖ ១) ការត្រួតពិនិត្យសុវត្ថិភាព (Safety Oversights Trainings) ២)ការត្រួតពិនិត្យសន្តិសុខអាកាសចរណ៍ (Aviation Security Oversights) និង៣) ជំនាញគ្រប់គ្រង និងទូទៅ (Generic Trainings) ដល់មន្ត្រីត្រួតពិនិត្យសុវត្ថិភាព និងសន្តិសុខ និងមន្ត្រីរៀបចំបទបញ្ញត្តិ ព្រមទាំងមន្ត្រីផ្តល់សេវាសាធារណៈសម្រាប់អាកាសចរស៊ីវិលផងដែរ។

ការបណ្តុះបណ្តាលទាំងនេះ ត្រូវបានបែងចែកតាមលក្ខណៈបច្ចេកទេសជា៣កម្រិតគឺ៖ វគ្គជំនាញបឋម (សម្រាប់មន្ត្រីចូលថ្មីនិងមន្ត្រីផ្លាស់ប្តូរជំនាញ) វគ្គរក្សានិរន្តរភាពជំនាញ(ជាធម្មតារយៈពេលពីរឆ្នាំម្តង) សម្រាប់មន្ត្រីជាអធិការសុវត្ថិភាព និងសន្តិសុខ និងវគ្គបង្កើនសមត្ថភាពជំនាញ (បង្កើនចំណេះដឹងទៅតាមការវិវឌ្ឍន៍ នៃបច្ចេកវិទ្យា)។

ជាលទ្ធផល សម្រាប់ឆ្នាំ២០១៨ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានបណ្តុះបណ្តាលមន្ត្រី ចំនួន ៣៥៦នាក់ ក្នុងនោះ ៖

- **ការបណ្តុះបណ្តាលក្នុងប្រទេស**
  - រយៈពេលវែង

    រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានសហការជាមួយក្រសួងមុខងារសាធារណៈដោយបានបញ្ជូនមន្ត្រីរាជការចំនួន៤នាក់ ចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំ លើជំនាញគ្រប់គ្រងរដ្ឋបាលនៅសាលាភូមិន្ទរដ្ឋបាល។
  - រយៈពេលមធ្យម

    ក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានបញ្ជូនមន្ត្រីរាជការចំនួន១២នាក់ ទៅចូលរួមវគ្គបណ្តុះបណ្តាលនៅវិទ្យស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើមុខជំនាញដូចខាងក្រោម៖
    - បច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុ ចំនួន៤នាក់
    - លទ្ធកម្មសាធារណៈ ចំនួន២នាក់
    - រដ្ឋទេយ្យបុរេប្រទាន ចំនួន៤នាក់
    - រដ្ឋទេយ្យចំណូល ចំនួន៤នាក់។
  - រយៈពេលខ្លី

    រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានបញ្ជូនមន្ត្រីទៅទទួលការបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាលចំនួន៩នាក់ ក្នុងស្ត្រីមានចំនួន៤នាក់។ បានបញ្ជូនមន្ត្រីទៅបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលបណ្តុះ

បណ្តាលកម្ពុជា-សឹង្ហបុរីចំនួន២វគ្គ មានសិក្ខាកាមចំនួន២៨នាក់ និងបានបញ្ជូនមន្ត្រីរាជការទៅចូលរួមវគ្គបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិលបានចំនួន១៦វគ្គ មានសិក្ខាកាមសរុបចំនួន២៥២នាក់។

**- ការបណ្តុះបណ្តាលក្រៅប្រទេស**

- រយៈពេលវែង

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានបញ្ជូនមន្ត្រីរាជការចំនួន២នាក់ទៅវគ្គបណ្តុះបណ្តាលរយៈពេល២ឆ្នាំ លើជំនាញបញ្ជាចរាចរផ្លូវអាកាស (Air Traffic Controller) នៅប្រទេសកាតា ដែលជាអាហារូបករណ៍របស់ Qatar-ICAO 2018/2019និងតាមរយៈអង្គការ JICA ចំនួន១នាក់។ ជាមួយគ្នានេះដែរ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក៏បានបញ្ជូនថ្នាក់ដឹកនាំចំនួន២នាក់ ទៅទទួលការបណ្តុះបណ្តាលរយៈពេលវែង១៨ខែ កម្រិត Advance Master of Air Transport នៅទីក្រុងហុងកុង។

- រយៈពេលខ្លី

ដោយសារពុំមានវគ្គបណ្តុះបណ្តាលជំនាញនៅក្នុងប្រទេស រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានបញ្ជូនមន្ត្រីរាជការបច្ចេកទេសទៅចូលរួមវគ្គបណ្តុះបណ្តាលជំនាញនៅក្រៅប្រទេសបានចំនួន៣៣វគ្គ មានសិក្ខាកាមចូលរួមចំនួន៤៦នាក់។ ក្នុងនោះ វគ្គបឋមមានសិក្ខាកាមចំនួន១នាក់ វគ្គរក្សានិរន្តភាពជំនាញចំនួន៦វគ្គ មានសិក្ខាកាមចំនួន១០នាក់ វគ្គបង្កើនសមត្ថភាពជំនាញចំនួន១៨វគ្គ មានសិក្ខាកាមចំនួន៣៩នាក់ និងវគ្គគ្រប់គ្រងចំនួន៤វគ្គ មានសិក្ខាកាមចំនួន៦នាក់។

លទ្ធផលដែលទទួលបានពីការបណ្តុះបណ្តាលឆ្នាំ២០១៨ មានដូចខាងក្រោម៖

| ការបែងចែកវគ្គបណ្តុះបណ្តាល Type Course | ប្រភេទបណ្តុះបណ្តាល Type of Training | ចំនួនវគ្គ No. of Course | ចំនួនសិក្ខាកាម No. of Trainee |
|---|---|---|---|
| បណ្តុះបណ្តាលក្នុងស្រុក ចំនួន២៤ វគ្គ សិក្ខាកាមចំនួន៣០៧នាក់ | បណ្តុះបណ្តាលជំនាញបឋម Initial Skill Training | ០៧ | ១១៦ |
| | បណ្តុះបណ្តាលរក្សាជំនាញ Recurrent Skill Training | ០៣ | ២៩ |
| | បណ្តុះបណ្តាលបង្កើនជំនាញ Upgrading Skill Training | ១០ | ១៣៨ |
| | បណ្តុះបណ្តាលជំនាញគ្រប់គ្រង និង ទូទៅ Generic Training | ០៣ | ១៩ |
| | ហាត់ការ Generic Training | ០១ | ០១ |
| | **សរុប** | **២៤** | **៣០៧** |
| បណ្តុះបណ្តាលក្រៅប្រទេស ចំនួន ៣៥ វគ្គ សិក្ខាកាមចំនួន ៤៩ នាក់ | បណ្តុះបណ្តាលជំនាញបឋម Initial Skill Training | ០១ | ០២ |
| | បណ្តុះបណ្តាលរក្សាជំនាញ Recurrent Skill Training | ០០ | ០០ |
| | បណ្តុះបណ្តាលបង្កើនជំនាញ Upgrading Skill Training | ២៣ | ៣០ |

| | | | |
|---|---|---|---|
| | បណ្តុះបណ្តាលជំនាញគ្រប់គ្រង និងទូទៅGeneric Training | ១០ | ១៥ |
| | ហាត់ការ Generic Training | ០១ | ០២ |
| | សរុប | **៣៥** | **៤៩** |
| សរុបរួម = **៥៩ វគ្គ = ៣៥៦ នាក់** | | | |

តាមរយៈលទ្ធផលនៃការការបណ្តុះបណ្តាលឆ្នាំ២០១៨ លើជំនាញទាំង៣ ប្រភេទខាងលើនេះ គឺអាចវាយតម្លៃបានថា៖ ធនធានមនុស្សលើជំនាញអាកាសចរស៊ីវិល ពិតជាមានសមត្ថភាព សម្រាប់ទទួលខុសត្រូវលើការងារត្រួតពិនិត្យ និងការរៀបចំបទបញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាព និងសន្តិសុខអាកាសចរស៊ីវិលបានមួយចំនួន ព្រមទាំងផ្តល់សេវាកម្មលើវិស័យអាកាសចរស៊ីវិល។

**១.៣.២ ផែនការបណ្តុះបណ្តាលធនធានមនុស្សរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលសម្រាប់ឆ្នាំ២០២០**

ដើម្បីធានាបាននូវនិរន្តរភាពការងារត្រួតពិនិត្យ និងចងក្រងបទប្បញ្ញត្តិសុវត្ថិភាព និងសន្តិសុខអាកាសចរស៊ីវិលឱ្យឆ្លើយតបទៅនឹងឧបសម្ព័ន្ធទាំង១៩ របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ និងធានាបាននូវនិរន្តរភាពការងារត្រួតពិនិត្យសុវត្ថិភាព និងសន្តិសុខអាកាសចរស៊ីវិល ព្រមទាំងពង្រឹងគុណភាពការងារផ្តល់សេវាកម្មអាកាសចរស៊ីវិលជូនដល់ប្រតិបត្តិករអាកាសចរណ៍ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលត្រូវការបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស ដូចមានក្នុងផែនការបណ្តុះបណ្តាលរយៈពេលខ្លី ឆ្នាំ ២០២០ មានខាងក្រោមនេះ៖

## ក. ការបណ្តុះបណ្តាលក្នុងប្រទេស

| **ចំណាត់ប្រភេទជំនាញ** | **ប្រភេទវគ្គ** | **ចំនួនវគ្គ** | **ចំនួនសិក្ខាកាម** |
|---|---|---|---|
| ជំនាញត្រួតពិនិត្យសុវត្ថិភាព SAFETY OVERSIGHTS | ជំនាញមូលដ្ឋាន Basic Skill | ០១ | ០៨ |
| | រក្សាជំនាញ/បណ្តុះបណ្តាលនៅនឹងកន្លែង Recurrent Skill /&OJT | ០១ | ០៦ |
| | បង្កើនជំនាញ Upgrading Skill | ០៥ | ៦៦ |
| ជំនាញត្រួតពិនិត្យសន្តិសុខ SECURITY OVERSIGHTS | ជំនាញមូលដ្ឋាន Basic Skill | ០១ | ១៥ |
| | រក្សាជំនាញ/បណ្តុះបណ្តាលនៅនឹងកន្លែង Recurrent Skill /&OJT | ០១ | ០៥ |
| | បង្កើនជំនាញ Upgrading Skill | ០៣ | ០៦ |
| វគ្គបណ្តុះបណ្តាលទូទៅ GENERIC TRAININGS | ជំនាញគ្រប់គ្រង Management Skill | ០២ | ០៤ |
| | ជំនាញអភិវឌ្ឍសមត្ថភាព | ០៥ | ៨០ |

| | Capacity Development | | |
|---|---|---|---|
| សរុប = | | ១៩ | ១៩០ |

## ខ. ការបណ្តុះបណ្តាលក្រៅប្រទេស

| ចំណាត់ប្រភេទជំនាញ | ប្រភេទវគ្គ | ចំនួនវគ្គ | ចំនួនសិក្ខាកាម |
|---|---|---|---|
| ជំនាញត្រួតពិនិត្យសុវត្ថិភាព SAFETY OVERSIGHTS | ជំនាញមូលដ្ឋាន Basic Skill | ០៨ | ១២ |
| | វគ្គរំលឹកជំនាញ Recurrent Skill | ០៦ | ១៧ |
| | បង្កើនជំនាញ Upgrading Skill | ៤៦ | ៨៦ |
| ជំនាញត្រួតពិនិត្យសន្តិសុខ SECURITY OVERSIGHTS | ជំនាញមូលដ្ឋាន Basic Skill | ០៥ | ០៧ |
| | វគ្គរំលឹកជំនាញ Recurrent Skill | ០១ | ០៣ |
| | បង្កើនជំនាញ Upgrading Skill | ០៥ | ០៨ |
| វគ្គបណ្តុះបណ្តាលទូទៅ GENERIC TRAININGS | ជំនាញគ្រប់គ្រង Management Skill | ០៩ | ១៨ |
| | ជំនាញអភិវឌ្ឍសមត្ថភាព Capacity Development Skill | ១៨ | ៣៥ |
| សរុប = | | *៩៨* | *១៨៦* |
| **សរុបរួម = ១១៧វគ្គ = ៣៧៦នាក់** | | | |

## ៣. ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

### ៣.១ ការគ្រប់គ្រងចំណាយឆ្នាំ២០១៨

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានរៀបចំក្របខ័ណ្ឌចំណាយដោយផ្អែកលើលទ្ធភាពថវិកាតាមរយៈការធ្វើអាទិភាវូនីយកម្មចំណាយឱ្យស្របតាមផែនការសកម្មភាព។ ទន្ទឹមនឹងការធានាបានប្រសិទ្ធភាពទាំងក្នុងកម្រិតវិភាជន៍ និងទាំងក្នុងកម្រិតប្រតិបត្តិការ និងបច្ចេកទេសដែលធានាបានជាសារវន្តទាំងចំណាយបន្ទុកបុគ្គលិក និងចំណាយក្រៅបន្ទុកបុគ្គលិក រួមទាំងចំណាយវិនិយោគចាំបាច់ជាអាទិភាពនានា។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានបង្កើនការយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យ តាមដានការអនុវត្តថវិកា និងសកម្មភាពការងាររបស់ខ្លួនជាប្រចាំប្រកបដោយភាពទន់ភ្លន់ទៅតាមសភាពការណ៍ហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ដោយអនុលោមតាមគោលការណ៍ណែនាំនៃសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ ជាពិសេសគឺក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងត្រៀមវិធានការដោះស្រាយប្រកបដោយប្រសិទ្ធភាព ដោយជៀសវាងផលប៉ះពាល់ដល់សកម្មភាពអាទិភាពខ្ពស់ក្នុងករណីមានការតម្រឹមថវិកាជាយថាហេតុ។

ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវច្បាស់លាស់ ទាំងលើការអនុវត្តចំណាយ ទាំងលើសមិទ្ធកម្មការងារ ថវិកាមួយផ្នែកធំត្រូវបានផ្ទេរឱ្យទៅអង្គភាពថវិកា ដើម្បីបង្កើនប្រសិទ្ធភាពលើការគ្រប់គ្រងចំណាយ និងធានាបាននូវនិរន្តរភាពការងារប្រចាំថ្ងៃ ជាពិសេសការអនុវត្តចំណាយឱ្យចំទិសដៅអាទិភាពពិតប្រាកដ មានភាពសន្សំសំចៃខ្ពស់ និងស្ថិតក្នុងរង្វង់នៃលទ្ធភាពដែលមាន។ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល នឹងរិះរកវិធានការ ដើម្បីជម្រុញអង្គភាពថវិកាទាំង២ អនុវត្តនូវសកម្មភាពអាទិភាពមួយចំនួនសម្រាប់គាំទ្រដល់គោលនយោបាយដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។

ជាលទ្ធផលផ្អែកតាមច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ សម្រាប់ចំណាយចរន្ត មានដូចខាងក្រោមៈ

***តារាងចំណាយតាមជំពូកសម្រាប់ឆ្នាំ២០១៨***

គិតជាប្រាក់រៀល

| មាតិកាថវិកា និងអត្ថន័យ | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | ឥណទាននៅសល់ | អនុវត្តធៀបនឹងច្បាប់ (%) |
|---|---|---|---|---|
| ជំពូក៦០៖ ការទិញ | ៤ ៨២៤ ០០០ ០០០ | ៤ ៧៩៧ ៨១៧ ៣៣០ | ៦៦ ២៤៦ ៦៧០ | ៩៨,៦៤% |
| ជំពូក៦១៖ សេវាខាងក្រៅ | ១១ ៨៧២ ៤៣៦ ០០០ | ១១ ៦៦១ ០៤៩ ០២៧ | ២១១ ៣៨៦ ៩៧៣ | ៩៨,២២% |
| ជំពូក៦៤៖ បន្ទុកបុគ្គលិក | ៣៣ ១៩៩ ៦០៦ ០០០ | ៣១ ៧៧៩ ១៣៨ ៧៨៩ | ១ ៤២០ ៤៦៧ ២១១ | ៩៥,៧២% |
| ជំពូកទី៦២៖ អត្ថប្រយោជន៍សង្គម | ១០ ០១០ ០០០ ០០០ | ៩ ៧៨២ ៩៤៦ ៤០០ | ២៣៧ ០៥៣ ៦០០ | ៩៧,៦៣% |
| ជំពូក៦៥៖ ឧបត្ថម្ភធន | ៥៥១ ០០០ ០០០ | ៣០៥ ២៣១ ៣៩៦ | ២៤៥ ៧៦៨ ៦០៤ | ៥៥,៤០% |
| ជំពូកទី៦៣៖ ពន្ធ និងអាករ | ១៤ ០០០ ០០០ | ០ | ១៤ ០០០ ០០០ | ០% |
| **សរុប** | **៦០ ៥២១ ១០៦ ០០០** | **៥៨ ៣២៦ ១៨២ ៩៤២** | **២ ១៩៤ ៩២៣ ០៥៨** | **៩៦,៣៧%** |

## ៣.២ ការគ្រប់គ្រងចំណូលឆ្នាំ២០១៨

ដើម្បីចូលរួមចំណែកសម្រេចឱ្យបាននូវគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ របស់រាជរដ្ឋាភិបាលទទួលបានជោគជ័យ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានផ្តោតលើការពង្រឹងយុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលមានស្រាប់តាមរយៈការអនុវត្តវិធានការម៉ឺងម៉ាត់ និងមុតស្រួច ជាពិសេសការលើកកម្ពស់ប្រសិទ្ធភាពប្រមូលចំណូល និងពង្រឹងយន្តការក្នុងការតាមដាន កត់ត្រា ការគៀរគរចំណូល និងវិធានការតឹងទារបំណុលជាមួយប្រតិបត្តិករអាកាសចរណ៍ រួមទាំងពង្រឹងការធ្វើបច្ចុប្បន្នភាពថ្លៃឈ្នួលទ្រព្យសម្បត្តិរដ្ឋ និងកម្រៃសេវាសាធារណៈរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានខិតខំប្រឹងប្រែងប្រមូលចំណូលតាមយន្តការដែលមានស្រាប់តាមរយៈការអនុវត្តឱ្យមានប្រសិទ្ធភាពនូវយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ឆ្នាំ២០១៩-២០២៣ ហើយបានបង់ចំណូលចូលថវិកា។ ជាលទ្ធផល ការអនុវត្តចំណូលចរន្តធៀបទៅនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ មានដូចខាង ក្រោមៈ

*តារាងចំណូលថវិការដ្ឋប្រចាំឆ្នាំ២០១៨*

គិតជាប្រាក់រៀល

| មាតិកាថវិកា និងអត្ថន័យ | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | % អនុវត្តធៀបនឹងច្បាប់ |
|---|---|---|---|
| ៧៣០១៥- ការលក់មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រចាស់ៗ ឬខូច | | ៤ ៤០០ ០០០ | |
| ៧៣០១៦- ការលក់ឧបករណ៍អេឡិចត្រូនិចចាស់ៗ ឬខូច | | ២ ៧០០ ០០០ | |
| ៧២០០៥- ការជួលដីទំនេរ | ៧០ ៩០០ ០០០ | ៧៥ ៧២៧ ៣០០ | ១០៦,៨១% |
| ៧៣០០១- ផលទុនអាកាសចរស៊ីវិល | ១៣៤ ៤៤០ ០០០ ០០០ | ១៥៣ ៣៤០ ២៨៤ ៣៥៨ | ១១៤,០៦% |
| ៧៣០៣៤- ការជួលដីមានអគារ | ១០០ ១០០ ០០០ | ៩៩ ៩៩៦ ៩៦៦ | ៩៩,៩០% |
| ៧៧០២១- លក់ឆ្នោតកោះពស់ | | ២០ ០៥០ ០០០ ០០០ | |
| **សរុប** | **១២០ ២៨១ ០០០ ០០០** | **១៧៣ ៥៧៣ ១០៨ ៦២៤** | **១២៨,៩៤%** |

## ៤. ការងារផែនការ យុទ្ធសាស្ត្រ និងគោលនយោបាយ

ជាការឆ្លើយតបទៅនឹងតម្រូវការរបស់ក្រសួងផែនការ ក្នុងការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានចូលរួមផ្តល់ធាតុចូលសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលពាក់ព័ន្ធនឹងវិស័យអាកាសចរស៊ីវិលសំដៅដល់ការចូលរួមចំណែកក្នុងការអនុវត្តនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា។ គោលដៅជាយុទ្ធសាស្ត្រ និងគោលនយោបាយអាទិភាពលើវិស័យអាកាសចរស៊ីវិល នឹងរួមចំណែកក្នុងកិច្ចការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ដោយធ្វើឱ្យសម្រេចបាននូវការគ្រប់គ្រងអាកាសចរស៊ីវិលនៅកម្ពុជាទទួលបានសុវត្ថិភាព សន្តិសុខ បរិស្ថាន និងប្រសិទ្ធភាពជានិរន្តន៍សម្រាប់ការធ្វើដំណើរ និងការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសក្នុងកម្រិតបទដ្ឋានអន្តរជាតិ។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានដាក់ចេញគោលដៅជាយុទ្ធសាស្ត្រចំនួន៦ រួមមាន៖ ១) ការពង្រឹងសុវត្ថិភាពហោះហើរ ២) ការពង្រឹងសន្តិសុខអាកាសចរស៊ីវិល ៣) ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការតភ្ជាប់ការហោះហើរ ៤) ការពង្រឹងសេវាកម្មនាំផ្លូវអាកាស ៥) ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិ និងអន្តរជាតិ និង៦) ការអភិវឌ្ឍន៍ធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន។

ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការសម្របសម្រួលយន្តការ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាមួយនឹងការគ្រប់គ្រងគម្រោងការនានា និងគោលនយោបាយរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីធានាបាននូវនិរន្តរភាពនៃដំណើរការប្រព្រឹត្តទៅរបស់ រ.ល.អ.ស ក្នុងការធ្វើឱ្យសម្រេចបានគោលបំណងគោលនយោបាយ។ ដើម្បីធ្វើជាមូលដ្ឋាននៃការតម្រង់ទិសសម្រាប់ការអភិវឌ្ឍវិស័យអាកាសចរស៊ីវិលកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បាននឹងកំពុងរៀបចំផែនការសកម្មភាពនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍អាកាសចរស៊ីវិល ឆ្នាំ២០១៩-២០២៣ ដើម្បីចូលរួមផ្តល់ធាតុចូលដល់ក្រសួងផែនការក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ (NSDP) ដែលជាផែនការដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលអាណត្តិទី៦ ដែលនឹងបង្ហាញ

លម្អិតនូវសកម្មភាព កម្មវិធី និងគម្រោងការសំខាន់ៗសំដៅធ្វើឱ្យបានសម្រេចនូវបណ្ដាគោលដៅអាទិភាពរបស់ជាតិដូចមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការអភិវឌ្ឍសហវត្ស (PCSDG)។

ជាមួយគ្នានេះដែរ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលក៍បានរៀបចំចងក្រង និងបោះពុម្ពសៀវភៅស្ថិតិអាកាសចរណ៍លើកទី៣ (Civil Aviation Data Book) និងផែនការវិនិយោគសាធារណៈ (PIP) ២០១៨-២០២០ ដែលជាផែនការសម្រាប់វិនិយោគរយៈពេលមធ្យម៣ឆ្នាំ រំកិលសម្រាប់កំណត់ពីកម្មវិធីវិនិយោគសាធារណៈរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានសហការជាមួយតួអង្គពាក់ព័ន្ធមួយចំនួន ដើម្បីធ្វើការសិក្សាស្រាវជ្រាវលើផ្នែកសេដ្ឋកិច្ច និងសង្គមពីវិស័យអាកាសចរស៊ីវិលលើផ្នែកការអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិទាំង៣ ហើយបានរកឃើញថា៖ ទិន្នផលសរុបនៃសកម្មភាពអាកាសយានដ្ឋានអន្តរជាតិទាំង៣ របស់កម្ពុជា មានចំនួន២,៧០ពាន់លានដុល្លារ ឬប្រហែល១៧ភាគរយ នៃផលិតផលដុលក្នុងស្រុកសរុប (GDP) របស់ប្រទេស។ ជាមួយគ្នានេះ ក៏បានរកឃើញថា សកម្មភាពទាំងនោះបានផ្ដល់ការងារដោយផ្ទាល់ និងប្រយោល ដល់ប្រជាជនប្រមាណ១,៧០លាននាក់ ស្មើនឹង២០ ភាគរយនៃចំនួនប្រជាជនធ្វើការនៅកម្ពុជា។ នៅថ្ងៃអនាគតវាមានសារៈសំខាន់ណាស់ក្នុងការរក្សាបាននូវសាមគ្គីភាពនៃបណ្ដាញអាកាសយានដ្ឋាននៅកម្ពុជា ដើម្បីបង្កើនប្រសិទ្ធភាពនៃវិស័យអាកាសចរស៊ីវិល និងពង្រីកអត្ថប្រយោជន៍ជាអតិបរិមាដល់សេដ្ឋកិច្ច និងសង្គមកម្ពុជា។

ក្រៅពីនេះរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល នឹងរៀបចំកសាងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពការងាររបស់បណ្ដានាយកដ្ឋាន និងអង្គភាពក្រោមចំណុះអង្គភាពថវិកាទាំង២ ដើម្បីធានាថាការអនុវត្តថវិកាប្រចាំឆ្នាំប្រកបដោយសក្ដិសិទ្ធភាព និងប្រសិទ្ធភាពខ្ពស់។

សម្រាប់ឆ្នាំ២០២០ខាងមុខនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល នឹងសិក្សារៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអាកាសចរស៊ីវិលឆ្នាំ២០១៩-២០២៣ និងរៀបចំចងក្រង និងធ្វើបច្ចុប្បន្នភាពសៀវភៅស្ថិតិអាកាសចរស៊ីវិលកម្ពុជាលើកទី៥ ដើម្បីបោះពុម្ព និងផ្សព្វផ្សាយ ព្រមទាំងរៀបចំធាតុចូលផែនការយុទ្ធសាស្ត្រអភិវឌ្ឍឧស្សាហកម្មកម្ពុជាលើវិស័យអាកាសចរស៊ីវិល និងបន្តសម្របសម្រួលគម្រោងសហប្រតិបត្តិការគ្រប់រូបភាពជាមួយដៃគូអភិវឌ្ឍន៍ ដូចជា៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) កិច្ចសហប្រតិបត្តិការមេគង្គឡានឆាង (Mekong Lan Chang) គម្រោង ARISE Plus Civil Aviation និងគម្រោង EU SEA APP។

ជាមួយគ្នានេះដែរ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការការងារយេនឌ័រ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានចងក្រងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអាកាសចរស៊ីវិលសម្រាប់ឆ្នាំ២០១៧-២០២១ ដើម្បីឆ្លើយតបទៅនឹងការអនុវត្តអនុសញ្ញា ស្ដីពីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងនារីភេទ ស៊ីដ (CEDAW) នៅកម្ពុជា ដែលសំដៅលើការលើកកម្ពស់ជីវភាព ស្ថានភាព ឋានៈ និងតួនាទីរបស់ស្ត្រី តាមរយៈការអនុវត្តអនុសញ្ញាស៊ីដ (CEDAW) និងច្បាប់ជាតិពាក់ព័ន្ធនានា សំដៅចូលរួមធ្វើឱ្យសម្រេចបានក្នុងការប្តេជ្ញាចិត្ត និងការអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ទាំង១១ចំណុច របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (នារីរតនៈ)។ ដើម្បីអនុវត្តស្របតាមផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រឆ្នាំ២០១៧-២០២១

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានរៀបចំសិក្ខាសាលា និងបើកវគ្គបណ្តុះបណ្តាលការងារយេនឌ័រ វិស័យអាកាសចរស៊ីវិល ដោយបានសហការជាមួយក្រសួងកិច្ចការនារី និងក្រុមប្រឹក្សា ជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីផ្សព្វផ្សាយដល់ថ្នាក់ដឹកនាំ ក៏ដូចជាស្ត្រីនៅក្នុងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលទាំងមូល។

## ៥. វឌ្ឍនភាពសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស

ដោយសារស្ថិរភាពនយោបាយ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានភាពល្អប្រសើរ រួមទាំងគោលនយោបាយសេដ្ឋកិច្ចបើកចំហរ ជាពិសេសគោលនយោបាយបើកចំហរជើងមេឃរបស់រដ្ឋាភិបាលធ្វើឱ្យវិស័យដឹកជញ្ជូនតាមផ្លូវអាកាសមានការកើនឡើងគួរឱ្យកត់សំគាល់។ ជាក់ស្តែងក្នុងឆ្នាំ២០១៨ នេះ អាកាសយានដ្ឋានអន្តរជាតិទាំង ៣ ទទួលបានអ្នកដំណើរសរុបប្រមាណ១០លាននាក់ ដោយកើនឡើង២៥ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ស្របពេលជាមួយគ្នានេះដែរ ការដឹកជញ្ជូនទំនិញបានកើនឡើង១៣ភាគរយ ហើយទទួលបានកំណត់ត្រាថ្មីគឺ ៧៣ ៥៩០ តោន។ ការកើនឡើងនេះមិនមែនកើតឡើងដោយចៃដន្យនោះទេ ប៉ុន្តែវាជាលទ្ធផលនៃយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍ការតភ្ជាប់ផ្លូវអាកាស និងយុទ្ធសាស្ត្រផ្តល់ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងកំណើនដែលទទួលបានភាពជោគជ័យដ៏អស្ចារ្យ។ កត្តាដែលជោគជ័យមួយទៀតគឺអ្វីៗដែលរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានសហការរៀបចំផែនការអភិវឌ្ឍជាមួយក្រុមហ៊ុនអាកាសយានដ្ឋានកម្ពុជា និងក្រសួងទេសចរណ៍ និងភាគីពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យទេសចរណ៍ គឺលេចចេញជារូបរាងទាំងអស់ដោយគ្មានការអាក់ខាន។ កិច្ចខិតខំប្រឹងប្រែងដើម្បីជម្រុញប្រទេសកម្ពុជាក្នុងនាមជាទិសដៅទេសចរណ៍ដ៏សំខាន់មួយ ដោយបានផ្តល់នូវកំណើនក្នុងវិស័យទេសចរណ៍ថេរចំនួន២ខ្ទង់ ក្នុងអំឡុងពេល១០ឆ្នាំ ចុងក្រោយនេះ។ វាក៏ជាលទ្ធផលនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់យើងដែលមានគោលបំណងដើម្បីស្វាគមន៍ក្រុមហ៊ុនអាកាសចរណ៍ច្រើនថែមទៀត បើកផ្លូវអាកាសថ្មី និងបង្កើនប្រេកង់ (ហោះហើរ)។

### ៥.១- កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី

ដើម្បីជម្រុញកំណើនក្រុមហ៊ុនអាកាសចរណ៍ ជើងហោះហើរ អ្នកដំណើរតាមផ្លូវអាកាស និងការការហោះហើរឆ្លងដែនអាកាសកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានកំណត់គោលដៅដ៏ច្បាស់លាស់មួយលើការពង្រីក និងពង្រឹងកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាមួយបណ្តាប្រទេសសំខាន់ៗ តាមរយៈការចរចាជាលក្ខណៈទ្វេភាគី និងពហុភាគីជាមួយបណ្តាប្រទេសជាមួយបណ្តាប្រទេសក្នុងតំបន់ និងក្រៅតំបន់អាស៊ាន។ រាល់ការចរចាកិច្ចព្រមព្រៀងទាំងអស់ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានកំណត់យុទ្ធសាស្ត្រ និងយុទ្ធវិធីច្បាស់លាស់លើបណ្តាសមាសធាតុសេដ្ឋកិច្ចសំខាន់ៗ ដូចជា៖ ការចាត់តាំងក្រុមហ៊ុនអាកាសចរណ៍ ការកំណត់ចំណុះដឹកជញ្ជូន ការកំណត់ផ្លូវហោះហើរ ការកំណត់បើកចំហរជើងហោះហើរសហការ (Code-Share Flights) ការប្រកួតប្រជែងដោយស្មើភាព និងការកំណត់សំណាញ់សុវត្ថិភាពនៃប្រតិបត្តិការហោះហើរជាដើម។ កមដល់ឆ្នាំ២០១៨នេះ កិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវបានកែសម្រួលឯកភាពលើខ្លឹមសារ និងចុះហត្ថលេខាជាច្រើន ដូចមានមានសេចក្តីលម្អិតសង្ខេបខាងក្រោម៖

#### ៥.១.១ កិច្ចព្រមព្រៀងទ្វេភាគី

មកដល់បច្ចុប្បន្ននេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ចុះហត្ថលេខាអនុស្សារណៈយោគយល់ និងឯកភាពជាគោលការណ៍ខ្លឹមសារនៃកិច្ចព្រមព្រៀង បានចំនួន៤៦ប្រទេស ដែលរួមមាន៖

- កិច្ចព្រមព្រៀងបានចុះហត្ថលេខាបានចុះហត្ថលេខាសំគាល់ចំនួន១៨ប្រទេស
- អនុស្សារណៈយោគយល់បានចុះហត្ថលេខាចំនួន៥៤ប្រទេស
- កិច្ចព្រមព្រៀងបានចុះហត្ថលេខាចំនួន២៧ប្រទេស។

**៥.១.២ កិច្ចព្រមព្រៀងពហុភាគីអាស៊ាន**

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានភារកិច្ចក្នុងការចរចាកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការងារដឹកជញ្ជូនតាមផ្លូវអាកាស និងការងារបច្ចេកទេសពាក់ព័ន្ធវិស័យអាកាសចរស៊ីវិលបាននាំមកនូវដំណើរការរីកចម្រើនជាលំដាប់ដោយមានរួមទាំងកិច្ចព្រមព្រៀងបានទទួលសច្ចាប័នរួចពីរដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀងចុះហត្ថលេខារួចហើយតែរង់ចាំការផ្តល់សច្ចាប័នពីរដ្ឋសភាជាតិ និងកិច្ចព្រមព្រៀងកំពុងដំណើរការចរចា។

- កិច្ចព្រមព្រៀងពហុភាគីអាស៊ាន និងដៃគូសន្ទនាអាស៊ានចំនួន៤ បានស្នើសុំរដ្ឋសភាជាតិផ្តល់សច្ចាប័នរួច តាមរយៈរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦។
- កិច្ចព្រមព្រៀងពហុភាគីអាស៊ាន និងពិធីសារចំនួន៥ បានចុះហត្ថលេខាកាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ តាមរយៈសិទ្ធិប្រទានពីរាជរដ្ឋាភិបាលកម្ពុជា ហើយគ្រោងនឹងស្នើសុំរដ្ឋសភាជាតិផ្តល់សច្ចាប័ននៅក្នុងឆ្នាំ២០១៩នេះ។
- កិច្ចព្រមព្រៀងពហុភាគីអាស៊ានយ៉ាងតិចចំនួន៣ និងកិច្ចព្រមព្រៀងរវាងអាស៊ាន និងដៃគូអាស៊ានយ៉ាងតិចចំនួន៤ នឹងត្រូវចុះហត្ថលេខានៅក្នុងរង្វង់២ឆ្នាំខាងមុខ។

**៥.២ ដំណើរការគាំទ្រឧស្សាហកម្មដឹកជញ្ជូនតាមផ្លូវអាកាស**

ក្រៅពីដំណើរការហោះហើរ ការអនុញ្ញាតការហោះហើរ ចរចាកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាលក្ខណៈទ្វេភាគី និងពហុភាគីអាស៊ាន រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានដើរតួនាទីសម្របសម្រួល និងគាំទ្រសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- **ការងារធានារ៉ាប់រងវិស័យអាកាសចរស៊ីវិល៖** រាល់អ្នកដំណើរតាមផ្លូវអាកាសទាំងអស់ រួមទាំងទំនិញ និងឥវ៉ាន់ ត្រូវបានធានាថាមានធានារ៉ាប់រងត្រឹមត្រូវតាមរយៈក្រុមហ៊ុនអាកាសចរណ៍ជាតិ និងអន្តរជាតិ អាកាសយានដ្ឋាន និងចរាចរនាំផ្លូវអាកាស។ ប័ណ្ណធានារ៉ាប់រងរបស់ក្រុមហ៊ុនផ្តល់សេវាដឹកជញ្ជូនទាំងនេះត្រូវត្រួតពិនិត្យសុពលភាពជាប្រចាំ។
- **ការងារបោះពុម្ពផ្សាយស្ថិតិដឹកជញ្ជូនតាមផ្លូវអាកាស៖** ព្រឹត្តិប័ត្រស្ថិតិប្រចាំឆ្នាំ ឆមាស ត្រីមាស និងប្រចាំខែ ត្រូវបានបោះពុម្ពផ្សាយជាប្រចាំជូនក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ។
- **ការងារដោះស្រាយបណ្តឹង និងវិវាទ៖** បណ្តឹងរបស់ធ្វើដំណើរតាមផ្លូវអាកាស ជាមួយក្រុមហ៊ុនអាកាសចរ ក្រុមហ៊ុនអាកាសចរណ៍ជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន និងក្រុមហ៊ុនចរាចរដែនអាកាស ត្រូវបានដោះស្រាយជាបន្តបន្ទាប់ ដោយឈរលើមូដ្ឋានសាមគ្គីភាព បង្រួមបញ្ហា និងសុខដុមនីយកម្ម។
- **ទ្រទ្រង់វិស័យឯកជន៖** ផ្សព្វផ្សាយលទ្ធផលកិច្ចប្រជុំទ្វេភាគី និងពហុភាគីអាស៊ាន ស្តីពីចំណុចខ្លាំង និងចំណុចខ្សោយនៃការអនុវត្តកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសថ្មីៗ ជាទៀងទាត់ជាមួយវិស័យឯកជន និងបើកកិច្ចប្រជុំពិភាក្សាផ្តល់យោបល់ រវាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាមួយ

វិស័យឯកជន ដើម្បីស្វែងរកលទ្ធភាពជម្រុញ និងគាំទ្រដល់ដំណើរការអាជីវកម្មឱ្យមាននិរន្តរភាព និងតម្លាភាព។

- **ការងារសេវាកម្មទ្រទ្រង់ដឹកជញ្ជូនតាមផ្លូវអាកាស៖** បានរៀបចំសេចក្តីប្រកាសស្តីពីការគ្រប់គ្រងប្រតិបត្តិករផ្តល់សេវាកម្មគាំទ្រដឹកជញ្ជូនតាមផ្លូវអាកាស និងកំពុងដំណើរការតម្រូវឱ្យក្រុមហ៊ុនដែលផ្តល់សេវាកម្មទាំង១៣ប្រភេទ មកធ្វើការចុះបញ្ជីជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

**៥.៣- ចំនួនអ្នកដំណើរតាមផ្លូវអាកាសក្នុងស្រុក និងអន្តរជាតិឆ្នាំ២០១៨**

ដោយអនុវត្តតាមគោលនយោបាយបើកចំហរជើងមេឃ ដែលបានដាក់ចេញដោយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលដើរតួនាទីយ៉ាងសំខាន់ក្នុងការទំនាក់ទំនងជាមួយបណ្តាប្រទេសនានានៅក្នុងតំបន់ និងលើពិភពលោក ដើម្បីបង្ហាញពីសក្តានុពល និងទីផ្សារអាកាសចរណ៍របស់កម្ពុជាក្នុងគោលបំណងទាក់ទាញភ្ញៀវទេសចរណ៍ ក៏ដូចជាវិនិយោគិនមកធ្វើការវិនិយោគ និងទេសចរណ៍នៅប្រទេសកម្ពុជា។

ជាលទ្ធផលទិន្នន័យអ្នកដំណើរអន្តរជាតិចេញ-ចូលសម្រាប់ឆ្នាំ២០១៨មានចំនួន **៩ ៣៧៦ ៣៩៣នាក់** ក្នុងនោះអាកាសយានដ្ឋានអន្តរជាតិភ្នំពេញមចំនួន៥ ០០២ ៥១១នាក់, អាកាសយានដ្ឋានអន្តរជាតិសៀមរាបមានចំនួន ៣ ៨៨៧ ៥១៧នាក់ និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ចំនួន ៤៨៦ ៣៦៥ នាក់។

ចំណែកទិន្នន័យអ្នកដំណើរក្នុងស្រុកសម្រាប់ឆ្នាំ២០១៨ មានចំនួន **៦៣៦ ៧២៥នាក់** ក្នុងនោះអាកាសយានដ្ឋានអន្តរជាតិភ្នំពេញមានចំនួន ២៣៨ ៤២០នាក់, អាកាសយានដ្ឋានអន្តរជាតិសៀមរាបចំនួន ២៩៥ ៣៣០នាក់ និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ចំនួន ១០២ ៩៧៥នាក់។

ជាសរុបអាកាសយានដ្ឋានអន្តរជាតិទាំង៣ ទទួលបានអ្នកដំណើរចេញ-ចូលទាំងអន្តរជាតិ និងក្នុងស្រុកចំនួន **១០ ០១៣ ១១៨នាក់** ក្នុងនោះអ្នកដំណើរអន្តរជាតិចំនួន ៩ ៣៧៦ ៣៩៣នាក់ និងអ្នកដំណើរក្នុងស្រុកចំនួន ៦៣៦ ៧២៥នាក់ ដែលមានកំណើន ២២ភាគរយ ធៀបនឹងឆ្នាំ២០១៧។ តាមការព្យាករណ៍ផ្អែកលើស្ថានភាពនយោបាយ និងសេដ្ឋកិច្ច បានបង្ហាញថា៖ ចាប់ពីឆ្នាំ២០២០-២០២២ ចំនួនអ្នកដំណើរតាមផ្លូវអាកាស (Passenger) នឹងមានកំណើន ៥ ភាគរយ (ក្នុងស្រុក) និង ១២ ភាគរយ (អន្តរជាតិ)។

**អ្នកដំណើរតាមផ្លូវអាកាស**

គិតជា នាក់

| ចំនួនអ្នកដំណើរ | 2017 | 2018 | 2019 | 2020 | 2021 | 2022 |
|---|---|---|---|---|---|---|
| អន្តរជាតិ | 7,665,717 | 9,376,393 | 10,501,560 | 11,761,747 | 13,173,157 | 14,753,936 |
| ក្នុងស្រុក | 571,687 | 636,725 | 668,561 | 701,989 | 737,089 | 773,943 |
| **សរុប** | **8,237,404** | **10,013,118** | **11,170,121** | **12,463,737** | **13,910,246** | **15,527,879** |




### ៥.៣- ចំនួនជើងហោះហើរក្នុងស្រុក និងអន្តរជាតិ ឆ្នាំ២០១៨

ជាលទ្ធផលនៃចំនួនជើងយន្តហោះដែលធ្វើការហោះហើរចេញ-ចូលតាមផ្លូវអាកាសទាំងក្នុងស្រុក និងអន្តរជាតិ (Movement Flight)សម្រាប់ឆ្នាំ២០១៨ មានចំនួន ៩៩ ១៩៧ជើង ដែលក្នុងនោះ ជើងហោះហើរអន្តរជាតិ (International Flight) មានចំនួន ៨២ ៣១៩ជើង និងជើងហោះហើរក្នុងស្រុក (Domestic Flight) មានចំនួន ១៦ ៨៧៨ជើង។ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញមានជើងហោះហើរអន្តរជាតិចំនួន ៤៤ ២៤៥ ជើង និងជើងហោះហើរក្នុងស្រុកចំនួន ៥ ១០៩ជើង, អាកាសយានដ្ឋានអន្តរជាតិសៀមរាបមានជើងហោះហើរអន្តរជាតិ ចំនួន ៣៣ ៨៥៩ជើង និងជើងហោះហើរក្នុងស្រុកចំនួន ៧ ២៧៤ជើង អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ មានជើងហោះហើរអន្តរជាតិចំនួន ៤ ២១៥ជើង និងជើងហោះហើរក្នុងស្រុកចំនួន ៤ ៤៩៥ជើង។

ជារួមចំនួនជើងហោះហើរចេញ-ចូល និងហោះហើរឆ្លងកាត់តាមផ្លូវអាកាសរបស់កម្ពុជា (Movement Flight) សម្រាប់ឆ្នាំ២០១៨ មានចំនួន ១៦៥ ២៨៩ជើង ក្នុងនោះចំនួនជើងហោះហើរអន្តរជាតិ (International Flight) មានចំនួន ៨២ ៣១៩ជើង និងក្នុងស្រុក (Domestic Flight)មានចំនួន ១៦ ៨៧៨ជើង និងចំនួនជើងហោះហើរឆ្លងកាត់ (Over Flight) មានចំនួន ៦៦ ០៩២ជើង កើនឡើងចំនួន ១៣ភាគរយ ធៀបនឹងឆ្នាំ ២០១៧។

ដើម្បីបង្កើនសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបាននឹងកំពុងខិតខំប្រឹងប្រែងចរចារកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនផ្លូវអាកាសជាមួយបណ្តាប្រទេសមួយចំនួនទៀតឱ្យទទួលបានលទ្ធផលល្អ និងតាមការព្យាករណ៍ផ្អែកលើស្ថានភាពនយោបាយ និងសេដ្ឋកិច្ច និងបានបង្ហាញថា៖ ចាប់ពីឆ្នាំ២០២០-២០២២ ចំនួនជើងហោះហើរតាមផ្លូវអាកាសនឹងមានកំណើនចំនួន៥ភាគរយ សម្រាប់ក្នុងស្រុក និង១៥ភាគរយ សម្រាប់អន្តរជាតិ។ ដោយឡែកចំពោះជើងហោះហើរហោះឆ្លងកាត់ (Over flight) គឺមានកំណើនប្រមាណ ១២ភាគរយ ចាប់ពីឆ្នាំ២០២០-២០២២។

**ជើងហោះហើរផ្លូវអាកាស**

គិតជា ជើង

| ចំនួនជើងហោះ | 2017 | 2018 | 2019 | 2020 | 2021 | 2022 |
|---|---|---|---|---|---|---|
| អន្តរជាតិ | 67,910 | 82,319 | 92,197 | 103,261 | 115,652 | 129,531 |
| ក្នុងស្រុក | 16,761 | 16,878 | 17,216 | 17,560 | 17,911 | 18,269 |
| ហោះឆ្លងកាត់ | 58,737 | 66,092 | 74,023.04 | 82,906 | 92,854.50 | 103,997 |
| **សរុប** | **143,408** | **165,289** | **183,436** | **203,727** | **226,418** | **251,797** |




## ៥.៤- ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសក្នុងឆ្នាំ២០១៨

ឆ្នាំ២០១៨ ជាឆ្នាំឯកត្តកម្មមួយទៀតសម្រាប់ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសនៅកម្ពុជា ដោយមានក្រុមហ៊ុនអាកាសចរណ៍ដឹកជញ្ជូនកាន់តែច្រើនធ្វើការឆ្លើយតបទៅនឹងការកើនឡើងការនាំដឹកជញ្ជូនទំនិញតាមផ្លូវអាកាស ជាពិសេសការនាំចេញរបស់ក្រុមហ៊ុនផលិតសំលៀកបំពាក់។ បរិមាណទំនិញតាមជើងយន្តហោះសរុបមានជាង ៧៣ ៥៩១តោន ក្នុងឆ្នាំ២០១៨ ដែលបរិមាណនេះ គឺកើនឡើង ១៥ ភាគរយ បើប្រៀបធៀបនឹងឆ្នាំ២១០៧។ បច្ចុប្បន្នមានក្រុមហ៊ុនអាកាសចរណ៍ទាំងអស់ចំនួន៥ កំពុងបម្រើសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាស។ ក្រុមហ៊ុនទាំង៥នោះ រួមមានៈ ក្រុមហ៊ុន Cathay Pacific Cargo, K-Mile Air, Turkish Airlines, Emirates Sky Cargo និងក្រុមហ៊ុន Qatar Airways ដែលកំពុងប្រតិបត្តិការជាប្រចាំក្នុងការដឹកជញ្ជូនទំនិញនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដោយប្រើប្រាស់ជើងយន្តហោះប្រភេទដឹកទំនិញ ខណៈដែលក្រុមហ៊ុនដឹកជញ្ជូនទំនិញតាមយន្តហោះផ្សេងទៀតបម្រើសេវាកម្មជួលយន្តហោះសម្រាប់ការដឹកជញ្ជូនទំនិញ។

ដើម្បីឆ្លើយតបទៅនឹងកំណើនយ៉ាងធំនៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ស្ថានីយ៍ដឹកជញ្ជូនទំនិញនៅតាមអាកាសយានដ្ឋាន ត្រូវបានពង្រីកបន្ថែមឡើងដោយក្រុមហ៊ុន Cambodia Airports ដូចជាការពង្រីកនូវកន្លែងផ្ទុកទំនិញធំៗឱ្យកាន់តែធំឡើង ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស។ ជាមួយគ្នានេះដែរ ស្ថានីយ៍ដឹកជញ្ជូនទំនិញនៅអាកាសាយនដ្ឋានអន្តរជាតិភ្នំពេញ ត្រូវបានពង្រីកឱ្យធំបន្ថែមក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃចរាចរណ៍ទំនិញនៅតាមផ្លូវអាកាស។ បច្ចុប្បន្ននេះមានក្រុមការងារឃ្លាំងចំនួន៤ សម្រាប់ជួយសម្របសម្រួលក្នុងការលើកដាក់ទំនិញ ដែល

អាចលើកដាក់ទំនិញលើយន្តហោះដឹកជញ្ជូនខ្នាតធំយ៉ាងហោចណាស់២ ឬ៣គ្រឿង ក្នុង១ថ្ងៃ រួមបន្ថែមទាំងការដឹកជញ្ជូនតាមជើងយន្តហោះផ្នែកដឹកអ្នកដំណើរធម្មតា។

ការអភិវឌ្ឍន៍កន្លែងដឹកទំនិញចាស់នៅក្នុងបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ គឺដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការនាពេលអនាគត។ ក្រុមហ៊ុន Cambodia Airports កំពុងបន្តអភិវឌ្ឍចំណតរថយន្តដឹកទំនិញ ការបញ្ជាទិញទំនិញ កន្លែងធ្វើការងារ និងឃ្លាំងស្តុកទំនិញ ដើម្បីបង្កើនប្រសិទ្ធភាពឃ្លាំងផ្ទុកទំនិញ និងចរាចរទំនិញ។

ជាមួយគ្នានេះដែរ ទិន្នន័យដឹកជញ្ជូនទំនិញ (Cargo) តាមផ្លូវអាកាសសម្រាប់ឆ្នាំ២០១៨ មានចំនួន ៧៣ ៥៩១ តោន ក្នុងនោះ៖

- ដឹកជញ្ជូនទំនិញ (International Carried) ជាលក្ខណៈអន្តរជាតិ មានចំនួន ៧៣ ២០៧ តោន និង
- ដឹកជញ្ជូនទំនិញ (Domestic Carried) ក្នុងស្រុកមានចំនួន ៣៨៤ តោន ។

**ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស**

គិតជា តោន

| ចំនួនទំនិញ | 2017 | 2018 | 2019 | 2020 | 2021 | 2022 |
|---|---|---|---|---|---|---|
| អន្តរជាតិ | 63,872 | 73,207 | 80,528 | 88,580 | 97,439 | 107,182 |
| ក្នុងស្រុក | 76 | 384 | 403 | 423 | 445 | 467 |
| **សរុប** | **63,948** | **73,591** | **80,931** | **89,004** | **97,883** | **107,649** |




ជាមួយនឹងការរីកចម្រើនវិស័យទេសចរណ៍ ក្រុមហ៊ុនអាកាសចរណ៍កាន់តែច្រើនបានចាប់អារម្មណ៍ចំពោះទីផ្សារកម្ពុជាមានការប្រកួតប្រជែងខ្លាំងឡើងជាលំដាប់។ ការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ផ្លូវអាកាស (Air Connectivity) ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក ជាពិសេសការរីកចម្រើននៃការហោះហើរទៅកាន់ប្រទេសចិននាពេលថ្មីៗនេះ បានទាក់ទាញភ្ញៀវទេសចរណ៍ជនជាតិចិនជាច្រើនធ្វើដំណើរមកប្រទេសកម្ពុជា។

ក្នុងឆ្នាំ២០១៨នេះ កម្ពុជាទទួលបានភ្ញៀវទេសចរណ៍បរទេស ៥,៦០លាននាក់ ដោយក្នុងនោះប្រហែល ៦០ភាគរយ បានមកដល់តាមផ្លូវអាកាស។ អាកាសយានដ្ឋានអន្តរជាតិទាំង៣ (ភ្នំពេញ, សៀមរាប និង

ខេត្តព្រះសីហនុ)បានទទួលអ្នកដំណើរចំនួន៨,៨លាននាក់ ដោយកើនឡើង២៥ភាគរយ បើប្រៀបធៀបនឹងឆ្នាំ២០១៦។

ចំនួនជើងហោះហើរសរុបបានកើនឡើងដល់ ៩៩ ១៩៧ ហើយចំនួននេះត្រូវបានគេរំពឹងថានឹងកើនឡើងបន្ថែមទៀតនៅឆ្នាំ២០១៩នេះ នៅពេលដែលក្រុមហ៊ុនអាកាសចរណ៍ថ្មីៗនឹងចាប់ផ្តើម ហើយក្រុមហ៊ុនដឹកជញ្ជូនដែលមានស្រាប់ក៏បង្កើនជើងហោះហើរ ឬបន្ថែមផ្លូវហោះហើរថ្មី។ បច្ចុប្បន្នមានក្រុមហ៊ុនអាកាសចរណ៍ចំនួន៤៧ បាននឹងកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ខណៈក្រុមហ៊ុនអាកាសចរណ៍យ៉ាងហោចណាស់ចំនួន៦ ផ្សេងទៀត កំពុងរង់ចាំទទួលវិញ្ញាបនប័ត្រហោះហើរ (AOC) ពីរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលនឹងអនុញ្ញាតឱ្យពួកគេធ្វើការហោះហើរនៅក្នុងដែនអាកាសរបស់ព្រះរាជាណាចក្រកម្ពុជា។

ឆ្នាំ២០១៩ កម្ពុជាមានក្រុមហ៊ុនអាកាសចរណ៍ចំនួន ៥១ បាននឹងកំពុងធ្វើប្រតិបត្តិការហោះហើរចេញ-ចូលកម្ពុជា និងមានកាន់តែច្រើននាពេលខាងមុខ ហើយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រំពឹងថានឹងនៅតែបន្តមានកំណើនជាមួយ នឹងសក្តានុពលទេសចរណ៍ និងស្ថិរភាពនយោបាយនៅកម្ពុជា។

**LIST OF ALL AIRLINES (PASSENGERS)**

| No. | Name of Airlines | No. | Name of Airlines | No. | Name of Airlines |
|---|---|---|---|---|---|
| **I** | **ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក** | **VII** | **The Airlines of China** | 3 | Citilink Indonesia |
| 1 | Cabodia Angkor Air (K6) | 1 | Hong Kong Dragon Airlines | **X** | **The Airlines of Korea** |
| 2 | Sky Angkor Air (ZA) | 2 | Cathay Pacific Airways (Cargo) | 1 | Asiana Airlines |
| 3 | Bassaka Air (5B) | 3 | China Southern Airlines | 2 | Air Seoul |
| 4 | JC Cambodia International Air (QD) | 4 | China Eastern Airlines | 3 | Korean Air |
| 5 | Lanmei Airlines | 5 | Hong Kong Express | 4 | Air Busan |
| 6 | Cambodia Airways | 6 | Spring Airlines | **XI** | **The Airlines of Qatar** |
| **II** | **ក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិ** | 7 | Xiamen Airlines | 1 | Qatar Airways (Passenger and Cargo) |
| | The Airline of Thailand | 8 | Shandong Airlines | **XII** | **The Airlines of United Arab Emirates** |
| 1 | Thai Airways International (TG) | 9 | China Express Airlines | 1 | Emirates Airlines |
| 2 | Thai Smile Air (WE) | 10 | Hainan Airlines | **XIII** | **The Airlines of Turkish** |
| 3 | Bangkok Airways (PG) | 11 | Ruili Airlines | 1 | Turkish Airlines (Cargo) |
| 4 | Thai Air Asia (FD) | 12 | Shenzhen Airlines | XIV | The Airlines of Japan |
| 5 | K-mile Air (Cargo) | 13 | Sichun Airlines | 1 | All Nippon Airways |
| **III** | **The Airlines of Malaysia** | 14 | Air China | | |

| | | | | | |
|---|---|---|---|---|---|
| 1 | Malaysia Air (MH) | 15 | Lucky Air Company Limited | | |
| 2 | Air Asia Berhad (AK) | 16 | Zhejian Loong Airlines | | |
| 3 | Malindo Air | 17 | Juneyao Airlines | | |
| **IV** | **The Airlines of Singapore** | 18 | Qingdao Airlines | | |
| 1 | Silk Air (MI) | 19 | Nine Air | | |
| 2 | Jetstar Asia Airways (3K) | **VIII** | **The Airlines of Taiwan** | | |
| **V** | **The Airlines of Vietname** | 1 | China Airlines | | |
| 1 | Vietnam Airlines (VN) | 2 | Eva Air | | |
| 2 | Vietjet Air(VJ) | **IX** | **The Airlines of philippines** | | |
| **VI** | **The Airline of Lao** | 1 | Cebu Pacific Airlines | | |
| 1 | Lao Airlines (QV) | 2 | Philippines Airlines | | |

*នេះបង្ហាញថា៖ ចុងបញ្ចប់ប្រទេសកម្ពុជា អាចនឹងចាប់ផ្តើមលើកកម្ពស់ដោយខ្លួនឯងចំពោះទិសដៅនៃការតភ្ជាប់ជើងហោះហើរ។*

ដាក់ស្តែងដោយសារកត្តាស្ថានភាពនយោបាយ និងកំណើនផលិតផលជាតិសរុបដែលរក្សាបានក្នុងកម្រិត ៧.៥ភាគរយ របស់កម្ពុជាមានជាបន្តបន្ទាប់ ជាពិសេសគឺ កំណើនភ្ញៀវទេសចរណ៍ដែលមកទស្សនាព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនអាកាសចរណ៍ជប៉ុន All Nippon Airways (ANA) និងក្រុមហ៊ុនអាកាសចរមកពីប្រទេសចិនមួយចំនួនទៀតបានសម្រេចចិត្តធ្វើការហោះហើរត្រង់ (Direct Flight) មកកម្ពុជា ដែលបានចាប់ដំណើរការអាជីវកម្មតាំងពីពាក់កណ្តាលឆមាសទី១ ឆ្នាំ២០១៩។

ដោយឡែកផ្នែកតាមរបាយការណ៍ស្ថិតិដឹកជញ្ជូនតាមផ្លូវអាកាសបានបង្ហាញថា៖ សេវាកម្មដឹកជញ្ជូនទំនិញនាំចេញទៅសហភាពអឺរ៉ុប និងអាមេរិកមានការកើនឡើង ហើយតម្រូវការនាំចូលមកកម្ពុជាក៏មានការកើនផងដែរ។ ថ្មីៗនេះក្រុមហ៊ុន Emirates Sky Cargo ដែលជាផ្នែកដឹកជញ្ជូនទំនិញរបស់ក្រុមហ៊ុនអាកាសចរណ៍ Emirates Airline បានចាប់ផ្តើមដំណើរការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសប្រចាំសប្តាហ៍រវាងទីក្រុងឌូបៃ និងទីក្រុងភ្នំពេញ ហើយវាបានក្លាយជាក្រុមហ៊ុនដឹកជញ្ជូនទំនិញតាមផ្លូវអាកាសឈានមុខគេទី៣ នៅកម្ពុជា បន្ទាប់ពីក្រុមហ៊ុនដឹកជញ្ជូនទំនិញតាមផ្លូវអាកាសជាតិរបស់ប្រទេសម៉ាឡេស៊ី Raya Airways បានដាក់ទិសដៅទីក្រុងភ្នំពេញទៅក្នុងបញ្ជីសេវាកម្មរបស់ខ្លួន ដើម្បីឆ្លើយតបនឹងតម្រូវការដែលកំពុងកើនឡើងនៃការដឹកជញ្ជូនផលិតផលតាមផ្លូវអាកាស ដូចជា៖ វាយនភណ្ឌ និងសំលៀកបំពាក់ជាដើម។

**LIST OF ALL AIRLINES (CARGO)**

| No. | Name of Airlines | No. | Name of Airlines |
|---|---|---|---|
| 1 | K-Mile Airlines (8K) | 4 | Emirate Airways (EK) |
| 2 | Cathay Pacific Airways (CX) | 5 | Turkish Airways (TK) |
| 3 | Quatar Airways Cargo (QR) | | |

ដើម្បីជម្រុញដល់វឌ្ឍនភាពប្រកបដោយចីរភាពនៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស និងស្របតាមផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ទេសចរណ៍ ២០១៧-២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានដាក់ចេញនូវផែនការសកម្មភាពលើការដឹកជញ្ជូនតាមផ្លូវអាកាសសម្រាប់ឆ្នាំ២០២០ ដូចខាងក្រោម៖

- បង្កើនចំនួនអ្នកដំណើរតាមផ្លូវអាកាសជាតិ និងអន្តរជាតិ ឱ្យបានចំនួន១២លាននាក់ ក្នុងឆ្នាំ២០២០ ជាមួយនឹងអត្រាកំណើន១២ភាគរយ ក្នុង១ឆ្នាំ តាមរយៈ ៖
  - កម្ពុជា-ចិន៖ ខិតខំជម្រុញឱ្យមានការហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍កម្ពុជា និងចិន ហោះហើរកាន់តែច្រើនឡើងថែមទៀត ឱ្យសម្រេចគោលដៅដឹកជញ្ជូនភ្ញៀវទេសចរណ៍ចិន ២ លាននាក់ នៅឆ្នាំ២០២០
  - កម្ពុជា-អូស្រ្តាលី៖ ខិតខំជម្រុញឱ្យមានការហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍ Qatar Airways និង Virgin Atlantic Airways ដែលបានដាក់ជើងហោះហើរមកកាន់កម្ពុជារួចហើយ ជាលក្ខណៈ Code-Share Flight
  - កម្ពុជា-ណូវែលហ្សេឡង់ដ៍៖ ខិតខំជម្រុញឱ្យមានការហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍ Air New Zealand ដែលបានដាក់ជើងហោះហើរមកកាន់កម្ពុជារួចហើយ ជាលក្ខណៈ Code-Share Flight
  - កម្ពុជា-រុស្ស៊ី៖ ខិតខំជម្រុញឱ្យមានការហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍ Aeroflot ដែលបានដាក់ជើងហោះហើរមកកាន់កម្ពុជារួចហើយ ជាលក្ខណៈ Code-Share Flight
  - កម្ពុជា-ឥណ្ឌា៖ ខិតខំជម្រុញឱ្យមានការហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍កម្ពុជា និងឥណ្ឌា រវាងប្រទេសទាំង២
  - កម្ពុជា-ហ្វីលីពីន៖ ចូលរួមចំណែកឱ្យមានដំណើរការហោះហើរដោយផ្ទាល់ រវាងរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ទៅកាន់ទីក្រុងម៉ានីឡា
- បង្កើនការចរចាកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស (ASA) ឱ្យបានចំនួន៦០ ប្រទេស និងការធ្វើសមាហរណកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាមួយអាស៊ានឱ្យមានប្រសិទ្ធភាព។
- រៀបចំបែបបទ ដើម្បីស្នើសុំសច្ចាប័នកិច្ចព្រមព្រៀងអាស៊ាន និងបណ្តាឯកសារពាក់ព័ន្ធនានាទៅរដ្ឋសភាតាមរយៈរាជរដ្ឋាភិបាល។
- បង្កើនដំណើរការចុះបញ្ជីរបស់ក្រុមហ៊ុន ដែលផ្តល់សេវាកម្មគាំទ្រដឹកជញ្ជូនតាមផ្លូវអាកាសឱ្យចប់សព្វគ្រប់នៅឆ្នាំ២០២០។
- ជម្រុញការងារគ្រប់គ្រងស្លត ឱ្យកាន់តែមានប្រសិទ្ធភាព និងកសាងបទដ្ឋានគតិយុត្ត និងនីតិវិធីនៃដំណើរការផ្តល់ស្លតជូនក្រុមហ៊ុនអាកាសចរណ៍នានា ដែលហោះចេញ និងចូលព្រះរាជាណាចក្រកម្ពុជា
- រៀបចំចងក្រងឱ្យបាននូវបទបញ្ញត្តិសេដ្ឋកិច្ច ស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ ស្របតាមគោលការណ៍ណែនាំរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO DOC9587)។

- បន្តអនុវត្តគោលនយោបាយទាក់ទាញក្រុមហ៊ុនអាកាសចរណ៍បរទេស ឱ្យធ្វើការហោះហើរត្រង់មកកាន់ទេសកម្ពុជា គឺគោលនយោបាយបើកចំហរជើងមេឃ ដែលប្រកាសដោយ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តាំងពី ឆ្នាំ១៩៩៩ មកម្ល៉េះ។
- ខិតខំរៀបចំធ្វើសមាហរណកម្មចូលក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលបាននឹងកំពុងជម្រុញដល់ដំណើរការបើកចំហរជើងមេឃអាស៊ានលើវិស័យដឹកជញ្ជូនតាមផ្លូវអាកាស។ វាជាឱកាសផ្តល់ដល់ក្រុមហ៊ុនអាកាសចរណ៍អាស៊ានបន្ថែមជើងហោះហើរថ្មីៗ ឬចាប់ផ្តើមការហោះហើររបស់ខ្លួន ដូចជាពេលបច្ចុប្បន្នមានក្រុមហ៊ុនអាកាសចរអាស៊ានស្ទើរតែទាំងស្រុងកំពុងហោះហើរមកកាន់កម្ពុជា លើកលែងតែពីប្រទេសឥណ្ឌូនេស៊ី និងប្រុយណេដារូសាឡាម ហើយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក៏កំពុងធ្វើកិច្ចការនេះយ៉ាងសកម្មផងដែរ ដើម្បីជម្រុញឱ្យមានកំណើនការហោះហើរមកកាន់កម្ពុជា។
- ខិតខំកសាងសមត្ថភាពមន្ត្រីរាជការ និងបុគ្គលិកក្រុមហ៊ុនឯកជនដែលបម្រើការងារលើវិស័យអាកាសចរស៊ីវិលខាងផ្នែកបច្ចេកទេសឱ្យគ្រប់កម្រិតស្តង់ដាអន្តរជាតិ តាមការកំណត់ដោយអង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។
- ជម្រុញវិស័យឯកជននៃព្រះរាជាណាចក្រកម្ពុជា ដែលជាកត្តាគន្លឹះនៃការទាក់ទាញដល់ក្រុមហ៊ុនអាកាសចរណ៍បរទេសសម្រេចចិត្តធ្វើការហោះហើរត្រង់មកកាន់ប្រទេសកម្ពុជាផងដែរ ដូចជា៖ ការពង្រីកស្ថានីយ៍អ្នកដំណើរទ្វេរដងរបស់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងសៀមរាប ដែលអាចទទួលអ្នកដំណើរតាមផ្លូវអាកាសប្រមាណប្រាំលាននាក់ សម្រាប់អាកាសយានដ្ឋាននីមួយៗ ចាប់ពីដើមឆ្នាំ ២០១៧ នេះតទៅ និងពង្រឹងគុណភាពសេវាកម្មនាំផ្លូវអាកាសលំដាប់អន្តរជាតិ ដែលមានការទទួលស្គាល់ដោយអង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។
- ចាត់វិធានការតឹងរឹងថែមទៀត ផ្នែកសន្តិសុខ និងសុវត្ថិភាពជូនអ្នកដំណើរតាមផ្លូវអាកាស ដែលមកដល់ពេលនេះពុំដែលជួបប្រទះនូវឧប្បត្តិហេតុណាមួយគួរឱ្យកត់សំគាល់នៅឡើយទេ។

## ៦. វឌ្ឍនភាពផ្នែកបណ្តុះបណ្តាលធនធានមនុស្សលើវិស័យអាកាសចរស៊ីវិល

វិស័យអាកាសចរស៊ីវិលបានបង្ហាញពីការវិវឌ្ឍគួរឱ្យកត់សំគាល់មួយ តាមរយៈការអភិវឌ្ឍន៍ធនធានមនុស្សឱ្យមានសមត្ថភាពប្រកួតប្រជែង និងលើកកម្ពស់គុណភាព និងប្រសិទ្ធិភាពការងារ ធានាបាននូវសន្តិសុខ និងសុវត្ថិភាពខ្ពស់សម្រាប់ការផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសស្របតាមស្តង់ដារ និងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការធនធានមនុស្សលើវិស័យអាកាសចរស៊ីវិលនៅកម្ពុជា រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េតាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) បានផ្តល់ជំនួយឥតសំណងជូនដល់ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីសាងសង់មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល និងបំពាក់ឧបករណ៍សម្ភារៈបរិក្ខារបច្ចេកទេសបម្រើឱ្យការបណ្តុះបណ្តាល។ មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយបង្កើនល្បឿន សម្រាប់បណ្តុះបណ្តាលសមត្ថភាពរបស់មន្ត្រីអាកាសចរស៊ីវិល និងកាត់បន្ថយការចំណាយលើការបញ្ជូនមន្ត្រីទៅបណ្តុះបណ្តាលនៅក្រៅប្រទេស ព្រមទាំងសន្សំ ពេលវេលា និងនាំយកធនធានមនុស្សដែលមានគុណភាពដើម្បីមកបម្រើការលើវិស័យអាកាសចរស៊ីវិលនៅកម្ពុជា។

ដើម្បីចូលរួមពង្រឹងគុណភាព និងសមត្ថភាពជំនាញរបស់មន្ត្រីពាក់ព័ន្ធឱ្យស្របទៅតាមផែនការអភិវឌ្ឍធនធានមនុស្ស និងឆ្លើយតបបានទៅនឹងតម្រូវការរបស់សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសទាំងរដ្ឋ និងឯកជន មជ្ឈមណ្ឌលបានចាប់ផ្តើមដំណើរការបណ្តុះបណ្តាលធនធានមនុស្សក្នុងឧស្សាហកម្មអាកាសចរស៊ីវិលដល់មន្ត្រីអាកាសចរស៊ីវិល ក៏ដូចជាបុគ្គលិកក្រុមហ៊ុនប្រតិបត្តិករអាកាសចរណ៍ **ជាលទ្ធផលសម្រាប់ឆ្នាំ២០១៨នេះ** មជ្ឈមណ្ឌលបានធ្វើការបណ្តុះបណ្តាល ចំនួន២១វគ្គ ដែលរួមមានដូចខាងក្រោម៖

| No.<br>ល.រ | Training Course<br>វគ្គបណ្តុះបណ្តាល | Training Date (កាលបរិច្ឆេទ) | | Duration<br>រយៈពេល | No. Trainees<br>ចំនួនសិក្ខាកាម |
|---|---|---|---|---|---|
| | | From | To | | |
| 1 | Basic Training for X-Ray Operator (X-Ray 6545) | 04 Jan 2018 | 10 Jan 2018 | 5 days | 7 |
| 2 | Haman Factor in Aviation | 05 Feb 2018 | 09 Feb 2018 | 5 days | 20 |
| 3 | Quality Management System | 05 Feb 2018 | 09 Feb 2018 | 5 days | 20 |
| 4 | Civil Aviation Indoctrination (ICAO Annexes) | 05 Feb 2018 | 23 Feb 2018 | 15 days | 20 |
| 5 | Basic Air Traffic Control 051 | 29 Jan 2018 | 27 Mar 2018 | 40 days | 13 |
| 6 | Adm. & HRM and Developement in SSCA | 19 Mar 2018 | 23 Mar 2018 | 5 days | 20 |
| 7 | Flight Check/Flight Inspection of Navigation | 12 Mar 2018 | 23 Mar 2018 | 10 days | 13 |
| 8 | Flight Operation Officer/Flight Dispatcher | 28 Mar 2018 | 06 Jun 2018 | 45 days | 25 |
| 9 | On The Job Training Instructor (OJTI) | 23 Apr 2018 | 27 Apr 2018 | 5 days | 9 |
| 10 | Introduction of International Air Law | 02 Apr 2018 | 06 Apr 2018 | 5 days | 20 |
| 11 | Safety Management System (SMS) | 02 Apr 2018 | 06 Apr 2018 | 5 days | 20 |
| 12 | State Safety Program (SSP) Implementation | 07 May 2018 | 11 May 2018 | 5 days | 20 |
| 13 | Communication Line VHF Radio-Advance | 07 May 2018 | 11 May 2018 | 5 days | 5 |
| 14 | Basic Training for Airport Security Personnel | 07 May 2018 | 11 May 2018 | 5 days | 20 |
| 15 | Dangerious Goods Awareness | 21 May 2018 | 25 May 2018 | 5 days | 15 |
| 16 | SSCA Orientation Programme | 21 May 2018 | 25 May 2018 | 5 days | 20 |
| 17 | Concept of DME/DVOR | 19 Jun 2018 | 29 Jun 2018 | 9 days | 12 |
| 18 | Air Traffic Simulator Operator | 15 Jul 2018 | 17 Jul 2018 | 3 days | 7 |
| 19 | Aeronautical Meteology Refresher (AMR) | 27 Aug 2018 | 31 Aug 2018 | 8 days | 15 |
| 20 | Aerodrome Control Tower Refresher (ACTR) | 27 Aug 2018 | 04 Sep 2018 | 5 days | 11 |
| 21 | Safety Risk Management | 10 Sep 2018 | 14 Sep 2108 | 5 days | 19 |
| | TOTAL | | | | 363 |

ផ្អែកលើស្ថានភាពឥណទានជាក់ស្តែងឆ្នាំ២០១៨ នេះ និងតាមផែនការបណ្តុះបណ្តាល ដើម្បីបង្កើនសមត្ថភាពដល់មន្ត្រី និងបុគ្គលិកក្រុមហ៊ុនឯកជន មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិលនឹងធ្វើការបណ្តុះបណ្តាលហ្វឹកហ្វឺនជំនាញបច្ចេកទេសក្នុងវិស័យអាកាសចរស៊ីវិលទៅតាមកម្មវិធីចំនួន២៣វគ្គ ជូនដល់មន្ត្រីរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងបុគ្គលិកក្រុមហ៊ុនអាកាសយានដ្ឋាន បុគ្គលិកក្រុមហ៊ុនបញ្ជាចរាចរណ៍ដែនអាកាស ព្រមទាំងបុគ្គលិកក្រុមហ៊ុនសន្តិសុខ ឯកជនដែលមានការពាក់ព័ន្ធផ្សេងៗទៀត។

មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិលបានសហការ និងអញ្ជើញគ្រូឧទ្ទេសនាមជាតិ និងអន្តរជាតិ ដែលមានជំនាញ និងបទពិសោធន៍លើវិស័យអាកាសចរស៊ីវិល និងធ្លាប់បានទទួលការបណ្តុះបណ្តាលនៅក្រៅ

ប្រទេស ជាក់ស្តែងសម្រាប់ឆមាសទី១ឆ្នាំ២០១៩ នេះ មជ្ឈមណ្ឌលបានបើកវគ្គបណ្តុះបណ្តាលចំនួន ១៦ វគ្គ មានសិក្ខាកាមចូលរួម ចំនួន២៦៧នាក់ ទៅមុខជំនាញដូចខាងក្រោម៖

| No.<br>ល.រ | Training Course<br>វគ្គបណ្តុះបណ្តាល | Training Date (កាលបរិច្ឆេទ) | | Duration<br>រយៈពេល | No. Trainees<br>ចំនួនសិក្ខាកាម |
|---|---|---|---|---|---|
| | | From | To | | |
| 1 | SSCA Orientation Programme | 08 Jan 2019 | 14 Jan 2019 | 5 days | 20 |
| 2 | Instrument Landing System | 08 Jan 2019 | 04 Feb 2019 | 20 days | 7 |
| 3 | Quality Management System | 15 Jan 2019 | 21 Jan 2019 | 5 days | 17 |
| 4 | Basic Air Traffic Control 051 | 21 Jan 2019 | 23 Mar 2019 | 40 days | 8 |
| 5 | Civil Aviation Indoctrination | 21 Jan 2019 | 08 Feb 2019 | 15 days | 20 |
| 6 | Civil Aviation Fundamental 1 | 11 Feb 2019 | 04 Apr 2019 | 20 days | 5 |
| 7 | Human Factor In Aviation | 11 Mar 2019 | 15 Mar 2019 | 5 days | 20 |
| 8 | Safety Management System | 11 Mar 2019 | 15 Mar 2019 | 5 days | 20 |
| 9 | National Security Inspector | 18 Apr 2019 | 23 Mar 2019 | 5 days | 15 |
| 10 | Introduction of Search and Rescue | 18 Mar 2019 | 29 Mar 2019 | 10 days | 19 |
| 11 | Aviation Fundamental 2 | 24 Mar 2019 | 23 May 2019 | 20 days | 15 |
| 12 | Administration and HR Management | 25 Mar 2019 | 29 Mar 2019 | 5 days | 20 |
| 13 | State Safety Programme | 25 Mar 2019 | 29 Mar 2019 | 5 days | 20 |
| 14 | Inroeduction to International Air Law | 01 Apr 2019 | 05 Apr 2019 | 5 days | 20 |
| 15 | Aerodrome Control Tower 052 | 01 Apr 2019 | 06 Jun 2019 | 40 days | 8 |
| 16 | Aeronautical Meteorology Refresher | 22 Apr 2019 | 10 Jun 2019 | 30 days | 18 |
| 17 | Basic Training for Airport Security 1 | 29 Apr 2019 | 10 May 2019 | 10 days | 20 |
| 18 | Basic Training for Airport Security 2 | 27 May 2019 | 07 Jun 2019 | 10 days | 20 |
| 19 | Computer Course | 03 Jun 2019 | 01 Jul 2019 | 20 days | 12 |
| | TOTAL | | | | 304 |

ដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ និងដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងពង្រឹងការអប់រំ និងបណ្តុះបណ្តាលជំនាញអាកាសចរស៊ីវិល មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល បានធ្វើបដិសណ្ឋាកិច្ចទទួលភ្ញៀវជាតិ និងអន្តរជាតិដែលមកទស្សនកិច្ចនៅមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ដើម្បីពិភាក្សាការងារ និងផ្លាស់ប្តូរបទពិសោធន៍ការងារលើការបណ្តុះបណ្តាលក្នុងវិស័យអាកាសចរស៊ីវិល ដែលក្នុងនោះរួមមាន៖

- ក្រុមហ៊ុន Bangkok Aviation Centre (BAC)
- បណ្ឌិតសភាអាកាសចរស៊ីវិលវៀតណាម (Vietnam Aviation Academy-VAA)
- វិទ្យាស្ថានជាតិពហុបច្ចេកទេសនៃកម្ពុជា
- គណៈប្រតិភូ ICAO CUSCAP
- ក្រុមហ៊ុនសេវាកម្មចរាចរណ៍ផ្លូវអាកាសកម្ពុជា (CATS)
- មជ្ឈមណ្ឌលបណ្តុះបណ្តាល Dviation Training Centre (MOU)

- គណៈប្រតិភូមេគង្គ Langcang មកពីប្រទេសឡាវ និងភូមា

ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិលបានចុះអនុស្សារណៈយោគយល់គ្នាជាមួយក្រុមហ៊ុន Dviation Training Centre ដើម្បីលើកម្ពស់កិច្ចសហប្រតិបត្តិការ និងពង្រឹងការអប់រំ និងបណ្តុះបណ្តាលជំនាញថែទាំយន្តហោះ (Aircraft Manintenance)។ ជាមួយគ្នានេះដែរ មជ្ឈមណ្ឌលក៏បានចុះកិច្ចព្រមព្រៀងជាមួយលោកស្រី Jennifer Meszaros ជាគ្រូបង្រៀនជនជាតិកាណាដាមកពី Aviation in Asia ដើម្បីរៀបចំបើកវគ្គបណ្តុះបណ្តាលសំខាន់ៗចំនួន៣ រួមមាន៖

- Fundamental of International Aviation
- Aviation English
- Career Life Skill ។

ដើម្បីសម្រេចឱ្យបានចក្ខុវិស័យក្នុងការប្រែក្លាយមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ឱ្យទៅជាមជ្ឈមណ្ឌលមួយដែលល្អបំផុត និងឈានមុខគេក្នុងការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យអាកាសចរស៊ីវិលនៅក្នុងព្រះរាជាណាចក្រកម្ពុជា មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល បានសម្រេចនូវសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- សហការជាមួយក្រុមហ៊ុន Dviation Training Centre, ក្រុមហ៊ុន Khmer Pilot និងលោកស្រី Jennifer Meszaros មកពី Aviation in Asia រៀបចំព្រឹត្តការណ៍ **Aviation Day** នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ ដោយមានសមាសភាពចូលរួមមកពីបណ្តាក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ ក្រុមហ៊ុនប្រតិបត្តិករអាកាសយានដ្ឋាន (SCA) ក្រុមហ៊ុនប្រតិបត្តិករសេវាកម្មនាំផ្លូវអាកាស (CATS) ក្រុមហ៊ុនទេសចរណ៍ សិស្ស និងនិស្សិត និងភាគីពាក់ព័ន្ធចំនួន៣៥០នាក់។
- រៀបចំកម្រងសេវាសាធារណៈរបស់មជ្ឈមណ្ឌល ដើម្បីធ្វើបច្ចុប្បន្នភាព និងដាក់បញ្ចូលក្នុងប្រកាសរួមអន្តរក្រសួងស្តីពីការផ្តល់ សេវាសាធារណៈរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។
- រៀបចំទម្រង់វាយតម្លៃតម្រូវការបណ្តុះបណ្តាល កែសម្រួលឯកសារត្រួតពិនិត្យគុណភាពបណ្តុះបណ្តាល
- ផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលឆ្នាំ២០១៩ ដល់បណ្តាប្រតិបត្តិករអាកាសចរណ៍ ដូចជា៖ ក្រុមហ៊ុន សម្បទានអាកាសយានដ្ឋានកម្ពុជា (Cambodia Airport) ក្រុមហ៊ុនសេវាកម្មចរាចរណ៍ផ្លូវអាកាសកម្ពុជា (CATS) បណ្តាក្រុមហ៊ុនអាកាសអាកាសចរណ៍ជាតិ និងអន្តរជាតិ (Airlines) និងក្រុមហ៊ុនសន្តិសុខផ្សេងៗ។
- បានបើកវគ្គបណ្តុះបណ្តាលលើជំនាញទូទៅ និងជំនាញបច្ចេកទេសបឋមក្នុងវិស័យអាកាសចរស៊ីវិល បានចំនួន ២១ វគ្គ មានសិក្ខាកាមចូលរួមចំនួន ៣៦៣នាក់។
- រៀបចំចងក្រង និងបោះពុម្ពសៀវភៅចំនួន៦៤មុខ មានសៀវភៅចំនួន២៤១ក្បាល សម្រាប់តម្កល់ និងរក្សាទុកនៅបណ្ណាល័យ។
- បានស្នើសុំភាគីកូរ៉េតាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)រួមមាន៖ ដើម្បីតបណ្តាញ និងតម្លើងប្រព័ន្ធទឹកថ្មីសម្រាប់ផ្គត់ផ្គង់លើការប្រើប្រាស់ និងស្រោចស្រពសួនច្បារក្នុងបរិវេណមជ្ឈមណ្ឌល ម៉ាស៊ីនភ្លើងសម្រាប់ផ្គត់ផ្គង់អគារមជ្ឈមណ្ឌលទាំងមូល រួមទាំងការស្នើសុំទិញ Software License ថ្មីសម្រាប់ Computer Base Training ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការធនធានមនុស្សលើវិស័យអាកាសចរស៊ីវិលនៅកម្ពុជា និងដើម្បីពង្រឹងធានាប្រសិទ្ធភាព និងប្រសិទ្ធផល មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិលបានរៀបចំសកម្មភាពសម្រាប់អនុវត្តឆ្នាំ ២០២០ ដូចខាងក្រោម៖

- រៀបចំវគ្គបណ្តុះបណ្តាលផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសក្នុងវិស័យអាកាសចរស៊ីវិល ដល់មន្ត្រីពាក់ព័ន្ធចំនួន៤៤វគ្គ មានតម្រូវការថវិកាចំនួន ៨៦៥ ៦៦២ ០០០រៀល។
- រៀបចំផែនការបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា ក៏ដូចជាសិក្ខាសាលាជូនមន្ត្រី និងថ្នាក់ដឹកនាំមជ្ឈមណ្ឌល ដើម្បីសិក្សាស្វែងយល់ និងបង្កើនសមត្ថភាពចំណេះដឹងបន្ថែម ដើម្បីធ្វើផែនការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលទទួលបាននូវប្រសិទ្ធផលខ្ពស់។
- រៀបចំផែនការទទួលបដិសណ្ឋាកិច្ចគណៈកម្មាធិការវាយតម្លៃ និងចូលជាសមាជិករបស់ Train Air Plus ICAO ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយស្ថាប័នជាតិ-អន្តរជាតិ និងដៃគូរនានាលើការបណ្តុះបណ្តាលធនធានមនុស្ស។
- រៀបចំផែនការធ្វើការទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមរយៈការដាក់ឱ្យដំណើរការគេហទំព័ររបស់មជ្ឈមណ្ឌល។
- រៀបចំបើកសិក្ខាសាលា សន្និសិទ និងកិច្ចប្រជុំជាមួយប្រតិបត្តិករអាកាសចរស៊ីវិល និងដៃគូពាក់ព័ន្ធនានា
- រៀបចំសៀវភៅផែនការមេ បោះពុម្ពសៀវភៅ និងចងក្រងសៀវភៅគោលនយោបាយរបស់មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល។
- ជួសជុលតំហែទឿបករណ៍បរិក្ខារបច្ចេកទេសបម្រើឱ្យការបណ្តុះបណ្តាលដែលផ្តល់ជូនដោយរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ។
- ជួសជុលថែទាអគាររដ្ឋបាល ជណ្តើរយន្ត ឧបករណ៍បរិក្ខារបច្ចេកទេសពត៌មានវិទ្យា និងមិនមែនពត៌មានវិទ្យា។
- ទិញឧបករណ៍សម្ភារៈអនាម័យ, សម្ភារៈការិយាល័យ, ឧបករណ៍សម្ភារៈបរិក្ខារបម្រើឱ្យការថែទាំសួនច្បារ
- រៀបចំទិញកម្មវិធី Software Application សម្រាប់ត្រួតពិនិត្យ និងវាយតម្លៃគុណភាពបណ្តុះបណ្តាល និងកម្មវិធីគ្រប់គ្រងទិន្នន័យសិក្ខាកាម។
- ស្នើសុំទិញរថយន្ត១២កៅអីចំនួន១គ្រឿង សម្រាប់បម្រើការងារនៅមជ្ឈមណ្ឌល ជាពិសេសដឹកជញ្ជូនសិក្ខាកាមទៅទស្សនកិច្ចសិក្សានៅតាមបណ្តាប្រតិបត្តិករអាកាសចរស៊ីវិល និងគ្រឹះស្ថានសិក្សានានា។

## ៧. វឌ្ឍនភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន

អាកាសយានដ្ឋាននៅក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើចំណាត់ថ្នាក់ស្របតាមនិយាមអន្តរជាតិ ដោយបានបែងចែកជា៣ ប្រភេទ គឺ៖

- ប្រភេទអាកាសយានដ្ឋានអន្តរជាតិ (International Airport) - អាកាសយានដ្ឋានខ្នាតធំ (ចាប់ពីកម្រិត 4D ដល់ 4F) និងខ្នាតមធ្យម (ចាប់ពីកម្រិត 3C ដល់ 4C)
- ប្រភេទអាកាសយានដ្ឋានក្នុងស្រុក (Domestic Airport) - អាចចាប់ពីកម្រិត 3C ដល់ 4C និង
- ប្រភេទយន្តហោះ (Airfield) - ព្រលានយន្តហោះតូចៗនៅតាមបណ្តាខេត្តនានា និងតំបន់ដាច់ស្រយាល។

ហេដ្ឋារចនាសម្ព័ន្ធបានក្លាយជាស្នូលនៃយុទ្ធសាស្ត្រអភិវឌ្ឍអាកាសយានដ្ឋានរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលក្រោមកិច្ចព្រមព្រៀងសម្បទានក្រុមហ៊ុន VINCI Airports ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ VINCI

Group នៃប្រទេសបារាំង និងក្រុមហ៊ុន MOHIBBAH SBN នៃប្រទេសម៉ាឡេស៊ីបង្កើតបានជាក្រុមហ៊ុនអាកាសយានដ្ឋានកម្ពុជា (Cambodia Airports) ទទួលបានសិទ្ធសម្បទានវិនិយោគ ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ ហើយបានត្រៀមបម្រុងទឹកប្រាក់ចំនួន២ពាន់លានដុល្លារ សម្រាប់ការអភិវឌ្ឍន៍បណ្តាញអាកាសយានដ្ឋានអន្តរជាតិទាំង០៣នេះ នៅមុនដំណាច់រយៈពេលសម្បទានរបស់ខ្លួននាឆ្នាំ២០៤០។

ក្នុងឆ្នាំ២០១៨នេះ ក្រុមហ៊ុនអាកាសយានដ្ឋានកម្ពុជា បានបញ្ចប់ការធ្វើបច្ចុប្បន្នភាពនៃអាកាសយានដ្ឋានដោយចំណាយទុនសាងសង់ចំនួន ១០០លានដុល្លារ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងសៀមរាប ដើម្បីបង្កើនសមត្ថភាពទទួលភ្ញៀវបានជាង ១០លាននាក់ ក្នុង១ឆ្នាំ និងបន្ថែមសេវាកម្មថ្មីៗផងដែរ។ ដំណាក់កាលទី២ នៃការពង្រីកនេះត្រូវបានដាក់ឱ្យដំណើរការកាលពីខែធ្នូ ឆ្នាំ២០១៧ មានដូចជា៖ ច្រកទ្វារសម្រាប់អ្នកដំណើរធ្វើដំណើរឡើងយន្តហោះ ផ្តល់នូវកន្លែងរង់ចាំអ្នកដំណើរមកដល់ និងចំណតរង់ចាំសម្រាប់អ្នកដំណើរក្នុងស្រុក (ជើងហោះហើរក្នុងស្រុក) ថ្មីមួយ។ ការជួសជុលឡើងវិញនៃអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ នាពេលបច្ចុប្បន្នកំពុងដំណើរការ ហើយរំពឹងថានឹងបញ្ចប់ក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ។ គម្រោងការនេះ មានការពង្រីកកន្លែងអ្នកដំណើររង់ចាំឡើងយន្តហោះ ដើម្បីផ្ទុកអ្នកដំណើរឱ្យបានកាន់តែច្រើន និងផ្តល់នូវសេវាកម្មកាន់តែទូលំទូលាយ ក៏ដូចជាការពង្រីក និងការត្រួតពិនិត្យផ្លូវរត់ និងចំណត ដើម្បីសំចតយន្តហោះដែលមានទំហំធំជាងមុន។ នៅពេលដែលគម្រោងការនេះបញ្ចប់ អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ នឹងអាចទទួលអ្នកដំណើរជាងកន្លះលាននាក់ក្នុង១ឆ្នាំ និងផ្តល់សេវាកម្មដល់យន្តហោះមានទំហំធំៗជាងមុន។

## ៧.១- អាកាសយានដ្ឋានអន្តរជាតិ

ក្រុមហ៊ុនអាកាសយានដ្ឋានកម្ពុជា ដែលជាប្រតិបត្តិករផ្តាច់មុខនៃអាកាសយានដ្ឋានជាតិ និងអន្តរជាតិទាំង៣ របស់ព្រះរាជាណាចក្រកម្ពុជា បានវិនិយោគយ៉ាងច្រើនក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃជើងហោះហើរ ចំនួនអ្នកដំណើរ ការដឹកជញ្ជូនទំនិញ និងត្រៀមខ្លួនទទួលយកភាពរីកចម្រើនបន្ថែមទៀតនាពេលអនាគត។

អាកាសយានដ្ឋានអន្តរជាតិទាំង៣ ត្រូវបានរាជរដ្ឋាភិបាលប្រគល់សិទ្ធិក្នុងការគ្រប់គ្រង និងអភិវឌ្ឍជូនទៅក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) ក្រោមរូបភាពសាងសង់-អាជីវកម្ម-ផ្ទេរ (BOT) ហើយបានធ្វើឱ្យមានការប្រែប្រួលជា វិជ្ជមានទាំងរូបភាព និងសមត្ថភាពរបស់អាកាសយានដ្ឋាន ជាលទ្ធផល ដោយសារមានកំណើនភ្ញៀវអ្នកដំណើរតាមផ្លូវអាកាស ដើម្បីធានាដល់ប្រតិបត្តិការអាជីវកម្ម ជាពិសេសគឺការចតចាំរបស់យន្តហោះ ក្រុមហ៊ុនបានពង្រីកស្ថានីយ៍អ្នកដំណើរអន្តរជាតិនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប ចំណតអាកាសយាន (អាកាសយានដ្ឋានអន្តរជាតិសៀមរាប បានចំនួន ៥ចំណត និងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបានចំនួន ៦ចំណត) ព្រមទាំងបានពង្រីកទំហំផ្លូវរត់ និងពង្រឹង តំបន់សុវត្ថិភាពចុងផ្លូវរត់ ០៥ (អាកាសយានដ្ឋានអន្តរជាតិសៀមរាប) និងបំពាក់ឧបករណ៍លើដីថ្មី បំពាក់ឧបករណ៍កាមេរ៉ាសុវត្ថិភាពនៅស្ថានីយ៍អ្នកដំណើរថ្មីៗ និង ទំនិញ ព្រមទាំងបានបណ្តុះបណ្តាលបុគ្គលិកសម្រាប់ស្ថានីយ៍អ្នកដំណើរក្នុង និងក្រៅប្រទេសនៅអាកាសយាន ដ្ឋានអន្តរជាតិទាំង០៣។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលមានគោលដៅចំនួន២ គឺ: ទី១-នៅក្នុងបរិបទកំណើនខ្ពស់នៃចរាចរអ្នកដំណើរ និងទី២-ដើម្បីគិតគូរទុកមុនពីកំណើនទៅថ្ងៃអនាគត ត្រូវបង្កើនសមត្ថភាពបដិសណ្ឋាកិច្ចនៃអាកាសយានដ្ឋាន។ បន្ទាប់ពីកំណើននៅឆ្នាំ២០១៦ ដែលចរាចរណ៍នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបានកើនឡើងជាង ១០ភាគរយ ពោលគឺចំនួនអ្នកដំណើរបានឈានដល់៣,៤លាននាក់។

ទន្ទឹមនឹងនេះ ដើម្បីធានាដល់សុវត្ថិភាពរបស់យន្តហោះនៅពេលហោះឡើង និងចុះចត ដោយមានកិច្ចសហការល្អជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (Cambodia Airports) រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានតាមដាន ត្រួតពិនិត្យ និងផ្តល់យោបល់លើលក្ខណៈបច្ចេកទេសនៃការអភិវឌ្ឍន៍ និងកែលម្អបន្ថែមហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិទាំង៣ ដើម្បីឱ្យស្របតាមច្បាប់អាកាសចរស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដាររបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។

## ៧.២- អាកាសយានដ្ឋានក្នុងស្រុក

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានខិតខំប្រឹងប្រែងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានក្នុងស្រុក ដោយប្រើប្រាស់កញ្ចប់ថវិកាជាតិដែលបានវិភាជផ្ទាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគោលដៅបម្រើសេវាកម្មអាកាសចរជូនដល់ក្រុមហ៊ុន និងអង្គការអន្តរជាតិនានា ដូចជាការជួសជុលផ្លូវរត់នៅអាកាសយានដ្ឋាន បាត់ដំបង ការជួសជុលអគារ រដ្ឋបាល និងការតបណ្តាញអគ្គិសនីនៅអាកាសយានដ្ឋានកោះកុង ការជួសជុលស្ថានីយ៍អ្នកដំណើរនៅអាកាសយានដ្ឋានស្ទឹងត្រែងជាដើម។ ទន្ទឹមនឹងនេះ ដើម្បីចូលរួមការពារទ្រព្យសម្បត្តិឯកជនរបស់រដ្ឋឱ្យបានគង់វង្សជៀសវាងការបាត់បង់ជាយថាហេតុ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលក៏បានដំណើរការធ្វើប័ណ្ណកម្មសិទ្ធិដីធ្លី និងអគារដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់។ ជាក់ស្តែងការធ្វើប័ណ្ណកម្មសិទ្ធអាកាសយានដ្ឋានកោះកុងអនុវត្តបានសម្រេចចំនួន១០០ ភាគរយ អាកាសយានដ្ឋានស្ទឹងត្រែងអនុវត្តបានចំនួន៦០ភាគរយ ទៅលើការបោះបង្គោលព្រំខណ្ឌដី។

ដោយពិនិត្យឃើញស្ថានភាពនយោបាយ-សេដ្ឋកិច្ច និងសង្គមកិច្ចក្នុងតំបន់ ក៏ដូចជានៅក្នុងប្រទេសមានការវិវត្តន៍ និងផ្លាស់ប្តូរគួរឱ្យកត់សំគាល់នោះ រាជរដ្ឋាភិបាលបានសម្រេចឱ្យរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលប្រគល់ និងកាត់ចេញពីការគ្រប់គ្រងរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងពីបញ្ជីសារពើភ័ណ្ឌរបស់រដ្ឋនូវអាកាសយានដ្ឋានក្នុងស្រុកមួយចំនួនដូចជា៖ អាកាសយានដ្ឋានរតនគីរី អាកាសយានដ្ឋានមណ្ឌលគីរី (ទីតាំងចាស់) អាកាសយានដ្ឋានព្រះវិហារ និងអាកាសយានដ្ឋានក្រចេះ ព្រមទាំងវាលយន្តហោះក្នុងស្រុក (ព្រលានយន្តហោះតូចៗ) នៅតាមខេត្តមួយចំនួន (យោងតាមអនុសាសន៍ណែនាំរបស់សម្តេចតេជោ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ដោយរក្សាទុកតែអាកាសយានដ្ឋាន ដូចខាងក្រោម៖

ក. អាកាសយានដ្ឋានអន្តរជាតិទាំង៣ មាន៖ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិសៀមរាប អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ និង

ខ. អាកាសយានដ្ឋានក្នុងស្រុកទាំង៤ មាន៖ អាកាសយានដ្ឋានកំពង់ឆ្នាំង អាកាសយានដ្ឋានកោះកុង អាកាសយានដ្ឋានបាត់ដំបង និងអាកាសយានដ្ឋានស្ទឹងត្រែងជាអាកាសយានដ្ឋានបម្រុង និងជាអាកាសយានដ្ឋានយុទ្ធសាស្រ្តយូរអង្វែងសម្រាប់ការអភិវឌ្ឍវិស័យដឹកជញ្ជូនផ្លូវអាកាសក៏ដូចជាវិស័យទេសចរណ៍ ប្រកបដោយសន្តិទានភាព និងចិរភាព។

ទន្ទឹមនឹងនេះ ដើម្បីធានាដល់សុវត្ថិភាពរបស់យន្តហោះនៅពេលហោះឡើង និងចុះចតចាំបាច់ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវមានកញ្ចប់ថវិកាសមរម្យ ដើម្បីធ្វើការជួសជុល និងកែលម្អ ព្រមទាំងថៃទាំលើហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានក្នុងស្រុកទាំងអស់ ដើម្បីឱ្យស្របតាមស្តង់ដារបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។

ជាមួយគ្នានេះរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល កំពុងតែរកដៃគូវិនិយោគលើអាកាសយានដ្ឋានអាទិភាពក្នុងស្រុកមួយចំនួន ដើម្បីធ្វើការវិនិយោគ និងប្រតិបត្តិការក្រោមរូបភាពភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) ឬកម្ចីសម្បទានពីដៃគូអន្តរជាតិផ្សេងៗដើម្បីអភិវឌ្ឍអាកាសយានដ្ឋានក្នុងស្រុកទាំងនោះ។

## ៨. វឌ្ឍនភាពផ្នែកប្រព័ន្ធសុវត្ថិភាពនាំផ្លូវអាកាស

ដើម្បីធានាដល់ការផ្តល់សេវាកម្មលើការងារត្រួតពិនិត្យចរាចរដែនអាកាស និងគ្រប់គ្រងការប្រើប្រាស់ដែនអាកាសប្រកបដោយភាពជឿទុកចិត្តពីប្រតិបត្តិករ ជាពិសេសគឺអ្នកដំណើរតាមផ្លូវអាកាស រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលមានកាតព្វកិច្ចគ្រប់គ្រង និងត្រួតពិនិត្យលើការផ្តល់សេវាកម្មផ្នែកប្រព័ន្ធសុវត្ថិភាពនាំផ្លូវអាកាស ហើយត្រូវការចាំបាច់ក្នុងការពង្រឹងសមត្ថភាពធនធានមនុស្ស និងរៀបចំបទបញ្ញត្តិ រួមទាំងបទដ្ឋានគតិយុត្តិពាក់ព័ន្ធស្តីពីសេវាកម្មនាំផ្លូវអាកាសដើម្បីត្រួតពិនិត្យទៅលើប្រតិបត្តិករសេវាកម្មចរាចរដែនអាកាស រួមមាន៖ សេវាកម្មចរាចរដែនអាកាស (ATS) សេវាកម្មផ្តល់ព័ត៌មានអាកាសចរវិទ្យា (AIS) សេវាកម្មប្រព័ន្ធទាក់ទងនាំផ្លូវ និងឃ្លាំមើលដែនអាកាស (CNS) សេវាកម្មបទដ្ឋានហោះហើរ (IFPD) សេវាកម្មគូរផែនទីអាកាសចរណ៍ (CHART) សេវាកម្មផ្តល់ព័ត៌មានឧតុនិយម (MET) និងសេវាកម្មរុករក និងសង្គ្រោះ (SAR)។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានតួនាទីនៅក្នុងការគ្រប់គ្រង និងត្រួតពិនិត្យដែនអាកាស (Air Space) ទូទាំងប្រទេសកម្ពុជា និងអភិវឌ្ឍផ្លូវអាកាសផ្លូវអាកាសជាតិ និងអន្តរជាតិ ហើយបានផ្តល់ឱ្យក្រុមហ៊ុនអាកាសចរណ៍មានទស្សនវិស័យល្អប្រសើរជាងមុននៅពេលពិភាក្សាអំពីផ្លូវហោះហើរថ្មី។ ឧទាហរណ៍ ក្រុមហ៊ុនអាកាសចរណ៍មួយដែលកំពុងស្វែងរកការបើកដំណើរការផ្លូវហោះហើរអន្តរជាតិទៅកាន់ខេត្តសៀមរាប អាចពិភាក្សាជាមួយនឹងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលអំពីលទ្ធភាពបន្ថែមជើងហោះហើរក្នុងស្រុក ទៅកាន់ខេត្តព្រះសីហនុផងដែរ។

ក្រុមហ៊ុនសេវាកម្មចរាចរដែនអាកាសកម្ពុជា (Cambodia Air Traffic Service-CATS) ជាប្រតិបត្តិករវិនិយោគទទួលខុសត្រូវលើការផ្តល់សេវាកម្មចរាចរដែនអាកាសទូទាំងប្រទេសកម្ពុជា ហើយដែលមានកាតព្វកិច្ចក្នុងការគ្រប់គ្រង និងផ្តល់សេវាកម្មបញ្ជាហោះហើរចរាចរណ៍ផ្លូវអាកាស (Air Traffic Control)។

បន្ទាប់ពីគម្រោងការ New CNS/ATM ត្រូវបានបញ្ចប់ជាស្ថាពរ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានអនុវត្តបទដ្ឋានហោះហើរថ្មីដោយប្រើប្រាស់ប្រព័ន្ធផ្កាយរណប (PBN) ចំពោះអាកាសយានដ្ឋានអន្តរជាតិទាំង៣ ដោយកាត់បន្ថយបាននៅពេលវេលា រយៈចម្ងាយហោះហើរ និងថ្លៃដើមនៃការហោះហើរ។

ជាលទ្ធផលសម្រាប់ឆ្នាំ២០១៨ លើការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពនាំផ្លូវអាកាសរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានដូចខាងក្រោម៖

- បានបញ្ជូនមន្ត្រីអធិការកិច្ច (Inspectors) ចំនួន៧នាក់ ទៅទទួលការបណ្តុះបណ្តាលនៅក្រៅប្រទេស លើផ្នែក៖ ANS, ATS, AIS, CNS, PANS-OP & CHART, MET, SAR ដើម្បីឱ្យមានសមត្ថភាព និងគុណវឌ្ឍឆ្លើយតបទៅនឹងស្តង់ដារបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) ។
- បានបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសឱ្យមានសមត្ថភាព និងគុណវុឌ្ឍន៍ចំនួន១៧នាក់ សម្រាប់ជំនាញ ANS, ATS, AIS, CNS, PANS-OPS & Chart, MET and SAR ។
- បានរៀបចំកិច្ចប្រជុំជាតិ និងអន្តរជាតិក្នុងនាមជាម្ចាស់ផ្ទះ និងជាប្រធានអង្គប្រជុំ ដូចជា៖ កិច្ចប្រជុំ SEACG, SOUTH EAST ASIA-INDIAN OCEAN ATM COORDINATION GROUP ។
- បានចុះកិច្ចព្រមព្រៀងបច្ចេកទេស ស្តីពីការកែតម្រូវប្រតិបត្តិការសេវាកម្មបញ្ជាហោះហើរ (Operational Letter of Agreement) ជាមួយភាគីថៃ ក្នុងកិច្ចប្រជុំ ATM Coordination Technical ។
- ផ្អែកតាមកម្មវិធីរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) និង ASEAN បានបញ្ជូនមន្ត្រីបច្ចេកទេស ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំសំខាន់ៗ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ការងារ និងធ្វើបច្ចុប្បន្នភាពកិច្ចការនានាដែលពាក់ព័ន្ធនឹងសេវាកម្មនាំផ្លូវអាកាស។
- បានរៀបចំ ចងក្រង និងធ្វើបច្ចុប្បន្នភាពបទបញ្ញត្តិបច្ចេកទេស CCAR Part 18 ស្តីពីការគ្រប់គ្រងសេវាកម្ម ATS, AIS, CNS, PANS-OPS & Chart, MET and SAR ។
- សហការជាមួយអ្នកជំនាញការរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ ក្នុងការដោះស្រាយបញ្ហាប្រឈមលើផ្នែកនាំផ្លូវអាកាស ដោយទទួលបាននូវលទ្ធផល ដូចជា៖ របាសម្ព័ន្ធ ឯកសារគតិយុត្តិ ធនធានមនុស្ស និងបង្រៀនអំពីបច្ចេកទេស និងនីតិវិធីក្នុងការចុះធ្វើអធិការកិច្ច។
- រៀបចំកម្រងឯកសារសម្រាប់ធ្វើអធិការកិច្ច និងនីតិវិធីអនុវត្តការងារនានាលើផ្នែក ATS, AIS, CNS, PANs-OP & Chart, MET and SAR ។
- បានចុះធ្វើងធិការកិច្ចលើផ្នែកATS, CNS, PANS-OPS ដើម្បីឆ្លើយតបទៅនឹង Protocol Questionaires នៃ Critical Element ទី៧ របស់ ICAO-USOAP។
- បានបោះពុម្ព និងផ្សព្វផ្សាយពត៌មានអាកាសចរណ៍ ដូចជា៖ AIP Amendment, AIP Supplements, AIC ព្រមទាំងបានចែកចាយជូនដល់បណ្តាប្រទេសជាសមាជិក ICAO ក្រុមហ៊ុនអាកាសចរណ៍ជាតិ និងអន្តរជាតិដែលធ្វើប្រតិបត្តិការក្នុងដែនអាកាសកម្ពុជា។
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ទទួលខុសត្រូវផងដែរលើការគ្រប់គ្រង ចាត់ចែង និងផ្តល់សេវាកម្មឧតុនិយមអាកាសចរណ៍ដល់បណ្តាក្រុមហ៊ុនអាកាសចរណ៍ជាតិ និងអន្តរជាតិដែលធ្វើប្រតិបត្តិការហោះហើរនៅកម្ពុជា ដើម្បីទទួលបាននូវសុវត្ថិភាពជូនអាកាសយានដែលធ្វើប្រតិបត្តិការ។

ដើម្បីពង្រឹងប្រព័ន្ធសុវត្ថិភាពសេវាកម្មនាំផ្លូវអាកាសប្រកបដោយប្រសិទ្ធភាពខ្ពស់ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានកំណត់នូវសកម្មភាពអាទិភាពសម្រាប់អនុវត្តឆ្នាំ២០២០ ដូចខាងក្រោម៖

- បន្តធានាសុវត្ថិភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពនាំផ្លូវអាកាស។
- បន្តរៀបចំ និងចងក្រងបទប្បញ្ញត្តិ នីតិវិធី ស្តង់ដាតម្រូវការ សេចក្តីណែនាំ សៀវភៅណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងស្តង់ដា និងសុវត្ថិភាពនាំផ្លូវអាកាស និងសេវាកម្មនាំផ្លូវអាកាស។

- បណ្តុះបណ្តាលមន្ត្រីអធិការកិច្ច (Inspectors) នៅក្រៅប្រទេសឱ្យគ្រប់លក្ខខ័ណ្ឌរបស់ ICAO ចំនួន៧ នាក់ ថែមទៀត។
- បន្តចុះធ្វើអធិការកិច្ចលើបណ្តាប្រតិបត្តិករដែលបម្រើសេវាកម្មនាំផ្លូវអាកាស។
- ចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាសំខាន់ៗរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ និងដៃគូអន្តរជាតិនានា។
- ពង្រឹង និងបណ្តុះបណ្តាលមន្ត្រីជំនាញបច្ចេកទេសបន្ថែមនៅក្នុង និងក្រៅប្រទេស។

## ៩. វឌ្ឍនភាពផ្នែកប្រតិបត្តិការហោះហើរ និងលទ្ធភាពហោះហើរ

ដើម្បីរក្សាបាននូវសុវត្ថិភាពអ្នកដំណើរតាមផ្លូវអាកាស រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលមានភារកិច្ចក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងចេញវិញ្ញាបនប័ត្រទៅដល់ប្រតិបត្តិករអាកាសចរណ៍ ក៏ដូចជាបុគ្គលិកអាកាសចរណ៍ និងអាកាសយានគ្រប់ប្រភេទដែលធ្វើប្រតិបត្តិការអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។ ដើម្បីពង្រឹងប្រតិបត្តិការ និងសុវត្ថិភាពហោះហើរស្របតាមស្តង់ដារបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលយកចិត្តទុកដាក់លើការងារបច្ចេកទេសមួយចំនួន ដែលរួមមានៈការរៀបចំបទបញ្ញត្តិ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលទាក់ទងទៅនឹងស្តង់ដា និងសុវត្ថិភាពហោះហើរ , ពិនិត្យ និងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់ ផ្អាក ដកហូត និងបន្តវិញ្ញាបនប័ត្រប្រតិបត្តិការផ្លូវអាកាសចំពោះសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសដែលកាន់វិញ្ញាបនប័ត្រប្រតិបត្តិការផ្លូវអាកាសរបស់កម្ពុជា រួមទាំងការវាយតម្លៃបច្ចេកទេសលើការអនុញ្ញាតផ្តល់ប្រតិបត្តិការហោះហើរនៃអាកាសយានគ្រប់ប្រភេទដែលហោះហើរនៅក្នុង ចេញ-ចូល និងឆ្លងកាត់អាកាសកម្ពុជា។

ដើម្បីធានាបាននូវសុវត្ថិភាពហោះហើរ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលទទួលខុសត្រូវលើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៃអាកាសយាន ដូចជាការចុះបញ្ជីអាកាសយាន ការផ្តល់វិញ្ញាបនប័ត្រលទ្ធភាពហោះហើរ វិញ្ញាបនប័ត្របញ្ជាក់សមត្ថភាពវិស្វករ និងអ្នកជំនាញបច្ចេកទេសជាដើម។ ដោយអនុលោមតាមច្បាប់ស្តីពីអាកាសចរស៊ីវិល និងបទបញ្ញត្តិអាកាសចរស៊ីវិល និងផែនការសកម្មភាពដែលបានកំណត់ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានចុះធ្វើអធិការកិច្ចទៅតាមបណ្តាក្រុមហ៊ុនអាកាសចរជាតិ និងអន្តរជាតិដែលបានធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ដូចជា៖ ត្រួតពិនិត្យ និងវាយតម្លៃបច្ចេកទេសសុវត្ថិភាពហោះហើរ (បន្តសុពលភាពវិញ្ញាបនប័ត្រប្រតិបត្តិការផ្លូវអាកាស, បន្តសុពលភាពអាកាសយានិក) ត្រួតពិនិត្យ និងវាយតម្លៃបច្ចេកទេសលទ្ធភាពហោះហើរ (បន្តសុពលភាព AOC, AMO, Aircraft) ត្រួតពិនិត្យ និងវាយតម្លៃអាជ្ញាប័ណ្ណបុគ្គលិក (បន្តសុពលភាព Personnel Licensing) សម្រាប់បម្រើសេវាកម្មអាកាសចរណ៍។

ដើម្បីពង្រឹងប្រតិបត្តិការហោះហើរ និងលទ្ធភាពហោះហើរឱ្យមានសុវត្ថិភាពធានាដល់ការធ្វើដំណើរតាមផ្លូវអាកាស រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានកំណត់សកម្មភាពការងារអាទិភាពមួយចំនួនសម្រាប់អនុវត្តនៅឆ្នាំ២០២០ មានដូចខាងក្រោម:

- ត្រួតពិនិត្យសុវត្ថិភាពអាកាសចរណ៍ និងរោងជាងថែរក្សាបច្ចេកទេសយន្តហោះ។
- ធ្វើអធិការកិច្ច ចំពោះក្រុមហ៊ុនអាកាសចរណ៍ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- បណ្តុះបណ្តាលជំនាញត្រួតពិនិត្យ និងវាយតម្លៃក្នុងការផ្តល់ ផ្អាក បន្តវិញ្ញាបនប័ត្រអាកាសយាន។

- បណ្តុះបណ្តាលជំនាញត្រួតពិនិត្យ និងវាយតម្លៃក្នុងការផ្តល់ ផ្អាក បន្តវិញ្ញាបនប័ត្រប្រតិបត្តិការហោះហើរ។
- បណ្តុះបណ្តាលជំនាញត្រួតពិនិត្យ និងវាយតម្លៃក្នុងការផ្តល់ ផ្អាក បន្តវិញ្ញាបនប័ត្រអាកាសយានិក និងបុគ្គលិកបម្រើការនៅតាមបណ្តាប្រតិបត្តិករអាកាសចរណ៍។
- បណ្តុះបណ្តាលអធិការកិច្ចលទ្ធភាពហោះហើរ ស្តីពីកិច្ចការប្រតិបត្តិការផ្លូវអាកាស និងរោងជាងជួសជុលយន្តហោះ។
- បណ្តុះបណ្តាលធនធានមនុស្សបន្តវេន (AMO រយៈពេលជាមធ្យម២ឆ្នាំ នៅព្រះរាជាណាចក្រថៃ)។
- ត្រួតពិនិត្យលទ្ធភាពហោះហើរ ចំពោះអាកាសយាន និងរោងជាងនៅក្នុង និងក្រៅប្រទេស
- ធ្វើអធិការកិច្ចលើលទ្ធភាពហោះហើរ ចំពោះអាកាសយាន និងរោងជាងនៅក្នុង និងក្រៅប្រទេស។
- ចុះធ្វើការតាមដាន និងការអនុវត្ត Surveillance Programme គ្រប់ក្រុមហ៊ុនអាកាសចរណ៍ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។
- ចុះធ្វើការបន្តសម្រាប់ក្រុមហ៊ុនអាកាសចរណ៍នានាដែលផុតកំណត់ និងបន្តសុពលភាពឱ្យក្រុមហ៊ុននានា។
- បណ្តុះបណ្តាលអាកាសនិកជំនាន់ថ្មី ដើម្បីក្លាយជាអធិការចុះត្រួតពិនិត្យតាមក្រុមហ៊ុនអាកាសចរណ៍ដែលបានធ្វើប្រតិបត្តិការនៅកម្ពុជា។
- បន្តតាមដានសុវត្ថិភាពហោះហើរតាមក្រុមហ៊ុននានា ដែលកំពុងតែប្រតិបត្តិការនៅកម្ពុជា។

### ១០. វឌ្ឍនភាពផ្នែកក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តិអាកាសចរស៊ីវិល

ច្បាប់អាកាសចរស៊ីវិលត្រូវបានអនុម័តដោយរដ្ឋសភាកាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៧ និងដោយព្រឹទ្ធសភាកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ហើយបានប្រកាសដាក់អោយប្រើប្រាស់ដោយព្រះរាជក្រម ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨។ ជាមួយគ្នានេះផងដែរ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (រ.ល.អ.ស) បានចងក្រង និងដាក់ចេញនូវបទបញ្ញត្តិសុវត្ថិភាព (Cambodia Civil Aviation Regulation-CCAR) ដែលទាក់ទងដល់បញ្ញត្តិ ស្តីពីលទ្ធភាពហោះហើរ (AIR) ប្រតិបត្តិការហោះហើរ (OPS) ការផ្តល់វិញ្ញាបនប័ត្រ (PEL) អធិការកិច្ច (Inspection) ការចេញវិញ្ញាបនប័ត្រ (Certification) លើសេវាអាកាសយានដ្ឋាន សេវាត្រួតពិនិត្យដែនអាកាស ក្រុមហ៊ុនអាកាសចរណ៍ និងសន្តិសុខអាកាសចរស៊ីវិល រួមទាំងបទបញ្ញត្តិបច្ចេកទេសផ្សេងៗទៀត និងបានធ្វើកិច្ចកែសម្រួលបន្ថែមជាបន្តបន្ទាប់ទៅលើបទបញ្ញត្តិ នីតិវិធី សេចក្តីណែនាំ ព្រមទាំងបទដ្ឋានគតិយុត្តិមួយ ចំនួនទៀតដើម្បីឱ្យស្របតាមតម្រូវការ និងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។ ក្នុងនោះដែររដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានរៀបចំបទបញ្ញត្តិ ស្តីពីកម្មវិធីសន្តិសុខអាកាសចរជាតិ (National Security Program) កម្មវិធីសុវត្ថិភាពជាតិ (SSP-State Safety Program) កម្មវិធីសុវត្ថិភាពនាំផ្លូវអាកាស កម្មវិធីត្រួតពិនិត្យសុវត្ថិភាព (Safety Oversight and Audit) និងព្រមទាំងខិតខំអនុវត្តផែនការសកម្មភាពកែតម្រូវរបស់ខ្លួនជាបណ្តើរៗស្របតាមរបកគំហើញនៃកម្មវិធីត្រួតពិនិត្យសុវត្ថិភាពសកលរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO-USOAP) នៅក្នុងកម្រិតថ្នាក់ជាតិរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានផ្សព្វផ្សាយ និងស្វែងយល់ស្តីពីការអនុវត្តច្បាប់អាកាសចរស៊ីវិលដល់ស្ថាប័នរដ្ឋ និងសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស។

ជាមួយគ្នានេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានរៀបចំផែនការកែតម្រូវ (Corective Action Plan-CAPs) ដើម្បីដោះស្រាយចំណុចខ្សោយ (Findings) លើជំនាញ LEG (11 CAPs), ORG (04 CAPs), PEL (54 CAPs), OPS (80 CAPs), AIR (43 CAPs) និងបានដាក់បញ្ចូលក្នុង ICAO Website។ ទន្ទឹមនឹងនេះដើម្បីឱ្យវិស័យអាកាសចរស៊ីវិលពង្រឹងបានលើផ្នែកសុវត្ថិភាព និងសន្តិសុខប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធភាព រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបាននឹងកំពុងរៀបចំស្វែង រកជំនួយបច្ចេកទេសពីដៃគូរក្នុងការរៀបចំបទបញ្ញត្តិសេដ្ឋកិច្ច និងបទបញ្ញត្តិបច្ចេកទេសមួយចំនួនទៀត ដើម្បីធានាបាននូវបរិការធុរកិច្ចក្នុងវិស័យដឹកជញ្ជូនផ្លូវអាកាសប្រកបដោយនិរន្តភាព។

បទប្បញ្ញត្តិ និងនីតិវិធី (Regulations and Procedures) ចំនួន៧ ត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាព ដែលរួមមានដូចខាងក្រោម៖

- CCARs part 12, issue 4, revision 2, 18 September 2018
- CCARs part 18, issue 3, revision 0, 16 November 2018
- CCARs part 1, issue 3, revision 1, 04 October 2018
- Aerodrome Inspect Mannual, issue 2, revision 1, 04 October 2018
- IRLA procedure Mannual, issue 2, revision 0, 04 October 2018
- Enforcement Policy and Procedure, issue 2, revision 0, 04 October 2018
- Policy and Procedure for issuance of exemption, issue 2, revision 0, 04 October 2018។

## ១១. វឌ្ឍនភាពលើផ្នែកការចូលរួមពីវិស័យឯកជន និងការធ្វើឯកជនភាវូបនីយកម្ម

ដើម្បីជម្រុញ និងលើកទឹកចិត្តការវិនិយោគរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុក្នុងការចូលរួមស្តារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ព្រមទាំងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត ប្រកបដោយសក្តិសិទ្ធភាព និងប្រសិទ្ធភាពខ្ពស់ប្រកបដោយឧត្តមានុវត្តអន្តរជាតិ (International Best Practice) សំដៅរួមចំណែកទ្រទ្រង់ចិរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងបរិការណ៍នៃសមាហរណកម្មសេដ្ឋកិច្ច តំបន់ និងសកលលោក។ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលមានគោលនយោបាយ និងទិសដៅច្បាស់លាស់ក្នុងការធានាឱ្យបាននូវកម្រិតសមត្ថភាព, ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានថ្នាក់ជាតិ-អន្តរជាតិ និងប្រព័ន្ធនាំផ្លូវអាកាសឱ្យបានគ្រប់គ្រាន់ស្របទៅតាមតម្រូវការ ដោយធានាបាននូវការប្រើប្រាស់សមត្ថភាពជាអតិបរមា និងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាពនូវហេដ្ឋារចនាសម្ព័ន្ធ ទាំងនោះតាមរយៈបង្កើនការចូលរួមពីវិស័យឯកជន។

ការចូលរួមពីដៃគូរឯកជន-រដ្ឋ (Public Private Partnership-PPP) បានក្លាយទៅជាយុទ្ធសាស្ត្រមូលដ្ឋានក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មអាកាសចរស៊ីវិលនៅកម្ពុជា។ កន្លងមកការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិមួយចំនួន ត្រូវបានរាជរដ្ឋាភិបាលធ្វើសម្បទានឱ្យទៅក្រុមហ៊ុនឯកជនក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) តាមទម្រង់សាងសង់-អាជីវកម្ម-ផ្ទេរ/BOT។ ជាក់ស្តែងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានចំនួន២ បាននឹងកំពុងដំណើរការធុរកិច្ចរបស់ខ្លួនគឺ ១-ក្រុមហ៊ុនអាកាសយានដ្ឋានកម្ពុជា (Cambodia Airports/SCA) ដែលបានគ្រប់គ្រង និងចូលរួមក្នុងការអភិវឌ្ឍន៍

ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ ក្រោមទម្រង់វិនិយោគ សាងសង់-អាជីវកម្ម-ផ្ទេរ (BOT) លើហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានដែលមានស្រាប់ (brownfield) ដែលរយៈពេលសម្បទានសម្រាប់អាកាសយានដ្ឋានអន្តរជាតិទាំង៣ សរុប ៤៥ឆ្នាំ (ពីឆ្នាំ១៩៩៥-២០៤០) ២-ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិអង្គរថ្មី (Angkor International Airport Investment (Cambodia Co.,Ltd) ដែលទទួលបានសិទ្ធិក្នុងការគ្រប់គ្រង និងចូលរួមក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិអង្គរថ្មី ក្រោមទម្រង់វិនិយោគ សាងសង់-អាជីវកម្ម-ផ្ទេរ (BOT) កសាងហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិថ្មី (greenfield) លើផ្ទៃដីទំហំ ៧០០ហិកតា ដើម្បីប្រើប្រាស់សម្រាប់អភិវឌ្ឍ អាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ ដែលមានរយៈពេលវិនិយោគចំនួន៥៥ឆ្នាំ (ពីឆ្នាំ២០១៦-២០៧១) ដោយប្រើប្រាស់ទុនវិនិយោគចំនួនប្រមាណ ៨៨០ លាន ដុល្លារ ដោយសម្បទានិកចិន និង ៣-ក្រុមហ៊ុន ខេមបូឌា អ៊ែរផត អ៊ិនវេសមិន (Cambodia Airport Investment) បានទទួលសិទ្ធក្នុងការគ្រប់គ្រង និងចូលរួមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី (Greenfield) លើផ្ទៃដីចំនួន ១២០០ ហិកតា ដែលប្រើប្រាស់ទុនវិនិយោគចំនួន ១ ៥០០ លានដុល្លារ ក្នុងនោះរដ្ឋាភិបាលបានទទួលភាគហ៊ុនចំនួន ១០ ភាគរយ ។

ចំពោះសេវាកម្មនាំផ្លូវអាកាស ត្រូវបានរាជរដ្ឋាភិបាលប្រគល់សិទ្ធវិនិយោគជូនក្រុមហ៊ុនសេវាកម្មចរាចរដែនអាកាស កម្ពុជា (CATS) ក្រោមរូបភាព សាងសង់-ប្រតិបត្តិការ-ផ្ទេរ (BCT) ដែលមានរយៈពេល៣៩ឆ្នាំ គិតចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០៤១ ដែលគ្រប់គ្រង និងទំនើបកម្មបច្ចេកវិទ្យាឧបករណ៍នាំផ្លូវអាកាស ដោយក្រុមហ៊ុនសេវាកម្មចរាចរដែនអាកាសកម្ពុជា (CATS)។

ក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជា-អង្គរ (Cambodia Angkor Air) ក៏ត្រូវបានបង្កើតឡើងរវាងក្រុមហ៊ុនអាកាសចរណ៍វៀតណាម ៤៩ ភាគរយ រាជរដ្ឋាភិបាលកម្ពុជា ២៦ ភាគរយ និងវិនិយោគិនក្នុងស្រុក ២៥ ភាគរយ។ ក្រុមហ៊ុនអាកាសចរណ៍ឯកជនក្នុងស្រុកចំនួន៧ បាននឹងកំពុងប្រតិបត្តិការហោះហើរដឹកជញ្ជូនអ្នកដំណើរ និងទំនិញ ដូចជា៖ ១) ក្រុមហ៊ុនអាកាសចរណ៍ Cambodia Angkor Air ២) ក្រុមហ៊ុនអាកាសចរណ៍ Sky Angkor Airlines ៣) ក្រុមហ៊ុនអាកាសចរណ៍ JC Cambodia Airlines ៤) ក្រុមហ៊ុនអាកាសចរណ៍ Lanmier Airlines ៥) ក្រុមហ៊ុនអាកាសចរណ៍ Cambodia Airways ៦) ក្រុមហ៊ុនអាកាសចរណ៍ HELISTAR (Cambodia) ៧) ក្រុមហ៊ុនអាកាសចរណ៍ Cambodia Hellicopter។

ជាមួយគ្នានេះ ក្រុមហ៊ុនអាកាសចរណ៍មួយចំនួនទៀតបាននឹងកំពុងបំពេញនីតិវិធី ដើម្បីស្នើសុំវិញ្ញាបនប័ត្រប្រតិបត្តិការហោះហើរ (AOC) ពីរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចជា៖ ក្រុមហ៊ុន Air Siem Reap, ក្រុមហ៊ុន Cambodia MJ Airlines, ក្រុមហ៊ុន Damrey Airlines ជាដើម ដើម្បីដំណើរការហោះហើរដឹកជញ្ជូនអ្នកដំណើរ និងទំនិញក្នុងស្រុក និងក្រៅស្រុក។

ការចូលរួមក្នុងភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) បានបង្ហាញពីសញ្ញាវិជ្ជមានមួយសម្រាប់ជម្រុញឱ្យមានកំណើន និងទ្រទ្រង់ចិរភាពនៃកំណើនសេដ្ឋកិច្ចកម្ពុជារយៈពេលវែង ជាពិសេសបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងបរិការណ៍នៃសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក។

ចំពោះគម្រោង និងទិសដៅអភិវឌ្ឍសាងសង់ ស្តារ និងកែលម្អអាកាសយានដ្ឋានរបស់កម្ពុជាក្នុងរយៈពេលកន្លងមកនេះមានការវិវត្តគួរឱ្យកត់សំគាល់ ក្នុងនោះយើងមាន៖

- គម្រោងសាងសង់អាកាសយានដ្ឋានថ្មីនៅខេត្តសៀមរាប អាកាសយានដ្ឋានថ្មីនៅភ្នំពេញ អាកាសយានដ្ឋានថ្មីនៅខេត្តកោះកុង (តារាសាគរ) និងអាកាសយានដ្ឋានបន្ទាប់បន្សំ ដូចជា នៅប៉ោយប៉ែត នៅកោះកុង (អាកាសយានដ្ឋានបច្ចុប្បន្នក្រុងខេមរៈភូមិន្ទ) និងនៅតំបន់ភូមិភាគឥសាន (ខេត្តមណ្ឌលគីរី ឬខេត្តស្ទឹងត្រែង ឬខេត្តរតនគីរី) ។ល។
- យោងតាមការព្យាករណ៍អ្នកដំណើរតាមផ្លូវអាកាសសម្រាប់រយៈពេលវែង គឺនៅក្នុងឆ្នាំ២០២០ កម្ពុជានឹងទទួលបានអ្នកដំណើរតាមផ្លូវអាកាសចំនួន៨ (រាប់តែម្ខាង) លាននាក់ និងនៅឆ្នាំ២០៣០ មានចំនួនរហូតដល់ទៅ ១៥ លាននាក់ (រាប់តែម្ខាង)។
- ដូច្នេះការអភិវឌ្ឍន៍ ការស្តារ និងកែលម្អអាកាសយានដ្ឋានទាំងថ្មី ទាំងចាស់នៅក្នុងប្រទេសកម្ពុជា គឺធ្វើឡើងស្របទៅតាមកំណើន និងការព្យាករណ៍ខាងលើ ក្នុងនោះយើងក៏ត្រូវការកែលម្អរ និងធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងចរាចរណ៍ដែនអាកាសឱ្យស្របទៅតាមកំណើននេះផងដែរ។
- ការប៉ាន់ស្មានទុនវិនិយោគសរុបសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន និងប្រព័ន្ធគ្រប់គ្រងចរាចរណ៍ដែនអាកាស (ទាំងផ្នែកទន់ និងផ្នែករឹង) គឺមានចំនួនជាង ៣ ៧៤៨លានដុល្លារអាមេរិក សម្រាប់រយៈពេល៥ឆ្នាំ (២០១៨-២០២៣)។ ការអភិវឌ្ឍន៍ទាំងនេះ គឺបានដោយសារការចូលរួមក្នុងភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP-Public Private Partnership) ដែលជាកត្តាវិជ្ជមានមួយសម្រាប់ជម្រុញឱ្យមានកំណើនសេដ្ឋកិច្ចកម្ពុជារយៈពេលវែង ជាពិសេសបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងការដឹកជញ្ជូនអ្នកដំណើរ និងទំនិញ (ក្នុងស្រុក និងក្រៅស្រុក) តាមផ្លូវអាកាសរបស់កម្ពុជាក្នុងបរិការណ៍នៃសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក។

## ១២. វឌ្ឍនភាពផ្នែកសន្តិសុខអាកាសចរស៊ីវិល

សន្តិសុខអាកាសចរស៊ីវិលគឺ ជាផ្នែកមួយដែលដើរតួនាទីសំខាន់ដើម្បីធានាដល់សុវត្ថិភាពរបស់អាកាសយាន និងសុវត្ថិភាពរបស់អ្នកដំណើរតាមផ្លូវអាកាស ទាំងនៅក្នុងបរិវេណអាកាសយានដ្ឋានស្ថានីយ៍អ្នកដំណើរ និងនៅលើអាកាសយាន។ ដើម្បីអនុវត្តសកម្មភាពការងារឱ្យស្របតាមស្តង់ដា និងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ និងដើម្បីសម្រួលដល់កិច្ចការពារសន្តិសុខអាកាសចរស៊ីវិលនៅកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានរៀបចំនូវបទបញ្ញត្តិ នីតិវិធី ស្តង់ដារ តម្រូវការ កម្មវិធី សៀវភៅណែនាំមួយចំនួនដែលទាក់ទងនឹងវិធានការសន្តិសុខ និងការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ឱ្យស្របតាបតាមស្តង់ដារបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ ជាពិសេសគឺប្រព័ន្ធជាតិត្រួតពិនិត្យសន្តិសុខអាកាសចរស៊ីវិលនៅកម្ពុជា ដែលរួមមានដូចខាងក្រោម៖

- កម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល (National Civil Aviation Security Programme)
- កម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខអាកាសចរស៊ីវិល (National Civil Aviation Security Quality Control Programme)
- កម្មវិធីជាតិបណ្តុះបណ្តាលសន្តិសុខអាកាសចរស៊ីវិល (National Civil Aviation Security Training Programme)
- កម្មវិធីជាតិសម្របសម្រួលដឹកជញ្ជូនផ្លូវអាកាស (National Air Transport Facilitation Programme)
- កម្មវិធីសន្តិសុខអាកាសយានដ្ឋាន (Airport Security Programme)
- កម្មវិធីប្រតិបត្តិករសន្តិសុខអាកាសយាន (Aircraft Operator Security Programme)។

ជាក់ស្តែងឆ្នាំ២០១៨ នេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានរៀបចំកម្មវិធីបណ្តុះបណ្តាល និងបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីសន្តិសុខ មន្ត្រីតាមបណ្តាក្រសួង-ស្ថាប័ននានា និងក្រុមហ៊ុនឯកជនមួយចំនួនដែលពាក់ព័ន្ធនឹងការអនុវត្តការងារជាក់ស្តែងនៅតាមបណ្តាអាកាសយានដ្ឋានអន្តរជាតិទាំង៣ បានចំនួន៥វគ្គ ក្នុងនោះវគ្គសិក្សាកម្រិតបឋមចំនួន៣វគ្គ និងវគ្គប្រើប្រាស់ម៉ាស៊ីន x-Ray ចំនួន២វគ្គ។ ទន្ទឹមនឹងនេះដែរ បន្ទាប់ពីទទួលរងសវនកម្មពីអង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO USAP Audit) ដែលបានមកធ្វើសវនកម្មលើផ្នែកសន្តិសុខអាកាសចរស៊ីវិល ពីថ្ងៃទី២០-២៨ ខែតុលា ឆ្នាំ២០១៦ ក្រុមការងារបច្ចេកទេស ICAO USOAP / USAP-CMA របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានធ្វើការដោះស្រាយនូវបញ្ហាមួយចំនួន ដែលបានរកឃើញដោយក្រុមសវនកររបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ ដូចជាកង្វះខាតបទដ្ឋានគតិយុត្តិ ធនធានមនុស្ស និងវិធានការការពារសន្តិសុខអាកាសចរស៊ីវិលនៅ តាមបណ្តាអាកាសយានដ្ឋាន ក៏ដូចជានៅតាមអាកាសយាន។ ជាមួយគ្នានេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានរៀបចំបើកសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិលដល់ក្រសួង-ស្ថាប័ន និងប្រតិបត្តិករអាកាសចរស៊ីវិលនានា។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពនូវកម្មវិធីសន្តិសុខអាកាសចរស៊ីវិល ពិនិត្យកែសម្រួលកម្មវិធីភាពអាសន្នអាកាសយានដ្ឋានភ្នំពេញ និងកម្មវិធីសន្តិសុខអាកាសយានដ្ឋានខេត្តព្រះសីហនុ ព្រមទាំងបទដ្ឋានគតិយុត្តិមួយចំនួនទៀត សម្រាប់អនុវត្តការងារប្រចាំថ្ងៃនៅនាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល និងតាមបណ្តាប្រតិបត្តិករអាកាសចរនានាដែលពាក់ព័ន្ធនឹងការផ្តល់សេវាកម្មអាកាសចរស៊ីវិលនៅកម្ពុជា។

ទិសដៅបន្តសម្រាប់ឆ្នាំ២០២០ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានរៀបចំផែនការសកម្មភាពអាទិភាពមួយចំនួន ដើម្បីសម្រេចគោលបំណងគោលនយោបាយ ដែលរួមមានៈ ១- ពិនិត្យកែសម្រួលកម្មវិធីជាតិបណ្តុះបណ្តាលសន្តិសុខអាកាសចរស៊ីវិល និងកម្មវិធីបណ្តុះបណ្តាលសន្តិសុខអាកាសយានដ្ឋាន ២-ចុះត្រួតពិនិត្យកម្មវិធីសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ និងផែនការភាពអាសន្នអាកាសយានដ្ឋាន ៣-រៀបចំបើកវគ្គបណ្តុះបណ្តាលសន្តិសុខអាកាសចរស៊ីវិលមួយចំនួនបន្ថែមទៀតដល់មន្ត្រីរាជការ ក៏ដូចជាបុគ្គលិកប្រតិបត្តិករអាកាសចរស៊ីវិល និង ៤-ចុះធ្វើអធិការកិច្ច វាយតម្លៃ និងធ្វើតេស្តការអនុវត្តការងារត្រួតពិនិត្យកម្មវិធីសន្តិសុខ និងគុណភាពសន្តិសុខរបស់ប្រតិបត្តិករអាកាសចរស៊ីវិល។

### ៣ - បញ្ហាប្រឈម (ដែលត្រូវយកចិត្តទុកដាក់ក្នុងឆ្នាំ២០១៩ និងឆ្នាំខាងមុខ)

ទន្ទឹមនឹងការរីកចម្រើនលើវិស័យអាកាសចរស៊ីវិលនៅកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនៅមានកត្តាប្រឈមមួយចំនួនដែលបានកើតឡើងពីការអនុវត្តថវិកាកម្មវិធី ហើយចាំបាច់ត្រូវមានដំណោះស្រាយដែលរួមមានដូចខាងក្រោមៈ

- នាយកដ្ឋាន និងអង្គភាពមួយចំនួននៅពុំទាន់បានចូលរួមសកម្មនៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាជាហេតុធ្វើឱ្យក្រុមការងារថវិកាជួបការលំបាកក្នុងការបូកសរុប និងរៀបចំកំណត់សូចនាករ និងគោលដៅសូចនាករសម្រាប់ធ្វើការវាស់វែងលទ្ធផលដែលសម្រេចបាន។
- អង្គភាពថវិកាជួបការលំបាកនៅក្នុងការប្រមូលរបាយការណ៍លទ្ធផលពីតាមបណ្តានាយកដ្ឋាន និងអង្គភាពមួយចំនួន ដើម្បីរៀបចំរបាយការណ៍សមិទ្ធកម្មជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- *កង្វះខាតថវិកាសម្រាប់ចំណាយលើការអភិវឌ្ឍស្ថាប័នគឺ មិនអាចបំពេញបានតាមតម្រូវការរបស់នាយកដ្ឋាន/អង្គភាព ដែលធ្វើឱ្យប៉ះពាល់ដល់ផែនការសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។*
- ផ្អែកតាមអនុសាសន៍ណែនាំរបស់សវនករអង្គការអាកាសចរស៊ីវិលអន្តរជាតិ សំណូមពរ *ត្រូវបង្កើតឱ្យមានថវិកាបម្រុងសម្រាប់ចុះប្រតិបត្តិការពេលមានគ្រោះថ្នាក់ ឬឧបទ្ទវហេតុយន្តហោះកើតឡើង។*
- ចំនួនក្រុមហ៊ុនអាកាសចរណ៍កើនឡើងពីមួយឆ្នាំទៅមួយឆ្នាំជាលំដាប់ ជាហេតុធ្វើឱ្យមានកង្វះខាតធនធានមនុស្ស (មន្ត្រីអធិការកិច្ច)លើវិស័យអាកាសចរស៊ីវិល សម្រាប់ដោះស្រាយបញ្ហាប្រឈម និងបន្តវេណដែលត្រូវការបណ្តុះបណ្តាលជាចាំបាច់។
- កង្វះខាតបទបញ្ញត្តិបច្ចេកទេស និងបទដ្ឋានគតិយុត្តមួយចំនួនរបស់វិស័យអាកាសចរស៊ីវិល ដែលចាំបាច់ត្រូវការរៀបចំ និងធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ ដើម្បីឱ្យស្របទៅតាមតម្រូវការ និងការវិវឌ្ឍន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) ដែលបទបញ្ញត្តិទាំងអស់នោះ រួមមានផ្នែកៈ LEG, ORG, AIR, PEL, OPS, DGs, ANS, AIG, AGA)
- ពុំទាន់មានអ្នកជំនាញការបរទេសគ្រប់គ្រាន់ មកជួយរៀបចំផែនការមេសម្រាប់អភិវឌ្ឍអាកាសចរស៊ីវិល (Master Plan for Civil Aviation) និងបទបញ្ញត្តិបច្ចេកទេសទាំង៩ផ្នែក ព្រមទាំងនីតិវិធីនានាលើវិស័យអាកាសចរស៊ីវិល
- ពុំមានថវិកាគ្រប់គ្រាន់សម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល ដូចជាៈ (ការជួសជុលផ្លូវរត់ ប៉មបញ្ជាហោះហើរ តបណ្តាញទឹក តបណ្តាញអគ្គិសនី ជួសជុលអគារស្ថានីអ្នកដំណើរ និងអគាររដ្ឋបាលជាដើម) ក៏ដូចជាការទិញឧបករណ៍សម្ភារៈបរិក្ខារបច្ចេកទេសមួយចំនួនសម្រាប់បម្រើឱ្យការងារផ្តល់សេវាកម្មឧតុនិយម រុករក និងសង្គ្រោះស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍។

## ៤- វិធានការគោលនយោបាយសម្រាប់រួមចំណែកអនុវត្តអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងវិធានគោលនយោបាយដែលមានចរិតតាមវិស័យ និងអន្តរវិស័យ សម្រាប់ឆ្នាំ២០២០-២០២២

### ៤.១ គោលនយោបាយសម្រាប់អាណត្តិទី៦ (២០១៨-២០២៣)

សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសនៃព្រះរាជាណាចក្រកម្ពុជា នឹងចូលរួមធ្វើអតិបរមានីយកម្មផលប្រយោជន៍សេដ្ឋកិច្ចដល់ព្រះរាជាណាចក្រកម្ពុជា រួមទាំងវិស័យពាណិជ្ជកម្ម និងទេសចរណ៍ ដោយមានសង្គតិភាពជាមួយគោលនយោបាយថ្នាក់អន្តរជាតិ និងតំបន់។ ក្នុងមូលហេតុនេះ ព្រះរាជាណាចក្រកម្ពុជានឹងខិតខំធ្វើការរៀបចំឱ្យមានសេវាកម្មដឹកជញ្ជូនផ្លូវអាកាសមួយដែលមានលក្ខណៈទន់ភ្លន់ បត់បែន និងមានសនិទានកម្មត្រឹមត្រូវបំផុតជាមួយនឹងបណ្តាប្រទេសនានានៅក្នុងតំបន់ និងក្រៅតំបន់តាមដែលអាចធ្វើទៅបានដើម្បីជាមធ្យោបាយមួយក្នុងការបង្កើនបានកម្រិតប្រសើរបំផុតទាំងបរិមាណ គុណភាព និងការរីកចម្រើនទៅមុខក្នុងសេវាកម្មដឹកជញ្ជូនផ្លូវអាកាសទាំងកម្រិតជាតិ និងអន្តរជាតិ ។

គោលនយោបាយជាតិនេះ បានដើរតួនាទីយ៉ាងសំខាន់ និងជាគន្លឹះនៅក្នុងការគាំទ្រដល់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ដែលមានវិសាលភាពធំៗក្នុងការពង្រឹងទំនាក់ទំនងទាំងក្នុង

និងក្រៅប្រទេស ដើម្បីជម្រុញកំណើនសេដ្ឋកិច្ច និងលើកទឹកចិត្តដល់សហគ្រាសនានាក៏ដូចជាការបង្កើតគំនិតថ្មីៗ ដែលធ្វើឱ្យសម្រេចបាននូវសេដ្ឋកិច្ចមួយដែលបើកទូលាយមានសន្ទុះទៅមុខ និងមានការធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌអន្តរជាតិ។

**៤.២ វិធានការគោលនយោបាយដែលមានចរិតតាមវិស័យ និងអន្តរវិស័យសម្រាប់ឆ្នាំ២០២០-២០២២**

ដើម្បីចូលរួមអនុវត្តគោលនយោបាយបើកចំហរជើងមេឃ (Open Sky) របស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាល ទី៦ នៃរដ្ឋសភា ព្រមទាំងដើម្បីពង្រឹងគុណភាពសេវាកម្មអាកាសចរស៊ីវិល រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានវិធានការគោលនយោបាយសម្រាប់អនុវត្តសកម្មភាពអាទិភាពដូចខាងក្រោម៖

**ពង្រឹងគុណភាពសេវាកម្មអាកាសចរស៊ីវិលកម្ពុជា ដើម្បីធានាបាននូវសន្តិសុខ សុវត្ថិភាព ប្រសិទ្ធិភាព និងចូលរួមការពារបរិស្ថានសម្រាប់ប្រតិបត្តិការដឹកជញ្ជូនអ្នកដំណើរ និងទំនិញតាមផ្លូវអាកាសជានិរន្តរ៍។**

**៤.៣ វិធានការបង្កើនប្រសិទ្ធភាពចំណាយ**

ដើម្បីចូលរួមចំណែកអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ជាពិសេសគឺកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖

- បង្កើនការរៀបចំថវិកាឱ្យកាន់តែផ្សារភ្ជាប់ទៅនឹងគោលនយោបាយ តាមរយៈការបង្កើនប្រសិទ្ធភាពនៃការវិភាជ ថវិកាឱ្យកាន់តែមានមូលដ្ឋានច្បាស់លាស់ និងចំទិសដៅ
- ពង្រឹងការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ និងការជ្រើសរើសមន្ត្រីរាជការ ពិសេសបុគ្គលិកជាប់កិច្ចសន្យា
- ពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃការប្រើប្រាស់ប្រាក់រង្វាន់ពីកម្រៃសេវាសាធារណៈសម្រាប់លើកទឹកចិត្តមន្ត្រីរាជការ និងសម្រាប់គាំទ្រការពង្រឹងយន្តការប្រមូលចំណូល
- លើកកម្ពស់ប្រសិទ្ធភាពបច្ចេកទេស និងប្រតិបត្តិការចំណាយរវាងអង្គភាពថវិកា និងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ
- រឹតត្បិតចំពោះមុខសញ្ញាចំណាយណាដែលមិនចាំបាច់ ឬមិនអាទិភាពរបស់នាយកដ្ឋាន និងអង្គភាពមួយចំនួន ដើម្បីសន្សំថវិកាយកទៅអនុវត្តសកម្មភាពអាទិភាពរបស់នាយកដ្ឋានផ្សេង ដែលមានតម្រូវការចាំបាច់ និងបន្ទាន់
- បន្តអនុវត្តឱ្យមានប្រសិទ្ធភាព និងតម្លាភាពនូវការងារលទ្ធកម្ម និងពង្រឹងការអនុវត្តនីតិវិធីលទ្ធកម្មជាធរមាន។

## II. គោលបំណងគោលនយោបាយ

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយតាមវិស័យ ពិសេសគោលនយោបាយរួមរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បី **កំណើន ការងារ សមធម៌** និង**ប្រសិទ្ធភាព** សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ និងដើម្បីសម្រេចបានគោលបំណង និងទិសដៅខាងលើឱ្យ

ទទួលបានជោគជ័យ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានបង្កើតគោលនយោបាយចំនួន១សម្រាប់ជាចក្ខុវិស័យរយៈពេលមធ្យម និងវែងគឺ **លើកកម្ពស់គុណភាពសេវាកម្ម និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល ដើម្បីធានាសុវត្ថិភាព និងសន្តិសុខសម្រាប់ប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាស។**

គោលនយោបាយខាងលើនេះ ត្រូវបានរៀបចំឡើងក្នុងបរិបទដែលវិស័យអាកាសចរស៊ីវិលពិភពលោកកំពុងតែមានការរីកចំរើនយ៉ាងឆាប់រហ័ស និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ច-សង្គមជាសកលក្នុងការគាំទ្រដល់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល ដែលមានវិសាលភាពធំៗក្នុងការពង្រឹងទំនាក់ទំនងទាំងក្នុង និងក្រៅប្រទេស ជម្រុញកំណើនសេដ្ឋកិច្ច និងលើកទឹកចិត្តដល់សហគ្រាសនានាក៏ដូចជាបង្កើតគំនិតថ្មីៗដែលធ្វើឱ្យសម្រេចបាននូវសេដ្ឋកិច្ចមួយដែលបើកទូលាយមានសន្ទុះទៅមុខ និងមានការធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌអន្តរជាតិ។ ជាពិសេសគោលបំណងខាងលើនេះ គឺស្របទៅនឹងគោលនយោបាយបើកចំហរជើងមេឃរបស់រាជរដ្ឋាភិបាល។

**គោលបំណងគោលនយោបាយ គឺ:**

ដើម្បីធានាបាននូវសណ្តាប់ធ្នាប់ និងធានាសុវត្ថិភាពប្រតិបត្តិការអាកាសចរស៊ីវិល ការគ្រប់គ្រងសេវាកម្មចរាចរដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា ធានាសុវត្ថិភាពអាកាសយាន ព្រមទាំងការគ្រប់គ្រង និងអភិវឌ្ឍអាកាសយានដ្ឋានស៊ីវិល និងជម្រុញឱ្យមានការអភិវឌ្ឍន៍ក្នុងវិស័យដឹកជញ្ជូនតាមផ្លូវអាកាសប្រកបដោយសុវត្ថិភាព ទំនុកចិត្ត និងមានលក្ខណៈសេដ្ឋកិច្ច ជាពិសេសធានាបាននូវការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល សុវត្ថិភាព សន្តិសុខ និងការការពារបរិស្ថានតាមស្តង់ដារអន្តរជាតិ ប្រកបដោយសក្តិសិទ្ធភាព ប្រសិទ្ធិភាពនៃសេវាកម្មដឹកជញ្ជូនផ្លូវអាកាស រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលមានគោលបំណងគោលនយោបាយ ជាមូលដ្ឋានដូចខាងក្រោម:

| គោលបំណងគោលនយោបាយ | បម្រើឱ្យគោលដៅយុទ្ធសាស្ត្រណាមួយ និងវិធានការគោលនយោបាយអ្វីខ្លះនៃយុទ្ធសាស្ត្រចតុកោណ | ស្ថិតនៅក្នុងវិស័យណាមួយ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
|---|---|---|
| លើកកម្ពស់គុណភាពសេវាកម្មនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល ដើម្បីធានាសុវត្ថិភាព និងសន្តិសុខសម្រាប់ប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាស | ចតុកោណទី២ មុំទី១៖ ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ | វិស័យដឹកជញ្ជូនតាមផ្លូវអាកាស ធុរៈកិច្ច និងសេវាកម្មទេសចរណ៍ |

## III. ការរៀបចំកម្មវិធី

ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើឱ្យទទួលបានជោគជ័យ និងសម្រេចបានទិសដៅយុទ្ធសាស្ត្រដែលបានបង្កើតឡើង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានរៀបចំកម្មវិធី ចំនួន២ មានដូចខាងក្រោម៖

## ១- ការពង្រឹង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល

**គោលបំណងនៃកម្មវិធី៖** ដើម្បីធានានូវសុវត្ថិភាព សន្តិសុខ បរិស្ថាន ប្រសិទ្ធភាពជានិរន្តរសម្រាប់ការធ្វើដំណើរ និងការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសក្នុងកម្រិតបទដ្ឋានអន្តរជាតិ។

ដើម្បីសម្រេចបាននូវគោលបំណងនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនឹងត្រូវផ្តោតសកម្មភាពជាអាទិភាពលើ៖

- ការលម្អសុវត្ថិភាព និងសន្តិសុខអាកាសចរស៊ីវិលៈ ពង្រឹង និងកែលម្អលក្ខខ័ណ្ឌបច្ចេកទេសលើប្រព័ន្ធសុវត្ថិភាពហោះហើរ និងលទ្ធភាពហោះហើររបស់ក្រុមហ៊ុនដែលបានស្នើសុំអភិវឌ្ឍន៍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសុវត្ថិភាពនាំផ្លូវអាកាស និងអាកាសយានដ្ឋានស៊ីវិលនៅកម្ពុជា ព្រមទាំងពង្រឹងតាមដាន និងត្រួតពិនិត្យលើប្រតិបត្តិករសន្តិសុខអាកាសយានដ្ឋាន និងក្រុមហ៊ុនសន្តិសុខឯកជន សំដៅធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងផ្តល់សេវាកម្មអាកាសចរស៊ីវិល និងកាត់បន្ថយនូវហានិភ័យខ្ពស់ពីគ្រោះថ្នាក់អាកាសចរដែលអាចកើតមានឡើងជាយថាហេតុ។
- ការត្រួតពិនិត្យសុវត្ថិភាព និងសន្តិសុខអាកាសចរស៊ីវិលៈ ដើម្បីធានាដល់សុវត្ថិភាពនិងសន្តិសុខចំពោះអ្នកដំណើរតាមផ្លូវអាកាស ចាំបាច់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលត្រូវធ្វើការត្រួតពិនិត្យលើប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ និងត្រួតពិនិត្យលើការងារសន្តិសុខអាកាសចរស៊ីវិល។
- ការផ្តល់សេវាកម្មអាកាសចរស៊ីវិលៈដើម្បីជម្រុញឱ្យមានកំណើនជាបន្តនៃការដឹកជញ្ជូនតាមផ្លូវអាកាស រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលត្រូវគ្រប់គ្រងនិងចាត់ចែងផ្តល់សេវាកម្មនាំផ្លូវអាកាសចេញ-ចូល និងឆ្លងកាត់ដែនអាកាសផ្តល់សេវាកម្មចុះចតជាលក្ខណៈឯកជន ផ្តល់សេវាកម្មរុករកសង្គ្រោះ បន្ទាន់ និងពន្លត់អគ្គីភ័យសម្រាប់យន្តហោះស្ថិតនៅក្នុងភាពគ្រោះថ្នាក់ក្នុងតំបន់ពត៌មានហោះហើរ ភ្នំពេញ (FIR)។

## ២- ការពង្រឹងស្ថាប័ន និងបង្កើនប្រសិទ្ធភាពសេវាគាំទ្រ

**គោលបំណងនៃកម្មវិធី៖** ដើម្បីបង្កើនប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៅក្នុងការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ការអភិវឌ្ឍន៍វិស័យអាកាសចរស៊ីវិលប្រកបដោយនិរន្តរភាព។

ដើម្បីសម្រេចបាននូវគោលបំណងនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនឹងត្រូវផ្តោតសកម្មភាពជាអាទិភាពលើ៖

- ការពង្រឹងស្ថាប័នៈ ជម្រុញការគ្រប់គ្រងអង្គភាពជំនាញក្រោមឱវាទរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ី វិល ឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តគោលនយោបាយ សម្រាប់អភិវឌ្ឍវិស័យអាកាសចរស៊ីវិលប្រកបដោយចីរភាព។
- ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រៈ ការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព ភាពសក្តិសិទ្ធិក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញ បង្កើនសមត្ថភាពកសាង និងអនុវត្តផែនការយុទ្ធសាស្ត្រ ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និងឯកជន កិច្ចការទំនាក់ទំនងអន្តរជាតិ និងនីតិកម្ម ព្រមទាំងផ្សព្វផ្សាយ និង

ជម្រុញការហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍បរទេស និងក្នុងស្រុក និងពង្រីកសកម្មភាពចរចាកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាលក្ខណៈទ្វេភាគី និងពហុភាគីក្នុងតំបន់ អាស៊ាន និងដៃគូរអាស៊ាន។

- ការអភិវឌ្ឍន៍ធនធានមនុស្សៈ បង្កើនចំណេះដឹងផ្នែកបច្ចេកទេស និងជំនាញអាកាសចរស៊ីវិលពាក់ព័ន្ធនានា សំដៅពង្រឹង និងពង្រីកធនធានមនុស្សក្នុងវិស័យអាកាសចរស៊ីវិល ដើម្បីឆ្លើយតបតាមបទដ្ឋានគតិយុត្តិដែលមានស្រាប់របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងលក្ខខ័ណ្ឌតម្រូវការរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ(ICAO)។

| តារាង ១ : កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវ | | | |
|---|---|---|---|
| ឈ្មោះ គោលបំណង គោលនយោបាយ | ឈ្មោះ កម្មវិធី និង អនុកម្មវិធី | **អ្នកគ្រប់គ្រង** | **អង្គភាពទទួលខុសត្រូវ** |
| **គោលបំណងគ.ប ទី១:** **ធានាសុវត្ថិភាព សន្តិសុខ បរិស្ថាន អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង សេវាកម្មអាកាសចរស៊ីវិលប្រកប ដោយគុណភាព ប្រសិទ្ធភាព និង និរន្តរភាព នៃប្រតិបត្តិការដឹកជញ្ជូន តាមផ្លូវអាកាស** | **កម្មវិធីទី១: ការពង្រឹងសុវត្ថិភាព សន្តិសុខ បរិស្ថាន និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល** | **អគ្គនាយក** | **អគ្គនាយកដ្ឋានបច្ចេកទេស** |
| | ○ **អនុកម្មវិធីទី១**: ការកែលម្អសុវត្ថិភាព សន្តិសុខ និង បរិស្ថានអាកាសចរស៊ីវិល | ប្រធាននាយកដ្ឋាន | - នាយកដ្ឋាស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន<br>- នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ<br>- នាយកដ្ឋានលទ្ធភាពហោះហើរ<br>- នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពនាំផ្លូវអាកាស<br>- នាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល<br>- នាយកដ្ឋានអាជ្ញាប័ណ្ណបុគ្គលិក |
| | ○ **អនុកម្មវិធីទី២**: ការត្រួតពិនិត្យ និងធ្វើសវនកម្មផ្នែកសុវត្ថិភាព សន្តិសុខ និងបរិស្ថានអាកាសចរស៊ីវិល | ប្រធាននាយកដ្ឋាន | - នាយកដ្ឋានត្រួតពិនិត្យសន្តិសុខ និង សុវត្ថិភាពអាកាសចរណ៍<br>- អង្គភាពស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍ |
| | ○ **អនុកម្មវិធីទី៣**: ការផ្តល់សេវាកម្មអាកាសចរស៊ីវិលប្រកបដោយ ប្រសិទ្ធភាព និងសក្តិសិទ្ធភាព | ប្រធាននាយកដ្ឋាន | - នាយកដ្ឋានសេវាកម្មអាកាសចរណ៍ |
| | **កម្មវិធីទី២: ការពង្រឹងស្ថាប័ន និង ការអភិវឌ្ឍធនធានមនុស្ស ព្រមទាំង បង្កើនប្រសិទ្ធភាពសេវាគាំទ្រ** | **អគ្គនាយក** | **អគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ** |
| | ○ **អនុកម្មវិធីទី១**: ការពង្រឹងស្ថាប័ន និងអភិបាលកិច្ច | ប្រធាននាយកដ្ឋាន | - នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស<br>- មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល |

| | | | |
|---|---|---|---|
| | ○ **អនុកម្មវិធីទី២:** សេវាគាំទ្រ និង ការចូលរួម | ប្រធាននាយកដ្ឋាន | - នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ<br>- នា.ផែនការ យុទ្ធសាស្ត្រ និងគោលនយោបាយ<br>- នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស<br>- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងនីតិកម្ម<br>- អាកាសយានដ្ឋានអន្តរជាតិទាំង៣<br>- អាកាសយានដ្ឋានក្នុងស្រុកទាំង៣ |

## IV. ការកំណត់សូចនាករ និងគោលដៅសូចនាករ

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានកំណត់នូវសូចនាករ និងគោលដៅសូចនាករ ដើម្បីតាមដានវឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តកម្មវិធី និងគោលបំណងគោលនយោបាយនីមួយៗ ដូចខាងក្រោម:

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

**តារាង ២ : ការកំណត់សូចនាករ និងគោលដៅសូចនាករ នៃកម្មវិធី និងអនុកម្មវិធី**

| ឈ្មោះ គោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មវិធី | **សូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅ** | | | | **សូចនាករលទ្ធផលចុងក្រោយ និងគោលដៅ** | |
|---|---|---|---|---|---|---|
| | សូចនាករ | ឆ្នាំ២០១៨ (អនុវត្ត) | ឆ្នាំ២០១៩ (បច្ចុប្បន្ន) | ឆ្នាំ២០២០ (គ្រោង) | សូចនាករ | គោលដៅ |
| ○ **គោលបំណងគ.បទី១: ធានាសុវត្ថិភាព សន្តិសុខ បរិស្ថាន អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មអាកាសចរស៊ីវិលប្រកបដោយគុណភាព ប្រសិទ្ធភាព និងនិរន្តរភាព នៃប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាស** | -សុវត្ថិភាព សន្តិសុខ និងបរិស្ថានអាកាសចរស៊ីវិល នឹងត្រូវបានពង្រឹង និងកែលម្អស្របទៅតាមលក្ខខ័ណ្ឌបច្ចេកទេស និងស្តង់ដារបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) | -បានរៀបចំ កែលម្អ និងធ្វើបច្ចុប្បន្នកម្ម នូវប្រព័ន្ធសុវត្ថិភាព សន្តិសុខ និងបរិស្ថានអាកាសចរស៊ីវិល ដើម្បីឲ្យស្របតាមលក្ខខ័ណ្ឌបច្ចេកទេស និងស្តង់ដា របស់អង្គការ | -បាន និងកំពុងបន្តរៀបចំ កែលម្អ និងធ្វើបច្ចុប្បន្នកម្ម នូវប្រព័ន្ធសុវត្ថិភាព សន្តិសុខ និងបរិស្ថានអាកាសចរស៊ីវិល ដើម្បីឲ្យស្របតាមលក្ខខ័ណ្ឌបច្ចេកទេស និងស្តង់ដា | -នឹងបន្តកែលម្អ និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធសុវត្ថិភាព សន្តិសុខ និងបរិស្ថានអាកាសចរស៊ីវិល ដើម្បីឲ្យស្របតាមលក្ខខ័ណ្ឌបច្ចេកទេស និងស្តង់ដា របស់អង្គការ | រក្សាបាននូវសណ្តាប់ធ្នាប់ និងធានាសុវត្ថិភាពប្រតិបត្តិការសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសប្រកបដោយទំនុកចិត្ត ដល់ប្រតិបត្តិករ និងអ្នកដំ | ធានាបាននូវគុណភាព ប្រសិទ្ធភាព និងនិរន្តរភាពនៃប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាស |

| | | | | | | |
|---|---|---|---|---|---|---|
| | ដើម្បីធានាបាននូវគុណភាពនៃការគ្រប់គ្រង និងប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស | អាកាសចរស៊ីវិលអន្តរជាតិ (ICAO) ព្រមទាំងបង្កើននូវកិច្ចសហប្រតិបត្តិការសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស | របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) ព្រមទាំងបង្កើន នូវកិច្ចសហប្រតិបត្តិការសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស | អាកាសចរស៊ីវិលអន្តរជាតិ (ICAO) ព្រមទាំងបង្កើននូវកិច្ចសហប្រតិបត្តិការសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស | ណើរតាមផ្លូវអាកាស | |
| ▪ **កម្មវិធីទី១:** ការពង្រឹងសុវត្ថិភាព សន្តិសុខ បរិស្ថាន និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល | -រៀបចំផែនការ និងបណ្តុះបណ្តាល, ធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្តចំនួន ៦២, ត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើប្រតិបត្តិករ,ជួសជុលកែលម្អ និងថែទាំហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល (អាកាសយានដ្ឋាន ឧបករណ៍សម្ភារៈបរិក្ខាបច្ចេកទេស និងអគារលេអស) ជាប្រចាំតាមកម្មវិធី | -មន្ត្រីចំនួន ៤១២នាក់ បានបណ្តុះបណ្តាលជំនាញ និងបទដ្ឋានគតិយុត្តចំនួន ៧ច្បាប់ បានរៀបចំ និងធ្វើបច្ចុប្បន្នកម្ម, បានធ្វើការត្រួតពិនិត្យ និងអធិការកិច្ចលើប្រតិបត្តិករចំនួន ២៩, ហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិលមួយចំនួន បានជួសជុល កែលម្អ និងថែទាំតាមកម្មវិធី | -មន្ត្រីចំនួន ៤១២នាក់ បាននឹងកំពុងបណ្តុះបណ្តាលជំនាញ និងបទដ្ឋានគតិយុត្តចំនួន ២២ច្បាប់ បាននឹងកំពុងរៀបចំ និងធ្វើបច្ចុប្បន្នកម្ម, បាននឹងកំពុងធ្វើការ ត្រួតពិនិត្យ និងអធិការកិច្ចលើប្រតិបត្តិករចំនួន២២, ហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិលមួយចំនួន បាននឹងកំពុងជួសជុលកែលម្អ និងថែទាំតាមកម្មវិធី | -បន្តបណ្តុះបណ្តាលមន្ត្រីជំនាញចំនួន ១ ១១៩នាក់,បន្តរៀបចំ និងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្តចំនួន២១ ,បន្តធ្វើអធិការកិច្ចលើប្រតិបត្តិករចំនួន២១, បន្តជួសជុលកែលម្អ និងថែទាំហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិលមួយចំនួនតាមកម្មវិធី | -មន្ត្រីមាន សមត្ថភាព និងជំនាញសមល្មមសម្រាប់អនុវត្តការងារដោយអនុលោមតាមក្របខ័ណ្ឌបទដ្ឋានគតិយុត្ត សម្រាប់ត្រួតពិនិត្យតាមដាន និងធ្វើអធិការកិច្ចលើប្រតិបត្តិករអាកាសចរស៊ីវិល | សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសមានគុណភាពជាសកល និងប្រកបដោយសុវត្ថិភាព សន្តិសុខ និងបរិស្ថានអាចជឿទុកចិត្តបាន |
| ✓ **អនុកម្មវិធីទី១:** ការកែលម្អសុវត្ថិភាព សន្តិសុខ និងបរិស្ថានអាកាសចរស៊ីវិល | -បណ្តុះបណ្តាលមន្ត្រីជំនាញចំនួន ២០៥២នាក់ (កម្រិតជំនាញមូលដ្ឋាន, រក្សាជំនាញ និងបង្កើនសមត្ថភាពជំនាញ) | -បានបណ្តុះបណ្តាលមន្ត្រីជំនាញចំនួន ៤១២នាក់ (ក្នុងស្រុក ៣៦៣នាក់ និងក្រៅប្រទេស ៤៩នាក់) | -បាន និងកំពុងបន្តបណ្តុះបណ្តាលមន្ត្រីជំនាញចំនួន ៦១១នាក់ (ក្នុងស្រុក ៤៦៤នាក់ និងក្រៅប្រទេស ១៤៧នាក់) | -បន្តបណ្តុះបណ្តាលមន្ត្រីជំនាញចំនួន ១០២៩នាក់ (ក្នុងស្រុក ៧៩១នាក់ និងក្រៅប្រទេស ២៣៨នាក់) | -មន្ត្រីត្រូវបានបណ្តុះបណ្តាលស្របទៅតាមក្របខ័ណ្ឌបច្ចេកទេស និងលក្ខខណ្ឌតម្រូវការ | -រក្សាបាននូវសមត្ថភាព និងមានលទ្ធភាពក្នុងការផ្តល់ និងធានាបាននូវសុវត្ថិភាព សន្តិសុខ និងបរិស្ថានអាកាសចរស៊ីវិល |

| | | | | | | |
|---|---|---|---|---|---|---|
| | -រៀបចំ និងធ្វើបច្ចុប្បន្នកម្មលើ វិធាន បទបញ្ញត្តិ សៀវភៅណែនាំ នីតិវិធី តារាងត្រួតពិនិត្យកម្មវិធីប្រព័ន្ធសុវត្ថិភាព និងសន្តិសុខជាតិ និងបញ្ជីអនុលោមភាព ចំនួន ៦២ | -បានរៀបចំ និងធ្វើបច្ចុប្បន្នកម្មលើ វិធាន បទបញ្ញត្តិ សៀវភៅណែនាំ នីតិវិធី តារាងត្រួតពិនិត្យកម្មវិធីប្រព័ន្ធសុវត្ថិភាព និងសន្តិសុខជាតិ និងបញ្ជីអនុលោមភាព ចំនួន ២៩ | -បាន និងកំពុងរៀបចំ និងធ្វើបច្ចុប្បន្នកម្មលើ វិធាន បទបញ្ញត្តិ សៀវភៅណែនាំ នីតិវិធី តារាងត្រួតពិនិត្យកម្មវិធីប្រព័ន្ធសុវត្ថិភាព និងសន្តិសុខជាតិ និងបញ្ជីអនុលោមភាពចំនួន ២២ | -បន្តរៀបចំ និងធ្វើបច្ចុប្បន្នកម្មលើ វិធាន បទបញ្ញត្តិ សៀវភៅណែនាំ នីតិវិធី តារាងត្រួតពិនិត្យកម្មវិធីប្រព័ន្ធសុវត្ថិភាព និងសន្តិសុខជាតិ និងបញ្ជីអនុលោមភាព ចំនួន ២១ | -បន្តរៀបចំ និងធ្វើបច្ចុប្បន្នកម្មលើ វិធាន បទបញ្ញត្តិ សៀវភៅណែនាំ នីតិវិធី តារាងត្រួតពិនិត្យកម្មវិធីប្រព័ន្ធសុវត្ថិភាព និងសន្តិសុខជាតិ និងបញ្ជីអនុលោមភាពសមល្មម គ្រប់គ្រាន់ដែលអាចអនុវត្តបានតាមស្តង់ដា | -មានបទបញ្ញត្តិសមល្មម គ្រប់គ្រាន់ដែលអាចអនុវត្តបានតាមលក្ខខណ្ឌតម្រូវការ និងស្តង់ដា |
| | -កម្មវិធីត្រួតពិនិត្យ និងធ្វើអធិការកិច្ច (ក្នុងចន្លោះ) ចំនួន ៤០០លើក លើប្រតិបត្តិករអាកាសចរស៊ីវិលក្នុងប្រទេស និងក្រៅប្រទេស | -បានចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ច ចំនួន ៣២៤ លើក លើប្រតិបត្តិករអាកាសចរស៊ីវិលក្នុងប្រទេស និងក្រៅប្រទេស | -បាន និងបន្តចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ច ៣៣០ លើក លើប្រតិបត្តិករអាកាសចរស៊ីវិលក្នុងប្រទេស និងក្រៅប្រទេស | -បន្តចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ច ចំនួន ៣៣៥លើក លើប្រតិបត្តិករអាកាសចរស៊ីវិលក្នុងប្រទេស និងក្រៅប្រទេស | -ប្រតិបត្តិករអាកាសចរស៊ីវិលក្នុងប្រទេស និងក្រៅប្រទេសដែលមានកិច្ចព្រមព្រៀងនឹងត្រូវទទួលបានការធ្វើសវនកម្មពីរលេអស ជាប្រចាំ | -ភាពអនុលោម និងអភិក្រមនៃការតាមដានត្រួតពិនិត្យត្រូវបានអនុវត្តស្របតាមក្របខ័ណ្ឌបទបញ្ញត្តិលក្ខខណ្ឌតម្រូវការ និងស្តង់ដារ |
| | -ធ្វើការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល (អាកាសយានដ្ឋាន ឧបករណ៍សម្ភារៈបរិក្ខាបច្ចេកទេស និងអគារ | -បានធ្វើការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល (អាកាសយានដ្ឋាន ឧបករណ៍សម្ភារៈបរិក្ខា | -បាន និងកំពុងធ្វើការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល (អាកាសយានដ្ឋាន ឧបករណ៍សម្ភារៈបរិក្ខា | -បន្តធ្វើការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល (អាកាសយានដ្ឋាន ឧបករណ៍សម្ភារៈបរិក្ខាបច្ចេកទេស | -បន្តធ្វើការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល (អាកាសយានដ្ឋាន ឧបករណ៍សម្ភារៈ | -គុណភាព និងការផ្តល់សេវានៅក្នុងហេដ្ឋារចនាសម្ព័ន្ធទាំងនោះត្រូវបានធានាស្របទៅតាមលក្ខខណ្ឌតម្រូវការ |

| | | | | | | |
|---|---|---|---|---|---|---|
| | លេអស) ជាប្រចាំតាមកម្មវិធី | បច្ចេកទេស និងអគារ លេអស) ជាប្រចាំតាមកម្មវិធី | បច្ចេកទេស និងអគារ លេអស) ជាប្រចាំតាមកម្មវិធី | និងអគារ លេអស) ជាប្រចាំតាមកម្មវិធី | បរិក្ខាបច្ចេកទេស និង អគារ លេអស) ជាប្រចាំតាមកម្មវិធី | និងស្តង់ដារ |
| ✓ **អនុកម្មវិធីទី២:** ការត្រួតពិនិត្យ និងធ្វើសវនកម្ម ផ្នែកសុវត្ថិភាព សន្តិសុខ និងបរិស្ថានអាកាសចរស៊ីវិល | -សកម្មភាពលើការតាមដានត្រួតពិនិត្យ និងធ្វើសវនកម្ម(ក្នុងចន្លោះ) ចំនួន ៤០០លើក លើប្រតិបត្តិករអាកាសចរស៊ីវិលក្នុងប្រទេស និងក្រៅប្រទេស | -បានត្រួតពិនិត្យ និងធ្វើសវនកម្មចំនួន ៣២៤ លើក លើប្រតិបត្តិករអាកាសចរស៊ីវិលក្នុងប្រទេស និងក្រៅប្រទេស | -បាន និងកំពុងត្រួតពិនិត្យ និងធ្វើសវនកម្មចំនួន ៣៣០ លើក លើប្រតិបត្តិករអាកាសចរស៊ីវិលក្នុងប្រទេស និងក្រៅប្រទេស | -បន្តត្រួតពិនិត្យ និងធ្វើសវនកម្មចំនួន ៣៣៥ លើក លើប្រតិបត្តិករអាកាសចរស៊ីវិលក្នុងប្រទេស និងក្រៅប្រទេស | -ប្រតិបត្តិករអាកាសចរស៊ីវិលក្នុងប្រទេស និងក្រៅប្រទេសដែលមានកិច្ចព្រមព្រៀង នឹងត្រូវទទួលបានការធ្វើសវនកម្មពី លេអស ជាប្រចាំ | -ភាពអនុលោម និងអភិក្រមនៃការតាមដានត្រួតពិនិត្យត្រូវបានអនុវត្តស្របតាមក្របក្ខ័ណ្ឌបទបញ្ញត្តិលក្ខខណ្ឌតម្រូវការ និងស្តង់ដារ |
| ✓ **អនុកម្មវិធីទី៣:** ការផ្តល់សេវាកម្មអាកាសចរស៊ីវិលប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធភាព | -ការផ្តល់សេវាកម្មអាកាសចរស៊ីវិលទាំងឡាយជូនប្រតិបត្តិករ/អតិថិជនប្រកបដោយការទទួលខុសត្រូវ និងគុណតម្លៃ ដែលអាចជឿជាក់ និងទុកចិត្តបាន។ | -បានផ្តល់សេវាកម្មអាកាសចរស៊ីវិលជូនប្រតិបត្តិករ/អតិថិជនប្រកបដោយការទទួលខុសត្រូវ និងគុណតម្លៃដែលអាចជឿជាក់ និងទុកចិត្តបាន | -បាន និងកំពុងផ្តល់សេវាកម្មអាកាសចរស៊ីវិល ជូនប្រតិបត្តិករ/អតិថិជនប្រកបដោយការទទួលខុសត្រូវ និងគុណតម្លៃដែលអាចជឿជាក់ និងទុកចិត្តបាន | -បន្តផ្តល់សេវាកម្មអាកាសចរស៊ីវិលជូនប្រតិបត្តិករ/ អតិថិជន ប្រកបដោយការទទួលខុសត្រូវ និងគុណតម្លៃ ដែលអាចជឿជាក់ និងទុកចិត្តបាន | -បន្តផ្តល់សេវាកម្មអាកាសចរស៊ីវិលជូនប្រតិបត្តិករ/អតិថិជនប្រកបដោយការទទួលខុសត្រូវ និងគុណតម្លៃ ដែលអាចជឿជាក់ និងទុកចិត្តបាន | -ធានាបាននូវគុណភាពប្រសិទ្ធភាព និងសក្តិសិទ្ធភាព ក្នុងការផ្តល់សេវាកម្មអាអាកាសចរស៊ីវិលទាំងឡាយជូនប្រតិបត្តិករ/អតិថិជន |
| ▪ **កម្មវិធីទី២:** ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ព្រមទាំងបង្កើនប្រសិទ្ធភាពសេវាគាំទ្រ | -ប្រសិទ្ធភាពការងារ និងការគ្រប់គ្រង ត្រូវបានកែលម្អ | -សេចក្តីព្រាងលើអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ លេអស និងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានរៀបចំនិងចងក្រង សម្រេចបាន៤០%។ | -សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ លេអស បានសម្រេច១០០% និងកំពុងបន្តរៀបចំ កែសម្រួល និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍធនធានមនុស្ស សម្រេចបាន ៨០% ។ | -សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ លេអស នឹងធ្វើជូនរដ្ឋាភិបាលពិនិត្យ និងអនុម័ត និងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ធនធានមនុស្ស សម្រេចបាន១០០% និងដាក់ក្នុងកិច្ចពិភាក្សា | -ប្រសិទ្ធភាព តម្លាភាព សក្តិសិទ្ធភាព និងសង្គតិភាពរបស់ លេអស ត្រូវបានបញ្ជាក់តាមរយៈរបាយការណ៍សវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ | មន្ត្រីមានសមត្ថភាព និងជំនាញអាកាសចរស៊ីវិលគ្រប់គ្រាន់ក្នុងការអនុវត្តការងារស្របតាមគោលការណ៍ណែនាំផ្សេងៗរបស់រដ្ឋាភិបាល ដើម្បីធានាសុវត្ថិភាព សន្តិសុខនិងឆ្លើយតបបាននៅលក្ខខណ្ឌតម្រូវ |

| | | | | | | |
|---|---|---|---|---|---|---|
| | -កិច្ចសហប្រតិបត្តិការលើវិស័យដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវបានពង្រឹង ដើម្បីបង្កើន និងជម្រុញអ្នកដំណើរនិងទំនិញតាមផ្លូវអាកាស<br><br>-បង្កើនចំណូល និងពង្រឹងប្រសិទ្ធភាពចំណាយ | -មានកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសចំនួន ៣ ស្មើនឹង ៤៦ប្រទេស និងបានធ្វើការតភ្ជាប់ការហោះហើរជាមួយបណ្តាប្រទេសជាដៃគូចំនួន ១២ប្រទេស ស្មើនឹង ៤២អាកាសយានដ្ឋានអន្តរជាតិ និងមានកំណើនអ្នកដំណើរតាមផ្លូវអាកាសចំនួន ១០ ០១៣ ១១៨នាក់។<br><br>-បានសម្របសម្រួល និងបម្រើដល់ជើងហោះហើរពិសេស (VVIP) ជូនថ្នាក់ដឹកនាំស្ថាប័នកំពូល ចំនួន ១៧លើក។ | -នឹងមានកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសចំនួន ៣ ស្មើនឹង ៤៩ប្រទេស និងបានធ្វើការតភ្ជាប់បន្ថែមជាមួយបណ្តាប្រទេសជាដៃគូចំនួន៤ប្រទេស ស្មើនឹង៤៦ប្រទេស និងមានកំណើនអ្នកដំណើរចំនួន ១១ ១៧០ ១២១ នាក់។<br><br>-បាន និងកំពុងសម្របសម្រួល និងបម្រើដល់ជើងហោះហើរពិសេស (VVIP) ជូនថ្នាក់ដឹកនាំស្ថាប័នកំពូល ចំនួន ១៨លើក។ | និងពិគ្រោះយោបល់។<br><br>-នឹងមានកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសចំនួន ៥ស្មើនឹង ៤៥ប្រទេស និងមានការតភ្ជាប់ជាមួយបណ្តាប្រទេសជាដៃគូបន្ថែមចំនួន ១៥ ស្មើនឹង ៤៨អាកាសយានដ្ឋានអន្តរជាតិ និងមានកំណើនអ្នកដំណើរចំនួន ១២ ៤៦៣ ៧៣៧ នាក់<br><br>-នឹងត្រៀមលក្ខណៈដើម្បីបម្រើដល់ជើងហោះហើរពិសេស (VVIP) ជូនថ្នាក់ដឹកនាំស្ថាប័នកំពូលចំនួន២០លើក។ | -កំណើនចំនួនអ្នកដំណើរតាមផ្លូវអាកាស ចំនួន១២% ជាប្រចាំឆ្នាំ និងបង្កើនប្រសិទ្ធភាពចំណូលចំនួន១៥% ជាប្រចាំឆ្នាំ ពីវិស័យអាកាសចរស៊ីវិល។ | ការរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ |
| ✓ **អនុកម្មវិធីទី១:** ការពង្រឹងស្ថាប័ន និងអភិបាលកិច្ច | -ការងារកែលម្អរចនាសម្ព័ន្ធគ្រប់គ្រង | -សេចក្តីព្រាងអង្គការលេខ និងយន្តការពង្រឹងស្ថាប័ន បាននឹងកំពុងរៀបចំ និងកែសម្រួល | -បន្តរៀបចំរៀបចំសេចក្តីព្រាងចុងក្រោយ នៃអង្គការលេខ និងនីតិវិធីគាំទ្រមួយចំនួនទៀត | ធ្វើការពិគ្រោះផ្តល់យោបល់ជាមួយភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍលើសេចក្តីព្រាងចុងក្រោយ នៃអង្គការលេខ និងនីតិវិធី | -រចនាសម្ព័ន្ធគ្រប់គ្រងរបស់ រលអស ឆ្លើយតបទៅតាមលក្ខខ័ណ្ឌតម្រូវការរបស់អង្គការអាកាសចរស៊ីវិលអន្តរ | -ប្រសិទ្ធភាព និងប្រសិទ្ធផល នៃការងារនៅក្នុង រលអស ស្របទៅតាមលក្ខខ័ណ្ឌតម្រូវការរបស់អង្គការអាកាស |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | គាំទ្រមួយចំនួន ទៀត | ជាតិ និងបទដ្ឋានគតិយុត្ត | ចរស៊ីវិលអន្តរជាតិ និង កំណែទម្រង់រដ្ឋ |
| | -រៀបចំផែនការអភិវឌ្ឍធនធានមនុស្ស | -ផែនការអភិវឌ្ឍធនធានមនុស្សបាននឹងកំពុងរៀបចំ និងសម្រេចបាន ៤០% ធៀបនឹងផែនការ រួម | -ផែនការអភិវឌ្ឍធនធានមនុស្ស បាននឹងកំពុងរៀបចំ និងសម្រេចឱ្យបាន៤០% ស្មើនឹង ៨០% ធៀបនឹងផែនការ រួម | -ផែនការអភិវឌ្ឍធនធានមនុស្ស នឹងសម្រេចឱ្យបាន១០០% ធៀបនឹងផែនការរួមនឹងដាក់ធ្វើការពិគ្រោះផ្តល់យោបល់ជាមួយភាគីពាក់ព័ន្ធ និងដៃគូរអភិវឌ្ឍលើសេចក្តីព្រាងចុងក្រោយ | -ផែនការអភិវឌ្ឍធនធានមនុស្សត្រូវបានអនុម័ត និងដាក់ឲ្យប្រើប្រាស់ | -ទទួលបានផែនការអភិវឌ្ឍធនធានមនុស្សគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តបាន |
| | -រៀបចំកម្មវិធីបណ្តុះបណ្តាលក្នុងប្រទេសចំនួន និង ក្រៅប្រទេស | -អនុវត្តកម្មវិធីបណ្តុះបណ្តាលក្នុងប្រទេសបានចំនួន ២៤វគ្គ និងក្រៅប្រទេសបាន ៣៥វគ្គ | -បាន និងកំពុងអនុវត្តកម្មវិធីបណ្តុះបណ្តាលក្នុងប្រទេសបានចំនួន ២៥វគ្គ និងក្រៅប្រទេសបានចំនួន ៣៥វគ្គ | -បន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៤៤វគ្គ និងក្រៅប្រទេសចំនួន ១៦៣វគ្គ | -លទ្ធផលដូចមាននៅក្នុងសូចនាករចុងក្រោយរបស់ អនុកម្មវិធីទី១ នៃ កម្មវិធីទី១ | -ទទួលបានកម្មវិធីបណ្តុះបណ្តាលមួយដែលឆ្លើយតបបានទៅតាមលក្ខខ័ណ្ឌតម្រូវការនិងស្តង់ដារបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ |
| ✓ **អនុកម្មវិធីទី២:** សេវាគាំទ្រ និងការចូលរួម | -ជំរុញ និងធ្វើឱ្យមានកំណើនសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស | -បានធ្វើការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសចំនួន ៣ ស្មើនឹងចំនួនសរុប ៤៦ ប្រទេស | -បាននឹងកំពុងធ្វើការចរចា និងត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសចំនួន ៣ ប្រទេស ស្មើនឹងចំនួនសរុប ៤៩ ប្រទេស | -នឹងបន្តធ្វើការចរចាដើម្បីពង្រីកកិច្ចសហប្រតិបត្តិការ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសចំនួន ៥ ប្រទេសស្មើនឹងចំនួនសរុប ៥៤ ប្រទេស | -មានកំណើនអ្នកដំណើរតាមផ្លូវអាកាសចំនួន ១២% និងការតភ្ជាប់ការ ហោះហើរក្នុងតំបន់ និងអន្តរជាតិ | ទទួលបាននូវកំណើនអ្នកដំណើរ, ទំនិញ,និងចំនួនជើងហោះហើរតាមផ្លូវអាកាស |

| | | | | | | |
|---|---|---|---|---|---|---|
| | -ជំរុញសមាហរណកម្មទីផ្សារអាកាសចរស៊ីវិលតែមួយរបស់អាស៊ាន | -ប្រទេសចំនួន ១២ ស្មើនឹងចំនួនសរុប ៤២ អាកាសយានដ្ឋានអន្តរជាតិបានធ្វើការតភ្ជាប់ការហោះហើរពីប្រទេសកម្ពុជា<br><br>-អ្នកដំណើរចំនួន ១០ ០១៣ ១១៨ នាក់បានធ្វើដំណើរតាមផ្លូវអាកាស និងទំនិញចំនួន ៧៣ ៥៩១តោន បានដឹកជញ្ជូនតាមផ្លូវអាកាស | -ប្រទេសចំនួន ១៣ ស្មើនឹងចំនួនសរុប ៤៦ អាកាសយានដ្ឋានអន្តរជាតិបានធ្វើការតភ្ជាប់ការហោះហើរពីប្រទេសកម្ពុជា<br><br>-នឹងមានអ្នកដំណើរចំនួន ១១ ១៧០ ១២១ នាក់ធ្វើដំណើរតាមផ្លូវអាកាស និងទំនិញចំនួន ៨០ ៩៣១ តោន បានដឹកជញ្ជូនតាមផ្លូវអាកាស | -នឹងមានប្រទេសចំនួន ១៥ ស្មើនឹងចំនួនសរុប ៤៨ អាកាសយានដ្ឋានអន្តរជាតិនឹងធ្វើការតភ្ជាប់ការហោះហើរពីប្រទេសកម្ពុជា<br><br>-នឹងមានអ្នកដំណើរចំនួន ១២ ៤៦៣ ៧៣៧ នាក់ធ្វើដំណើរតាមផ្លូវអាកាស និងទំនិញចំនួន ៨៩ ០០៤ តោន បានដឹកជញ្ជូនតាមផ្លូវអាកាស | | |
| | -ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូល-ចំណាយ | -ចំណូលសម្រេចបាន ១៧៣ ៥៧៣លានរៀល កើនឡើង២៩% ធៀបនឹងច្បាប់ និង<br><br>-ចំណាយសម្រេចបាន ៥៨ ៣២៦ លានរៀល ស្មើនឹង៩៦% ធៀបនឹងច្បាប់ | -ចំណូលនឹងសម្រេចបាន ២២៨ ១៧៣លានរៀល ថយចុះចំនួន ១៩ ០១៤ លានរៀល ដោយ ហេតុចំណូលពី ADS Profit Sharing ចំនួន ២៩ ៥៦៥លានរៀល និង<br><br>-ចំណាយនឹងសម្រេចបាន ៥៥ ៧១៦ លានរៀល ស្មើនឹង ៩៩,៨% ធៀបនឹងច្បាប់ | -ចំណូលនឹងសម្រេចឱ្យបានចំនួន២៣១ ៦៤៣ លានរៀល និង<br><br>-ចំណាយគ្រោងចំនួន ៦០ ៤៣៥ លានរៀល | -ការអនុវត្តចំណូលមានកំណើន ១៥% និងប្រសិទ្ធភាពនៃការចំណាយមានសង្គតិភាពជាមួយនឹងផែនការដែលបានកំណត់ | -កម្មវិធីចំណូល និង ចំណាយគឺ ស្មើ +/- ៥% ធៀបនឹងផែនការដែលបានកំណត់ និង គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល |

## V. ការកំណត់ធនធាន

ក. ការគ្រោងចំណូល

ដើម្បីរួមចំណែកការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម (២០១៩-២០២៣) របស់រាជរដ្ឋាភិបាល និងដើម្បីចូលរួមសម្រេចឱ្យបានគោលដៅសូចនាករចំណូលដែលបានកំណត់ក្នុងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២០-២០២២ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានដាក់ចេញនូវវិធានការមួយចំនួន ដើម្បីពង្រឹងការប្រមូលចំណូលដូចខាងក្រោមៈ

ក. ពង្រឹងគោលនយោបាយ និងផែនការសកម្មភាពដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយសម្រាប់រយៈពេលខ្លី មធ្យម និងវែង ជាពិសេសវិធានការក្នុងការតាមដាន កត់ត្រា ការកៀរគរចំណូល និងវិធានការតឹងទារបំណុល។

ខ. ចាត់វិធានការលើកកម្ពស់ប្រសិទ្ធភាពប្រមូលចំណូល និងពង្រឹងយន្តការគ្រប់គ្រង អនុលោមភាពកិច្ចសន្យានានា ជាមួយក្រុមហ៊ុនឯកជន ដូចជាពង្រឹងការធ្វើបច្ចុប្បន្នភាពថ្លៃឈ្នួលទ្រព្យសម្បត្តិរដ្ឋ ថ្លៃកម្រៃសេវាសាធារណៈដែលត្រូវបង់ចូលរដ្ឋ។

គ. ប្រឹងប្រែងប្រមូលចំណូលឱ្យអស់លទ្ធភាព និងអស់សក្តានុពល តាមរយៈការអនុវត្តឱ្យមានប្រសិទ្ធភាពនូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៩-២០២៣ ដែលបានប្រកាសឱ្យអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩។

តាមរយៈវិធានការទាំងនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានគ្រោងចំណូលដូចខាងក្រោមៈ

### រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

តារាង ៣ : ការគ្រោងចំណូល

ឯកតា : លានរៀល

| ការគ្រោងចំណូលតាមប្រភេទចំណូល | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ | | | គ្រោងឆ្នាំ២០២០ | | | គ្រោងឆ្នាំ២០២១ | | | គ្រោងឆ្នាំ២០២២ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ |
| **សរុបរួម** | ២៤៧ ១៩១.៨ | | | ២៦១ ២០៤.០ | ៣ ៨៩៩ ៩៥២.៥ | | ២៦៩ ០៣៥.៥ | ៣ ៨៩៧ ៩៥០.០ | | ១៦៨ ០៦០.៣ | ៣ ៨៩៧ ៩៥០.០ | |
| **១. ចំណូលពីប្រភពក្នុងស្រុក** | ២៤៧ ១៩១.៨ | | | ២៦១ ២០៤.០ | | | ២៦៩ ០៣៥.៥ | | | ១៦៨ ០៦០.៣ | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ○ ចំណូលសារពើពន្ធ | .0 | | | .0 | | | .0 | | | .0 | | |
| ○ ចំណូលមិនមែនសារពើពន្ធ | ២៤៧ ១៩១.៨ | | | ២៦១ ២០៤.០ | | | ២៦៩ ០៣៥.៥ | | | ១៦៨ ០៦០.៣ | | |
| - ផលទុនអាកាសចរស៊ីវិល | ២៤៧ ០១៦.០ | | | ២៦១ ០៥០.៤ | | | ២៦៨ ៨៨១.៩ | | | ១៦៨ ០៦០.៣ | | |
| - ការជួលដីទំនេរ | ៧៥.៧ | | | ៥៣.៥ | | | ៥៣.៥ | | | ៧៥.៧ | | |
| - ការជួលអចលនវត្ថុ | ១០០.១ | | | ១០០.១ | | | ១០០.១ | | | ១០០.១ | | |
| ○ ចំណូលមូលធនក្នុងស្រុក | .0 | | | .0 | | | .0 | | | .0 | | |
| ២. គម្រោងវិនិយោគ | | | | | ៣ ៨៩៩ ៤៥២.៥ | | | ៣ ៨៩៧ ៤៥០.០ | | | ៣ ៨៩៧ ៤៥០.០ | |
| ○ មានហិរញ្ញប្បទាន | | | | | ៣ ៥៦៤ ០០០.០ | | | ៣ ៥៦៤ ០០០.០ | | | ៣ ៥៦៤ ០០០.០ | |
| ○ មិនមានហិរញ្ញប្បទាន | | | | | ៣៣៣ ៤៥០.០ | | | ៣៣៣ ៤៥០.០ | | | ៣៣៣ ៤៥០.០ | |
| | | | | | ២ ០០២.៥ | | | | | | | |
| ៣- ជំនួយបច្ចេកទេស | | | | | ២ ០០២.៥ | | | | | | | |
| ○ មានហិរញ្ញប្បទាន | | | | | | | | | | | | |

ខ. ការកំណត់តម្រូវការចំណាយ

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

**តារាង ៤ : ការកំណត់តម្រូវការចំណាយសម្រាប់កម្មវិធី និងអនុកម្មវិធី**

ឯកតា: លានរៀល

| តម្រូវការផលទាន តាមប្រភេទ ចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៩ | | | គ្រោងតម្រូវការផលទាន សម្រាប់ឆ្នាំ២០២០ | | | គ្រោងតម្រូវការផលទាន សម្រាប់ឆ្នាំ២០២១ | | | គ្រោងតម្រូវការផលទាន សម្រាប់ឆ្នាំ២០២២ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូ អភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូ អភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូ អភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូ អភិវឌ្ឍ | ផ្សេងៗ |
| សរុបរួម | ៥៥ ៨១២.៣ | | | ៦០ ៤៣៥.៨ | ៣ ៨៩៩ ៤៥២.៥ | | ៦៣ ០៥៨.៦ | ៣ ៨៩៧ ៤៥០.០ | | ៦៧ ១៧៥.៧ | ៣ ៨៩៧ ៤៥០.០ | |
| ○ សរុបចំណាយចរន្ត | ៥៥ ៨១២.៣ | | | ៦០ ៤៣៥.៨ | | | ៦៣ ០៥៨.៦ | | | ៦៧ ១៧៥.៧ | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| • បន្ទុកបុគ្គលិក<br>• ក្រៅបន្ទុកបុគ្គលិក<br>○សរុបចំណាយមូលធន<br>• គម្រោងវិនិយោគ<br>- មានហិរញ្ញប្បទាន<br>- មិនទាន់មានហិរញ្ញប្បទាន<br>• ជំនួយបច្ចេកទេស<br>- មានហិរញ្ញប្បទាន<br>- មិនទាន់មានហិរញ្ញប្បទាន | ២៩ ៧៨១.៣<br>២៦ ០៣១.០ | | | ៣១ ៧៦៥.០<br>២៨ ៦៧០.៨ | ៣ ៨៩៩ ៤៥២.៥<br>៣ ៨៩៩ ៤៥២.៥<br>៣ ៥៦៤ ០០០.០<br>៣៣៣ ៤៥០.០<br>២ ០០២.៥<br>២ ០០២.៥ | | ៣៤ ២៦៥.៨<br>២៩ ២៤២.៨ | ៣ ៨៩៧ ៤៥០.០<br>៣ ៨៩៧ ៤៥០.០<br>៣ ៥៦៤ ០០០.០<br>៣៣៣ ៤៥០.០ | | ៣៣ ២៨៣.៥<br>៣៣ ៨៩២.២ | ៣ ៨៩៧ ៤៥០.០<br>៣ ៨៩៧ ៤៥០.០<br>៣ ៥៦៤ ០០០.០<br>៣៣៣ ៤៥០.០ | |
| ១. គោលបំណងគោលនយោបាយទី១<br>○សរុបចំណាយចរន្ត<br>• បន្ទុកបុគ្គលិក<br>• ក្រៅបន្ទុកបុគ្គលិក<br>○សរុបចំណាយមូលធន<br>• គម្រោងវិនិយោគ<br>- មានហិរញ្ញប្បទាន<br>- មិនទាន់មានហិរញ្ញប្បទាន<br>• ជំនួយបច្ចេកទេស<br>- មានហិរញ្ញប្បទាន<br>- មិនទាន់មានហិរញ្ញប្បទាន | ៥៥ ៨១២.៣<br>៥៥ ៨១២.៣<br>២៩ ៧៨១.៣<br>២៦ ០៣១.០ | | | ៦០ ៤៣៥.៨<br>៦០ ៤៣៥.៨<br>៣១ ៧៦៥.០<br>២៨ ៦៧០.៨ | ៣ ៨៩៩ ៤៥២.៥<br>៣ ៨៩៩ ៤៥២.៥<br>៣ ៨៩៩ ៤៥២.៥<br>៣ ៥៦៤ ០០០.០<br>៣៣៣ ៤៥០.០<br>២ ០០២.៥<br>២ ០០២.៥ | | ៦៣ ០៥៨.៦<br>៦៣ ០៥៨.៦<br>៣៤ ២៦៥.៨<br>២៩ ២៤២.៨ | ៣ ៨៩៧ ៤៥០.០<br>៣ ៨៩៧ ៤៥០.០<br>៣ ៨៩៧ ៤៥០.០<br>៣ ៥៦៤ ០០០.០<br>៣៣៣ ៤៥០.០ | | ៦៧ ១៧៥.៧<br>៦៧ ១៧៥.៧<br>៣៣ ២៨៣.៥<br>៣៣ ៨៩២.២ | ៣ ៨៩៧ ៤៥០.០<br>៣ ៨៩៧ ៤៥០.០<br>៣ ៨៩៧ ៤៥០.០<br>៣ ៥៦៤ ០០០.០<br>៣៣៣ ៤៥០.០ | |
| ១.១ កម្មវិធីទី១<br>○សរុបចំណាយចរន្ត<br>• បន្ទុកបុគ្គលិក<br>• ក្រៅបន្ទុកបុគ្គលិក | ៥ ៨៧៤.៩<br>៥ ៨៧៤.៩<br>.០ | | | ៦ ២៨៥.៤<br>៦ ២៨៥.៤<br>.០ | ៣ ៨៩៧ ៤៥០.០ | | ៦ ៥៩៩.៧<br>៦ ៥៩៩.៧<br>.០ | ៣ ៨៩៧ ៤៥០.០ | | ៦ ៩២៩.៧<br>៦ ៩២៩.៧<br>.០<br>៦ ៩២៩.៧ | ៣ ៨៩៧ ៤៥០.០ | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ○សរុបចំណាយមូលធន | ៥ ៨៧៤.៩ | | | ៦ ២៨៥.៤ | ៣ ៨៩៧ ៤៥០.០ | | ៦ ៥៩៩.៧ | ៣ ៨៩៧ ៤៥០.០ | | | ៣ ៨៩៧ ៤៥០.០ | |
| • គម្រោងវិនិយោគ | | | | | ៣ ៨៩៧ ៤៥០.០ | | | ៣ ៨៩៧ ៤៥០.០ | | | ៣ ៨៩៧ ៤៥០.០ | |
| - មានហិរញ្ញប្បទាន | | | | | ៣ ៥៦៤ ០០០.០ | | | ៣ ៥៦៤ ០០០.០ | | | ៣ ៥៦៤ ០០០.០ | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | ៣៣៣ ៤៥០.០ | | | ៣៣៣ ៤៥០.០ | | | ៣៣៣ ៤៥០.០ | |
| • ជំនួយបច្ចេកទេស | | | | | | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | | | | | | | | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១.១.១ អនុកម្មវិធីទី១ | ៥ ១៣៥.៤ | | | ៥ ៥០៧.៥ | ៣ ៨៦១ ០០០.០ | | ៥ ៧៨២.៩ | ៣ ៨៦១ ០០០.០ | | ៦ ០៧២.០ | ៣ ៨៦១ ០០០.០ | |
| ○សរុបចំណាយចរន្ត | ៥ ១៣៥.៤ | | | ៥ ៥០៧.៥ | | | ៥ ៧៨២.៩ | | | ៦ ០៧២.០ | | |
| • បន្ទុកបុគ្គលិក | .០ | | | .០ | | | .០ | | | .០ | | |
| • ក្រៅបន្ទុកបុគ្គលិក | ៥ ១៣៥.៤ | | | ៥ ៥០៧.៥ | | | ៥ ៧៨២.៩ | | | ៦ ០៧២.០ | | |
| ○សរុបចំណាយមូលធន | | | | | ៣ ៨៦១ ០០០.០ | | | ៣ ៨៦១ ០០០.០ | | | ៣ ៨៦១ ០០០.០ | |
| • គម្រោងវិនិយោគ | | | | | ៣ ៨៦១ ០០០.០ | | | ៣ ៨៦១ ០០០.០ | | | ៣ ៨៦១ ០០០.០ | |
| - មានហិរញ្ញប្បទាន | | | | | ៣ ៥៦៤ ០០០.០ | | | ៣ ៥៦៤ ០០០.០ | | | ៣ ៥៦៤ ០០០.០ | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | ២៩៧ ០០០.០ | | | ២៩៧ ០០០.០ | | | ២៩៧ ០០០.០ | |
| • ជំនួយបច្ចេកទេស | | | | | | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | | | | | | | | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១.១.២ អនុកម្មវិធីទី២ | ៣៩៨.៥ | | | ៤៣៤.២ | | | ៤៥៥.៩ | | | ៤៧៨.៧ | | |
| ○សរុបចំណាយចរន្ត | ៣៩៨.៥ | | | ៤៣៤.២ | | | ៤៥៥.៩ | | | ៤៧៨.៧ | | |
| • បន្ទុកបុគ្គលិក | .០ | | | .០ | | | .០ | | | .០ | | |
| • ក្រៅបន្ទុកបុគ្គលិក | ៣៩៨.៥ | | | ៤៣៤.២ | | | ៤៥៥.៩ | | | ៤៧៨.៧ | | |
| ○សរុបចំណាយមូលធន | | | | | | | | | | | | |
| • គម្រោងវិនិយោគ | | | | | | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| • ជំនួយបច្ចេកទេស | | | | | | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | | | | | | | | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១.១.៣ អនុកម្មវិធីទី៣ | ៣៤១.០ | | | ៣៤៣.៧ | ៣៦ ៤៥០.០ | | ៣៦១.០ | ៣៦ ៤៥០.០ | | ៣៧៨.៩ | ៣៦ ៤៥០.០ | |
| ○ សរុបចំណាយចរន្ត | ៣៤១.០ | | | ៣៤៣.៧ | | | ៣៦១.០ | | | ៣៧៨.៩ | | |
| • បន្ទុកបុគ្គលិក | .០ | | | .០ | | | .០ | | | .០ | | |
| • ក្រៅបន្ទុកបុគ្គលិក | ៣៤១.០ | | | ៣៤៣.៧ | | | ៣៦១.០ | | | ៣៧៨.៩ | | |
| ○ សរុបចំណាយមូលធន | | | | | ៣៦ ៤៥០.០ | | | ៣៦ ៤៥០.០ | | | ៣៦ ៤៥០.០ | |
| • គម្រោងវិនិយោគ | | | | | ៣៦ ៤៥០.០ | | | ៣៦ ៤៥០.០ | | | ៣៦ ៤៥០.០ | |
| - មានហិរញ្ញប្បទាន | | | | | | | | | | | | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | ៣៦ ៤៥០.០ | | | ៣៦ ៤៥០.០ | | | ៣៦ ៤៥០.០ | |
| • ជំនួយបច្ចេកទេស | | | | | | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | | | | | | | | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១.២ កម្មវិធីទី២ | ៤៩ ៩៣៧.៤ | | | ៥៤ ១៤៩.៦ | ២ ០០២.៥ | | ៥៦ ៩០៩.០ | | | ៦០ ៩៤៤.២ | | |
| ○ សរុបចំណាយចរន្ត | ៤៩ ៩៣៧.៤ | | | ៥៤ ១៤៩.៦ | | | ៥៦ ៩០៩.០ | | | ៦០ ៩៤៤.២ | | |
| • បន្ទុកបុគ្គលិក | ២៩ ៧៨១.៣ | | | ៣១ ៧៦៥.០ | | | ៣៤ ២៦៥.៨ | | | ៣៧ ១៦៨.៩ | | |
| • ក្រៅបន្ទុកបុគ្គលិក | ២០ ១៥៦.១ | | | ២២ ៣៨៥.៤ | | | ២២ ៦៤៣.២ | | | ២៣ ៧៧៥.៣ | | |
| ○ សរុបចំណាយមូលធន | | | | | ២ ០០២.៥ | | | | | | | |
| • គម្រោងវិនិយោគ | | | | | | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | | | | | | | | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| • ជំនួយបច្ចេកទេស | | | | | ២ ០០២.៥ | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | ២ ០០២.៥ | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១.២.១ អនុកម្មវិធីទី១ | ៣២ ៨៣១.៦ | | | ៣៥ ២៩៧.៣ | | | ៣៧ ៩៧៥.៦ | | | ៤១ ០៦៤.២ | | |
| ○ សរុបចំណាយចរន្ត | ៣២ ៨៣១.៦ | | | ៣៥ ២៩៧.៣ | | | ៣៧ ៩៧៥.៦ | | | ៤១ ០៦៤.២ | | |
| • បន្ទុកបុគ្គលិក | ២៩ ៧៨១.៣ | | | ៣១ ៧៦៥.០ | | | ៣៤ ២៦៥.៨ | | | ៣៧ ១៦៨.៩ | | |
| • ក្រៅបន្ទុកបុគ្គលិក | ៣ ០៥០.៣ | | | ៣ ៥៣៣.១ | | | ៣ ៧០៩.៨ | | | ៣ ៨៩៥.៣ | | |
| ○ សរុបចំណាយមូលធន | | | | | | | | | | | | |
| • គម្រោងវិនិយោគ | | | | | | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | | | | | | | | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| • ជំនួយបច្ចេកទេស | | | | | | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | | | | | | | | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១.២.២ អនុកម្មវិធីទី២ | ១៧ ១០៥.៨ | | | ១៨ ៨៥២.៣ | ២ ០០២.៥ | | ១៨ ៩៣៣.៤ | | | ១៩ ៨៨០.១ | | |
| ○ សរុបចំណាយចរន្ត | ១៧ ១០៥.៨ | | | ១៨ ៨៥២.៣ | | | ១៨ ៩៣៣.៤ | | | ១៩ ៨៨០.១ | | |
| • បន្ទុកបុគ្គលិក | .០ | | | .០ | | | .០ | | | .០ | | |
| • ក្រៅបន្ទុកបុគ្គលិក | ១៧ ១០៥.៨ | | | ១៨ ៨៥២.៣ | | | ១៨ ៩៣៣.៤ | | | ១៩ ៨៨០.១ | | |
| ○ សរុបចំណាយមូលធន | | | | | ២ ០០២.៥ | | | | | | | |
| • គម្រោងវិនិយោគ | | | | | | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | | | | | | | | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| • ជំនួយបច្ចេកទេស | | | | | ២ ០០២.៥ | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | ២ ០០២.៥ | | | | | | | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |

## VI. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២០-២០២២ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល គឺជាមូលដ្ឋានមួយដ៏សំខាន់សម្រាប់ចូលរួមចំណែកនៅក្នុងដំណាក់កាលទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេសគឺការអនុវត្តសាកល្បងក្របខណ្ឌថវិការយៈពេលមធ្យម ឆ្នាំ២០២០-២០២២ ដើម្បីបង្កើនសុក្រឹត្យភាពក្នុងការគណនាតម្រូវការថវិកា ជាមូលដ្ឋានសម្រាប់ពន្យល់ និងធ្វើអំណះអំណាងលើតម្រូវការថវិកា ជានានិរន្ត ភាពនៃកម្មវិធី និងយុទ្ធសាស្រ្តអាទិភាព និងពិសេសគឺជាមូលដ្ឋានសម្រាប់វាយតម្លៃលើអាទិភាពក្នុងការកំណត់កញ្ចប់ និងវិភាជន៍ថវិកា។ ផែនការសកម្មភាពទាំងអស់នេះជាធាតុចូលដ៏សំខាន់ដើម្បីធានា និងពង្រឹងនូវចិរភាពនៃប្រតិបត្តិការសុវត្ថិភាពហោះហើរ សន្តិសុខបរិស្ថាន សណ្តាប់ធ្នាប់ និងការធ្វើ ពិពិធកម្មសេវាកម្មដឹកជញ្ជូនផ្លូវអាកាស តាមរយៈវិធានការដាក់លាក់ដោយឈរលើមូលដ្ឋានទូលំទូលាយ និងមានមូលដ្ឋានបច្ចេកទេស-សេដ្ឋកិច្ចប្រកួតប្រជែងជាងមុន ប្រកបដោយសមធម៌ កាលានុវត្តភាព និង ផ្លែផ្កានៃកំណើន សេដ្ឋកិច្ច ជាពិសេសតាមរយៈការគ្រប់គ្រង និងប្រើប្រាស់ធនធានថវិកាជាតិ ដែលទទួលបានប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងចិរភាព។

ថ្ងៃសុក្រ ៧កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១៩

**រដ្ឋមន្ត្រី**

**ម៉ៅ ហាវណ្ណាល់**